

សង្ខេបរបាយការណ៍ពិនិត្យតាមដានការអប់រំជាសកល

២០២១/២

ភាសាមិនមែនរដ្ឋ ក្នុងការងារអប់រំនៃ

នរណាជាអ្នកជ្រើសរើស? នរណាជាអ្នកខាតបង់?

unesco

Sustainable Development Goals

Global Education Monitoring Report

សង្ខេបរបាយការណ៍ពិនិត្យតាមដានការអប់រំជាសកល

២០២១/២

តួអង្គមិនមែនរដ្ឋ ក្នុងការងារអប់រំ

នរណាជាអ្នកជ្រើសរើស? នរណាជាអ្នកខាតបង់?

សេចក្តីប្រកាសអ៊ីនឈ័ន និងក្របខ័ណ្ឌសកម្មភាពវិស័យអប់រំ ឆ្នាំ ២០៣០ ចែងថា របាយការណ៍ពិនិត្យតាមដានការអប់រំជាសកល មានតួនាទីជា "យន្តការសម្រាប់ពិនិត្យតាមដាន និងរាយការណ៍ពីគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤ និងពីការអប់រំ ដែលត្រូវបានបញ្ចូលទៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពផ្សេងទៀត" និង "រាយការណ៍ពីការអនុវត្តយុទ្ធសាស្ត្រជាតិ និងអន្តរជាតិ ដើម្បីទាមទារឱ្យគ្រប់ដៃគូពាក់ព័ន្ធទាំងអស់មានគណនេយ្យភាពចំពោះអ្វីដែលពួកគេបានសន្យា ជាផ្នែកមួយនៃការតាមដានបន្ត និងការពិនិត្យលើគោលដៅអភិវឌ្ឍន៍ដោយចីរភាពជារួម"។ របាយការណ៍នេះត្រូវបានរៀបចំឡើងដោយអ្នកជំនាញឯករាជ្យមួយក្រុម ក្រោមការដឹកនាំរបស់យូណេស្កូ។

ឈ្មោះតួនាទី ដែលត្រូវបានប្រើប្រាស់ និងព័ត៌មានដែលបង្ហាញក្នុងឯកសារបោះពុម្ពផ្សាយនេះ មិនមែនជាការបញ្ចេញមតិរបស់យូណេស្កូ ពាក់ព័ន្ធនឹងស្ថានភាពស្របច្បាប់របស់ប្រទេស ដែនដី ទីក្រុង ឬតំបន់ណាមួយ ឬសមត្ថកិច្ចរបស់ប្រទេស ដែនដី ទីក្រុង ឬតំបន់នេះ ឬពាក់ព័ន្ធនឹងការកំណត់ព្រំប្រទល់ដែនរបស់ប្រទេស ដែនដី ទីក្រុង ឬតំបន់ទាំងនេះឡើយ។

ក្រុមការងាររៀបចំរបាយការណ៍ពិនិត្យតាមដានការអប់រំជាសកលនេះ គឺជាអ្នកទទួលខុសត្រូវលើការជ្រើសរើស និងការបង្ហាញអង្គហេតុ ក្នុងឯកសារបោះពុម្ពផ្សាយនេះ និងលើទស្សនៈដែលត្រូវបានបញ្ចេញក្នុងឯកសារនេះ។ ទស្សនៈទាំងនេះមិនមែនជាទស្សនៈយូណេស្កូ ហើយមិនតម្រូវឲ្យយូណេស្កូជាប់កាតព្វកិច្ចអ្វីមួយឡើយ។ ប្រធានក្រុមការងារនេះជាអ្នកទទួលខុសត្រូវជារួមលើគំនិតយោបល់ និងទស្សនៈយល់ឃើញ ដែលត្រូវបានលើកឡើងក្នុងរបាយការណ៍នេះ។

ក្រុមការងាររៀបចំរបាយការណ៍ពិនិត្យតាមដានការអប់រំជាសកល


ប្រធានក្រុម៖ Manos Antoninis

Daniel April, Bilal Barakat, Marcela Maria Barrios Rivera, Madeleine Barry, Katherine Black, Nicole Bella, Celia Eugenia Calvo Gutierez, Daniel Caro Vasquez, Anna Cristina D'Addio, Dimitra Dafalia, Dmitri Davydov, Francesca Endrizzi, Constanza Ginestra, Chandni Jain, Priyadarshani Joshi, Maria-Rafaela Kaldi, Josephine Kiyenje, Craig Laird, Katie Lazaro, Kate Linkins, Camila Lima De Moraes, Kassiani Lythrangomitis, Anissa Mechtar, Claudine Mukizwa, Yuki Murakami, Manuela Pombo Polanco, Judith Randrianatoavina, Kate Redman, Maria Rojnov, Laura Stipanovic, Ulrich Janse van Vuuren, Juliana Zapata, Lema Zekrya និង Jiaheng Zhou។

របាយការណ៍ពិនិត្យតាមដានការអប់រំជាសកលនេះ គឺជាឯកសារបោះពុម្ពផ្សាយឯករាជ្យប្រចាំឆ្នាំ។ របាយការណ៍ GEM នេះ ត្រូវបានរៀបចំឡើងក្រោមការឧបត្ថម្ភថវិកាពីរដ្ឋាភិបាល ទីភ្នាក់ងារពហុភាគី និងមូលនិធិឯកជន និងមានការសម្របសម្រួល និងការគាំទ្រពីយូណេស្កូ។

ឯកសារបោះពុម្ពផ្សាយនេះត្រូវបានផ្សព្វផ្សាយឱ្យមានការប្រើប្រាស់ជាចំហ ក្រោមអាជ្ញាប័ណ្ណ 3.0 IGO (CC-BY-SA 3.0 IGO) licence (http://creativecommons.org/licenses/by-sa/3.0/igo/)តាមរយៈការដកស្រង់ខ្លឹមសារពីឯកសារបោះពុម្ពផ្សាយនេះទៅប្រើប្រាស់ អ្នកប្រើប្រាស់ទទួលថាខ្លួននឹងជាប់កាតព្វកិច្ចគោរពតាមលក្ខខណ្ឌនៃការប្រើប្រាស់ ដែលកំណត់ដោយបណ្ណាល័យដែលអាចចូលប្រើប្រាស់ដោយសេរីរបស់យូណេស្កូ (http://www.unesco.org/open-access/ terms-use-ccbysa-en).

អាជ្ញាប័ណ្ណនេះអនុវត្តទាំងស្រុងចំពោះខ្លឹមសារអត្ថបទនៃឯកសារនេះ។ សម្រាប់ការប្រើប្រាស់ខ្លឹមសារទាំងឡាយ ដែលពុំត្រូវបានកំណត់ជាក់ច្បាស់ថាជារបស់យូណេស្កូ ចាំបាច់ត្រូវមានការស្នើសុំការអនុញ្ញាតជាមុនពីៈ publication.copyright@unesco.org or UNESCO Publishing, 7, place de Fontenoy, 75352 Paris 07 SP France.



ចំណងជើងដើមជាភាសាអង់គ្លេសៈ UNESCO. 2021. Global Education Monitoring Report 2021/2:
ឈ្មោះឯកសារយោង នៃរបាយការណ៍នេះៈ Non-state actors in education: Who chooses? Who loses? Paris, UNESCO.

© UNESCO, 2021

កំណែទី ១
បោះពុម្ពផ្សាយក្នុងឆ្នាំ ២០២១ ដោយអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌នៃសហប្រជាជាតិ 7, Place de Fontenoy, 75352 Paris 07 SP, France

វាយអត្ថបទដោយយូណេស្កូ
រចនាក្រាហ្វិចដោយ Optima Graphic Design Consultants Ltd Layout by Optima Graphic Design Consultants Ltd

Cover photo: Jaap Joris Vens / Super Formosa Photography

Caption: Different routes to school, the Netherlands.

Illustrations by Housatonic

Cartoons by Julio Carrión Cueva (Karry) and Miguel Morales Madrigal

Infographics by Housatonic

ED-2021/WS/38

របាយការណ៍ពិនិត្យតាមដានស្ថានភាពនៃការអប់រំជាសកលៈ

២០២១/២ តួអង្គមិនមែនរដ្ឋក្នុងការងារអប់រំៈ នរណាជាអ្នកជ្រើសរើស? នរណាជាអ្នកខាតបង់?
២០២០ បរិយាបន្ន និងការអប់រំៈ ទាំងអស់គ្នាមានន័យថាទាំងអស់គ្នា
២០១៩ ការធ្វើចំណាកស្រុក ការខ្វាតខ្វាយពីផ្ទះសម្បែង និងការអប់រំៈ សង់ស្ពានចម្លង មិនមែនសង់ជញ្ជាំងនោះទេ
២០១៧/៨ គណនេយ្យភាព ក្នុងវិស័យអប់រំៈ គោរពតាមអ្វីដែលយើងបានសន្យា
២០១៦ ការអប់រំ សម្រាប់មនុស្ស និងផែនដីៈ បង្កើតអនាគតប្រកបដោយនិរន្តរភាព សម្រាប់ទាំងអស់គ្នា

របាយការណ៍ពិនិត្យតាមដានទូទាំងសកលលោកសម្រាប់ការអប់រំសម្រាប់ទាំងអស់គ្នា

២០១៥ ការអប់រំសម្រាប់ទាំងអស់គ្នា ២០០០-២០១៥ៈ សមិទ្ធផលសម្រេចបាន និងបញ្ហាប្រឈម
២០១៣/៤ ការបង្រៀន និងរៀនៈ សម្រេចឲ្យបាននូវគុណភាព សម្រាប់ទាំងអស់គ្នា
២០១២ យុវជន និងជំនាញៈ ប្រែក្លាយការអប់រំ ជាការបំពេញការងារ
២០១១ បៃតិលាក់មុខៈ ជម្លោះប្រដាប់អាវុធ និងការអប់រំ
២០១០ ការផ្តល់សេវាដល់ក្រុមដែលពុំមានឱកាស
២០០៩ ការជំនះវិសមភាពៈ ហេតុអ្វីបានជាអភិបាលកិច្ចមានសារៈសំខាន់
២០០៨ ការអប់រំសម្រាប់ទាំងអស់គ្នាត្រឹមឆ្នាំ ២០១៥ៈ តើយើងអាចសម្រេចវាបានដែរឬទេ?
២០០៧ មូលដ្ឋានរឹងមាំៈ ការគាំពារ និងអប់រំកុមារតូច
២០០៦ អក្ខរកម្ម ដើម្បីជីវិត
២០០៥ ការអប់រំសម្រាប់ទាំងអស់គ្នាៈ គុណភាពដែលចាំបាច់ត្រូវមាន
២០០៣/៤ យេនឌ័រ និងការអប់រំសម្រាប់ទាំងអស់គ្នាៈ ការបោះជំហានទៅរកសមភាព
២០០២ ការអប់រំសម្រាប់ទាំងអស់គ្នាៈ តើពិភពលោកស្ថិតតាមផែនការដែលបានគ្រោងទុកដែរឬទេ?

របាយការណ៍សង្ខេប និងឯកសារពាក់ព័ន្ធនានា អាចដោនឡូតពីៈ Bit.ly/2021gemreport

សារគន្លឹះ..... ១
មានការគាំទ្រខ្លាំងក្លាដល់ការអប់រំសាធារណៈ ៣
ទទ្ទឹកករណ៍ផ្សេងៗគ្នាជំរុញឱ្យមានការជជែកវែកញែក ដែលគាំទ្រ ឬប្រឆាំងនឹងការផ្តល់សេវាអប់រំដោយ
តួអង្គមិនមែនរដ្ឋ ៣
ការយល់មិនត្រឹមត្រូវអំពីតួអង្គរដ្ឋ និងតួអង្គមិនមែនរដ្ឋក្នុងការងារអប់រំនៅតែបន្តមាន ៥
ការផ្តល់សេវាអប់រំ ៩
អភិបាលកិច្ច និងការធ្វើនិយ័តកម្ម ១១
ហិរញ្ញវត្ថុ ១២
ឥទ្ធិពល ១៤
ការគាំពារ និងអប់រំកុមារតូច ១៥
ការអប់រំនៅកម្រិតឧត្តមសិក្សា ១៦
ការអប់រំបច្ចេកទេសវិជ្ជាជីវៈ និងការអប់រំមនុស្សពេញវ័យ ១៧
អនុសាសន៍ ១៨
ការតាមដានការអប់រំក្នុងបរិបទនៃគោលដៅអភិវឌ្ឍន៍ដោយចីរភាព ២៣
ជំងឺកូវីដ ១៩ ..... ២៤
ចំណុចដៅ ៤.១. ការអប់រំបឋមសិក្សា និងមធ្យមសិក្សា ២៧
ចំណុចដៅ ៤.២. ការអប់រំកុមារតូច ២៧
ចំណុចដៅ ៤.៣. ការអប់រំបច្ចេកទេស វិជ្ជាជីវៈ ឧត្តមសិក្សា និងការអប់រំមនុស្សពេញវ័យ ២៨
ចំណុចដៅ ៤.៤. ជំនាញសម្រាប់ការងារ ៣០
ចំណុចដៅ ៤.៥. សមធម៌ ៣០
ចំណុចដៅ ៤.៦. អក្ខរកម្មមនុស្សពេញវ័យ ៣១
ចំណុចដៅ ៤.៧. ការអភិវឌ្ឍដោយចីរភាព និងភាពជាពលរដ្ឋសកល ៣២
ចំណុចដៅ ៤.ក. សម្ភារូបវន្តដែលបម្រើដល់ការអប់រំ និងបរិយាកាសរៀនសូត្រ ៣២
ចំណុចដៅ ៤.ខ. អាហារូបករណ៍ ៣៣
ចំណុចដៅ ៤.គ. គ្រូបង្រៀន ៣៣
ការអប់រំក្នុងគោលដៅអភិវឌ្ឍន៍ដោយចីរភាពផ្សេងទៀត ៣៤
ហិរញ្ញប្បទាន ៣៤



© UNESCO / PHOTO CREDIT: UNICEF

សារគន្លឹះ

ពុំមានផ្នែកណានៃការងារអប់រំ ដែលតួអង្គមិនមែនរដ្ឋពុំបានចូលរួមនោះឡើយ។

និយាយដោយសាមញ្ញ ប្រសិនបើពុំមានតួអង្គមិនមែនរដ្ឋនោះទេ ការអប់រំដល់កុមារជាង ៣៥០ លាននាក់បន្ថែមទៀតត្រូវក្លាយជាស្ថិតក្រោមការទទួលខុសត្រូវរបស់រដ្ឋជាមិនខាន។ ប៉ុន្តែ ការចូលរួមរបស់តួអង្គមិនមែនរដ្ឋក៏ជះឥទ្ធិពលលើសៀវភៅសិក្សាដែលពួកគេប្រើប្រាស់ អាហារដែលផ្តល់នៅតាមអាហារដ្ឋានរបស់ពួកគេ ការគាំទ្របន្ថែមដែលពួកគេទទួលបាន ជំនាញដែលពួកគេរៀនចេះ និងចំណុចផ្សេងទៀតជាច្រើន។

មនុស្សភាគច្រើនគាំទ្រដល់ការអប់រំសាធារណៈ។

ក្នុងចំណោមមនុស្ស ៤ នាក់ នៅក្នុងប្រទេសដែលមានចំណូលមធ្យម និងចំណូលខ្ពស់ចំនួន ៣៤ មាន ៣ នាក់ដែលចង់ឱ្យមានការចំណាយថវិការដ្ឋបន្ថែមទៀតលើការអប់រំ នៅពេលដែលការគាំទ្រកាន់តែមានការកើនឡើងប្រទេសនឹងកាន់តែជួបបញ្ហាវិសមភាព។ ក្នុងចំណោមមនុស្ស ១០ នាក់ជិត ៩ នាក់គិតថាការអប់រំ គួរជាសេវាសាធារណៈ។

ប៉ុន្តែការគាំទ្របែបនេះ បានថយចុះជាបណ្តើរៗនៅតាមប្រទេសចំណូលទាប និងចំណូលមធ្យមជាច្រើន។

ខណៈពេលដែលចំនួនសាលាសាធារណៈមិនមានគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការ ហើយគុណភាពនៃសាលារៀនទាំងនេះទៀតសោតមានការថយចុះ គ្រួសារជាច្រើនពុំបានបង្ហាញពីការគាំទ្រចំពោះសាលាឯកជន ឬសាលាសាធារណៈនោះឡើយ។ ភាគរយនៃគ្រឹះស្ថានឯកជននៅទូទាំងសកលលោក មានការកើនឡើងចំណុច ៧ ភាគរយចំណុចក្នុងរយៈពេលប្រហែលជា ១០ ឆ្នាំ៖ ពោល គឺរហូតដល់ ១៧% ត្រឹមឆ្នាំ ២០១៣ សម្រាប់ការអប់រំបឋមសិក្សា និងដល់ ២៦% ត្រឹមឆ្នាំ ២០១៤ សម្រាប់ការអប់រំមធ្យមសិក្សា។ តួលេខនេះនៅបន្តប្រហាក់ប្រហែលនេះ ចាប់តាំងពីពេលនោះមក។ នៅអាស៊ីភាគកណ្តាល និងភាគខាងត្បូង ភាគរយនៃការចុះឈ្មោះចូលរៀនក្នុងគ្រឹះស្ថានឯកជនមាន ៣៦% សម្រាប់ការអប់រំបឋមសិក្សា និង ៤៨% សម្រាប់ការអប់រំមធ្យមសិក្សា។

ការអប់រំសាធារណៈមិនមែនផ្តល់ដោយមិនគិតថ្លៃនោះឡើយ។

គ្រួសារត្រូវចំណាយ ៣0% នៃចំណាយសរុបសម្រាប់ការអប់រំទូទាំងសកលលោក ហើយតួលេខនេះមាន ៣៩% សម្រាប់ប្រទេសចំណូលទាប និងចំណូលមធ្យមកម្រិតទាប។ ហេតុផលមួយគឺ គ្រួសារដែលមានជីវភាពធូរធារព្យាយាមផ្តល់ឱ្យកូនៗរបស់ពួកគេនូវឧត្តមភាពប្រកួតប្រជែង។ ប៉ុន្តែចំណាយភាគច្រើន គឺជាចំណាយសម្រាប់ការអប់រំកម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា ដែលរដ្ឋាភិបាលបានប្តេជ្ញាចិត្តថានឹងផ្តល់ដោយមិនគិតថ្លៃ។ គ្រួសារប្រមាណ ៨% ត្រូវខ្ចីបុលគេសម្រាប់ចំណាយលើការអប់រំ ដែលតួលេខនេះកើនឡើងដល់ ១២% ក្នុងប្រទេសចំណូលទាប និងចាប់ពី ៣0% ឡើងទៅក្នុងប្រទេសហៃទី កេនយ៉ា ហ្វីលីពីន និងអ៊ូហ្គង់ដា។

ជារឿយៗ ការអប់រំសាធារណៈពុំមានលក្ខណៈបរិយាបន្នឡើយ។

ប្រព័ន្ធអប់រំសាធារណៈជាច្រើនខកខានពុំបានទប់ស្កាត់ការបែងចែកសិស្សទៅតាមចំណាត់ថ្នាក់ និងទៅតាមប្រភេទក្រុម។ សន្ទស្សន៍ភាពចម្រុះក្នុងសង្គមតាមសាលារៀនដែលប្រើប្រាស់ទិន្នន័យពីកម្មវិធីវាយតម្លៃសិស្សអន្តរជាតិជាគោលបានរកឃើញថាប្រទេសអាហ្សង់ទីន ប្រេស៊ីល ឈីលី និងម៉ិកស៊ិកូ បានធ្វើការបែងចែកសិស្សតាមចំណាត់ថ្នាក់ក្នុងកម្រិតខ្ពស់ស្រដៀងគ្នាក្នុងឆ្នាំ ២០១៨ បើទោះជាមានតែប្រទេសឈីលីប៉ុណ្ណោះ ដែលទទួលការរិះគន់ ត្បិតគ្រឹះស្ថានឯកជនមានភាគរយខ្ពស់នៅក្នុងប្រព័ន្ធអប់រំរបស់ខ្លួន។

ពុំមានអ្នកផ្តល់សេវាអប់រំតែមួយប្រភេទណាដែលអាចផ្តល់ការអប់រំក្នុងគុណភាពល្អជាងអ្នកផ្តល់សេវាអប់រំប្រភេទផ្សេងទៀតនោះឡើយ។

ទិន្នន័យដែលបានពីប្រទេសដែលមានចំណូលទាប និងមធ្យមចំនួន ៣0 បានបង្ហាញថា ការចំណាយជាក់ស្តែងក្នុងការចូលរៀននៅសាលាឯកជនធ្លាក់ចុះពីពាក់កណ្តាលរហូតដល់ ២ ភាគ ៣ ដោយសារជីវភាព និងប្រាក់ចំណូលគ្រួសារ។ នៅក្នុងសំណាកដែលមានប្រទេសចំនួន ៤៩ គ្រួសារដែលមានជីវភាពធូរធារជាងគេទំនងជាឱ្យកូនទៅរៀននៅសាលាឯកជនច្រើនជាងគ្រួសារដែលមានជីវភាពក្រីក្រ

រហូតដល់ដិត ១០ ដង។ ហើយឪពុកម្តាយដែលអាចមានលទ្ធភាពជ្រើសរើសសាលារៀនបាន ជ្រើសរើសសាលារៀនទៅតាមដំនឿសាសនា ភាពងាយស្រួល និងលក្ខណៈប្រជាសាស្ត្ររបស់សិស្សចៀសជាងទៅតាមគុណភាព ហើយពួកគេកម្រមានព័ត៌មានឱ្យបានគ្រប់គ្រាន់អំពីគុណភាពណាស់។

សមត្ថភាពនិយ័តកម្ម តាមដាន និងពង្រឹងការអនុវត្ត ច្រើនតែនៅមានកម្រិតទាបនៅទីកន្លែងដែលមានតម្រូវការសេវាទាំងនេះក្នុងកម្រិតខ្ពស់។

ការវិភាគលើប្រព័ន្ធអប់រំចំនួន ២១១ សម្រាប់គេហទំព័រPEERបង្ហាញថាការធ្វើបញ្ញត្តិកម្មច្រើនតែផ្តោតលើការចុះឈ្មោះការអនុម័តឬការផ្តល់អាជ្ញាប័ណ្ណ (៩៨%),ការចេញវិញ្ញាបនបត្រដល់គ្រូ (៩៣%),ហេដ្ឋារចនាសម្ព័ន្ធ (៨0%) និងផលធៀបសិស្ស/គ្រូ (៧៤%)។ការធ្វើបញ្ញត្តិកម្មទំនងជាងផ្តោតការយកចិត្តទុកដាក់តិចតួចជាងគេលើគុណភាពឬសមធម៌៖ ៦៧%ធ្វើបញ្ញត្តិកម្មលើការកំណត់ថ្លៃសេវា,៥៥%ហាមឃាត់មិនឱ្យមានការប្រើប្រាស់នីតិវិធីទទួលយកសិស្សតែប្រភេទណាមួយនៅតាមសាលារៀនមិនមែនរដ្ឋ,២៧%ហាមប្រាមមិនឱ្យមានការរកប្រាក់ចំណេញនិងត្រឹមតែ៧%តែប៉ុណ្ណោះដែលកំណត់កូតាសម្រាប់ជួយគាំទ្រដល់កាទទួលបានការអប់រំសម្រាប់ក្រុមសិស្សដែលជួបការលំបាក។ ពុំមានការធ្វើបញ្ញត្តិកម្មលើការបង្រៀនជាលក្ខណៈឯកជនក្នុងប្រទេសចំនួន ៤៨% ហើយមានការធ្វើបញ្ញត្តិកម្មតែនៅក្នុងច្បាប់ពាណិជ្ជកម្មក្នុងប្រទេស ១១% ប៉ុណ្ណោះ។

តួអង្គមិនមែនរដ្ឋមានវត្តមានច្រើនក្នុងវិស័យអប់រំកុមារតូច អប់រំបច្ចេកទេស អប់រំឧត្តមសិក្សា និងអប់រំមនុស្សពេញវ័យ។

ពេលខ្លះ វត្តមានរបស់ពួកគេ បង្កផលប៉ះពាល់ដល់សមធម៌ និងគុណភាព។ ចំណាយសម្រាប់ការអប់រំកុមារតូច និងឧត្តមសិក្សាដែលផ្តល់ដោយតួអង្គមិនមែនរដ្ឋ ដែលជាទូទៅមានការយកថ្លៃសេវាខ្ពស់ មានន័យថាក្រុមប្រជាពលរដ្ឋដែលមានអំណាច និងមានទ្រព្យសម្បត្តិស្តុកស្តម្ភក្នុងទីក្រុងច្រើនតែមានកូនរៀនទៅតាមគ្រឹះស្ថានទាំងនេះ។ នៅសហរដ្ឋអាមេរិកសាកលវិទ្យាល័យ ដែលខិតខំបង្កើនប្រាក់ចំណេញរបស់ខ្លួនដល់កម្រិតអតិបរមា មានទំនាក់ទំនងជាមួយនឹងការថយចុះលទ្ធផលសិក្សារបស់សិស្ស។ គ្រឹះស្ថានដែលផ្តល់ការបណ្តុះបណ្តាលជាលក្ខណៈឯកជន តាមរយៈការប្រកួតប្រជែងទីផ្សារ ឬកម្មវិធីអភិវឌ្ឍន៍ជំនាញ ដូចជាកម្មវិធីកម្ចី TVET FEE-HELP របស់ប្រទេសអូស្ត្រាលី និងសាជីវកម្មអភិវឌ្ឍន៍ជំនាញជាតិរបស់ប្រទេសឥណ្ឌា ត្រូវបានបង្ខំឱ្យពិចារណាជាថ្មីពីដំណើរការ គណនេយ្យភាព និងតាមដាន ដើម្បីបង្កើនគុណភាពនៃការផ្តល់សេវាជាលក្ខណៈឯកជន និងបង្កើនសមត្ថភាពអាចស្វែងរកការងារបានធ្វើរបស់សិស្ស។

រដ្ឋាភិបាលចាំបាច់ត្រូវចាត់ទុកគ្រឹះស្ថានអប់រំ សិស្ស និងគ្រូបង្រៀនទាំងអស់ថាជាផ្នែកនៃប្រព័ន្ធតែមួយ។

ស្តង់ដារ ព័ត៌មាន ការលើកទឹកចិត្ត និងគណនេយ្យភាព គួរជួយរដ្ឋាភិបាលក្នុងការការពារ គោរព និងបំពេញសិទ្ធិទទួលបានការអប់រំរបស់មនុស្សទាំងអស់គ្នា និងគួររារាំងមិនឱ្យរដ្ឋាភិបាលងាកមុខចេញពីក្រុមមនុស្សដែលមានបុព្វសិទ្ធិ ឬក្រុមមនុស្សដែលរងការកេងប្រវ័ញ្ចនោះឡើយ។ ការអប់រំដែលទទួលបានថវិកាគាំទ្រពីរដ្ឋ មិនចាំបាច់ត្រូវតែផ្តល់ដោយរដ្ឋនោះឡើយ ប៉ុន្តែគម្លាតនៅក្នុងដំណើរការអប់រំ លទ្ធផលសិក្សារបស់សិស្ស និងលក្ខខណ្ឌការងាររបស់គ្រូ គួរតែជាអ្វីដែលត្រូវទទួលបានការយកចិត្តទុកដាក់។ ប្រសិទ្ធភាព និងនវានុវត្តន៍មិនគួរជាអាថ៌កំបាំងនៃការធ្វើពាណិជ្ជកម្មឡើយ ផ្ទុយទៅវិញគេគួរផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយពីកត្តាដែលជួយបង្កើនប្រសិទ្ធភាព និងនវានុវត្តន៍ គួរជាអ្វីដែលទាំងអស់គ្នាគួរអនុវត្ត។ ដើម្បីសម្រេចគោលដៅនេះ គេចាំបាច់ត្រូវបន្តរក្សាតម្លាភាព និងសុចរិតភាពក្នុងដំណើរការធ្វើគោលនយោបាយអប់រំសាធារណៈ។

ការងារអប់រំមិនមែនសុទ្ធតែស្ថិតក្រោមការដឹកនាំរបស់រដ្ឋាភិបាលនោះឡើយ។ កន្លងមកការអប់រំត្រូវបានរៀបចំឡើងក្នុងពេលដំណាលគ្នានិងក្រៅផ្លូវការ តាមគ្រឹះស្ថានសាសនា គ្រួសារ និងសមាគមនានា។ ចាប់ពីចុងសតវត្សទី ១៨ មក រដ្ឋបានមើលឃើញឱកាសសម្រាប់ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួន តាមរយៈកម្លាំងពលកម្មដែលទទួលបានការអប់រំ ក៏ដូចជាឱកាសអភិវឌ្ឍន៍ និងពង្រឹងស្មារតីអត្តសញ្ញាណជាតិ តាមរយៈសាលារៀនសាធារណៈ។ រដ្ឋាភិបាលបានត្រៀមខ្លួនរ៉ាប់រងចំណាយដ៏ខ្ពស់ក្នុងការផ្តល់សេវាសាធារណៈមួយនេះ ព្រោះតែអត្ថប្រយោជន៍ដ៏ធំធេងរបស់វាចំពោះសង្គម និងសេដ្ឋកិច្ច។ សម្រាប់ប្រទេសដែលទើបទទួលបានឯករាជ្យភាពថ្មីៗនៅក្នុងសតវត្សទី ២០ ការកសាងប្រព័ន្ធអប់រំសាធារណៈគឺជាសមិទ្ធផលនៃការទទួលបានសេរីភាពពីនឹមអាណានិគម។ ការអប់រំសាធារណៈសុទ្ធតែមានគោលបំណងបណ្តុះឧត្តមគតិដែលបង្ហាញពីភាពថ្លៃថ្នូរ ឬមនោគមន៍វិជ្ជាដឹកនាំប្រទេស។ រចនាសម្ព័ន្ធថ្មីៗទាំងនេះបានស្រូបយករចនាសម្ព័ន្ធអប់រំបែបប្រពៃណី និងមានឧត្តមភាពជាង និងចូលមកជំនួសរចនាសម្ព័ន្ធអប់រំបែបប្រពៃណី។

ទោះជាយ៉ាងណាក៏ដោយ ការអប់រំក៏ជាទំនិញឯកជនផងដែរ។ ការប្រើប្រាស់សេវាអប់រំកាន់តែច្រើនធ្វើឱ្យបុគ្គលម្នាក់ៗមានឱកាសកាន់តែប្រសើរ និងអាចធ្វើឱ្យអ្នកដទៃទៀតត្រូវបានផាត់ចេញពីឱកាសទាំងនេះ។ អ្នកដែលមានលទ្ធភាពឡើងតាមដណ្តើរនៃការអប់រំកាន់តែអាចទទួលបានជីវភាពរស់នៅកាន់តែប្រសើរ និងប្រាក់ចំណូលកាន់តែខ្ពស់។ ដោយហេតុថាប្រព័ន្ធអប់រំមិនអាចនាំមនុស្សគ្រប់គ្នាទៅខាងលើបានទាំងអស់គ្នា គ្រួសារត្រូវធ្វើអ្វីៗគ្រប់បែបយ៉ាងដែលពួកគេអាចធ្វើបាន ដើម្បីធានាថាកូនៗរបស់ពួកគេ គឺជាអ្នកដែលអាចឡើងទៅកម្រិតខ្ពស់បំផុត។ ការប្រកួតប្រជែងបែបនេះបង្កើតឱ្យមាននូវតម្រូវការ ដែលជាកត្តានាំឱ្យមានការផ្តត់ផ្តង់ទំនិញ និងសេវាអប់រំ។ អាស្រ័យទៅតាមបរិបទជាតិ និងឧបនិស្ស័យតាមប្រទេសនីមួយៗ ទីផ្សារថ្មីៗអាចលេចចេញជារូបរាង សម្រាប់ផ្តល់សេវាអប់រំដោយផ្ទាល់ ដែលនាំមកនូវអត្ថប្រយោជន៍ជាច្រើន។

មានការគាំទ្រខ្លាំងក្លាដល់ការអប់រំសាធារណៈ

ជម្រើសនៃការអប់រំ គឺជាកត្តាកំណត់ពីជីវិតរបស់កុមារ។ ឪពុកម្តាយមិនត្រឹមតែធ្វើការគណនាបែបសាមញ្ញលើចំណាយ និងអត្ថប្រយោជន៍ផ្នែកហិរញ្ញវត្ថុប៉ុណ្ណោះទេ ប៉ុន្តែពួកគេក៏ធ្វើការពិចារណាពីកត្តាជាច្រើនដែលមានភាពពាក់ព័ន្ធជាមួយគ្នាទៅវិញទៅមកផងដែរ។ ជម្រើសពាក់ព័ន្ធនឹងអ្វីដែលត្រូវបានបង្រៀន បង្រៀនដោយរបៀបណា ដោយនរណា និងនៅកន្លែងណា សុទ្ធតែឆ្លុះបញ្ចាំងពីការមើលឃើញពិភពលោកពីជ្រុងផ្សេងៗគ្នា និងបំណងប្រាថ្នារបស់ឪពុកម្តាយ និងអ្នកពាក់ព័ន្ធដទៃទៀតក្នុងវិស័យអប់រំ។ កត្តាទាំងនេះ មានភាពពាក់ព័ន្ធនឹងទិដ្ឋភាពធំៗចំនួន ២៖ ការគ្រប់គ្រង និងការបែងចែកធនធាន ក៏ដូចជាគុណតម្លៃ និងជំនឿសម្រាប់សង្គមដែលកំពុងមានការផ្លាស់ប្តូរ។ ជម្រើសនៃការអប់រំក៏មានលក្ខណៈនយោបាយកម្រិតខ្ពស់ផងដែរ និងត្រូវបានឆ្លុះបញ្ចាំងយ៉ាងជាក់ច្បាស់ ឬដោយប្រយោលក្នុងរបៀបវារៈនយោបាយនានា។ បន្ថែមលើកត្តាមនោគមន៍វិជ្ជា និងកត្តាកាលៈទេសៈរបស់បុគ្គល ការយល់ពីបញ្ហាប្រឈមក្នុងសង្គម និងពីទំនាក់ទំនងដែលរដ្ឋាភិបាល ប្រជាពលរដ្ឋ និងស្ថាប័ននានា គួរមានជាមួយគ្នាទៅវិញទៅមក មានការប្រែប្រួលខុសៗគ្នាពីប្រទេសមួយទៅប្រទេសមួយ។ ការយល់ទាំងនេះមានឥទ្ធិពលលើឥរិយាបថពាក់ព័ន្ធប្រភេទគោលនយោបាយដែលរដ្ឋាភិបាលគួរអនុវត្ត និងអ្នកដែលគួរទទួលបានប្រយោជន៍ពីគោលនយោបាយទាំងនេះ។

មានការស្រាវជ្រាវអំពីការគាំទ្រដល់ការអប់រំសាធារណៈច្រើនលើសលប់ក្នុងប្រទេសដែលមានចំណូលខ្ពស់។ ការអង្កេតមួយដែលទើបតែធ្វើឡើងកាលពីពេលថ្មីៗនេះ លើឥរិយាបថក្នុងប្រទេសដាណឺម៉ាក បារាំង អាឡឺម៉ង់ អៀឡង់ អ៊ីតាលី អេស្ប៉ាញ ស៊ុយអែត និងចក្រភពអង់គ្លេស បានបង្ហាញថា នៅពេលដែលអ្នកឆ្លើយតបត្រូវបានស្នើឱ្យចាត់អាទិភាពលើវិស័យមួយក្នុងចំណោមវិស័យដែលមានសក្តានុពលចំនួន ៨ សម្រាប់ចំណាយថវិកាបន្ថែម ការអប់រំត្រូវបានចាត់ទុកជាជម្រើសលើគេ គឺ ២៨%, ដោយឡែកសេវាថែទាំសុខភាពនៅកម្រិតទី ២ គឺ ២២%។ ខណៈពេលដែលអ្នកឆ្លើយតប ៧៧% គាំទ្រដល់ជម្រើសសាលារៀន, ជាង ៦០% ជំទាស់នឹងតួនាទីដ៏សំខាន់របស់សាលាឯកជនក្នុងប្រព័ន្ធអប់រំជាតិ។

ការវិភាគលើទិន្នន័យនៃម៉ូឌុលពិសេសនៃកម្មវិធីអង្កេតសង្គមអន្តរជាតិ (ISSP) ឆ្នាំ ២០១៦ ស្តីពីតួនាទីរបស់រដ្ឋាភិបាលដែលធ្វើឡើងសម្រាប់ប្រមូលព័ត៌មាន ដើម្បីរៀបចំរបាយការណ៍នេះ បានផ្តោតការយកចិត្តទុកដាក់លើការគាំទ្រដល់ការអប់រំសាធារណៈដោយប្រើប្រាស់ប្រទេសចំនួន ៣៥ ជាសំណាក ដែលក្នុងនោះមានប្រទេសចំណូលមធ្យមចំនួន ១០។ ជារួម អ្នកឆ្លើយតបជាមនុស្សពេញវ័យ ៨៩% បាននិយាយថា រដ្ឋាភិបាល គឺជាអ្នកដែលទទួលខុសត្រូវចម្បងលើលើការផ្តល់សេវាអប់រំតាមសាលារៀន ខណៈពេលដែល ៦% លើកឡើងថា ការអប់រំ គឺជាការទទួលខុសត្រូវរបស់គ្រួសារ និង ៥% លើកឡើងថា ការអប់រំ គឺជាការទទួលខុសត្រូវរបស់ស្ថាប័នដទៃទៀត (ក្រុមហ៊ុនឯកជន និងស្ថាប័នមិនរកប្រាក់ចំណេញ, អង្គការមិនរកប្រាក់ចំណេញ, មូលនិធិសប្បុរសធម៌ និងសាជីវកម្ម និងគ្រឹះស្ថានសាសនាជាដើម)។ ប៉ុន្តែជាការឆ្លុះបញ្ចាំងលើការមានបទពិសោធន៍យ៉ាងច្រើនជាមួយនឹងការផ្តល់សេវាអប់រំពីតួអង្គមិនមែនរដ្ឋ អ្នកឆ្លើយតបនៅក្នុងប្រទេសឥណ្ឌា (៤៦%) ហ្វីលីពីន (៦៣%) និងឈីលី (៧៦%) បានបង្ហាញពីការគាំទ្រក្នុងកម្រិតទាបជាងគេដល់ការផ្តល់សេវាអប់រំសាធារណៈ (**រូបភាពទី ១**)។

ទង្វើការណ៍ផ្សេងៗគ្នាជំរុញឱ្យមានការជជែកវែកញែក ដែលគាំទ្រ ឬប្រឆាំងនឹងការផ្តល់សេវាអប់រំដោយតួអង្គមិនមែនរដ្ឋ


អ្នកគាំទ្រ និងអ្នកជំទាស់លើតួនាទីរបស់តួអង្គមិនមែនរដ្ឋក្នុងការផ្តល់សេវាអប់រំ បានលើកឡើងពីអំណះអំណាងពាក់ព័ន្ធនឹងសុវត្ថិភាព ក៏ដូចជាភាពស្របច្បាប់នៃតួអង្គរដ្ឋ និងតួអង្គមិនមែនរដ្ឋក្នុងការបង្កើនប្រសិទ្ធភាព សមធម៌ និងបរិយាបន្ន ព្រមទាំងនវានុវត្តន៍ក្នុងការអប់រំ។ បញ្ហាទាំងនេះ ត្រូវបានគេមើលឃើញចេញពីជ្រុង ថាតើមនុស្សជឿថាការអប់រំគឺជាទំនិញ ឬសេវាដែលត្រូវទិញតាមផ្សារ ឬថាតើមនុស្សទូទៅ គួរតែមានលទ្ធភាពជ្រើសរើសការអប់រំដែលពួកគេចង់បាន។

តើតួអង្គមិនមែនរដ្ឋ អាចផ្តល់សេវាអប់រំដែលអស់ចំណាយតិចជាងដែរឬទេ? អ្នកគាំទ្រដល់ការផ្តល់សេវាអប់រំដោយតួអង្គមិនមែនរដ្ឋ អះអាងថា វាជារឿងដែលចៀសមិនរួចឡើយ ព្រោះថារដ្ឋមិនអាចឆ្លើយតបចំពោះតម្រូវការសេវាអប់រំឱ្យបានពេញលេញឡើយ។ មិនថាតួអង្គមិនមែនរដ្ឋធ្វើសកម្មភាពរបស់ខ្លួនដោយសារតែទឹកចិត្តសប្បុរសធម៌ ជំនឿ និងគំនិត ឬដើម្បីប្រាក់ចំណេញនោះឡើយ ប្រសិនបើការផ្តត់ផ្តង់ទំនិញ និងសេវាអប់រំ បានឆ្លើយតបចំពោះតម្រូវការ នោះប្រាកដជាអាចមានទីផ្សារ ដែលមិនមែនជាទីផ្សារដែលកំពុងមាន ក៏អាចជាទីផ្សារដែលគេគ្រោងនឹងបង្កើតឱ្យមានផងដែរ។ តាមរយៈទីផ្សារគេអាចសម្រេចគោលដៅប្រសិទ្ធភាពចំណាយជាមិនខាន។

រូបភាពទី ១:

នៅក្នុងប្រទេសភាគច្រើនដែលត្រូវបានសិក្សា ជាង ៨0% គាំទ្រដល់ការផ្តល់សេវាអប់រំជាសាធារណៈ

ភាគរយនៃមនុស្សពេញវ័យដែលបាននិយាយថា ការទទួលខុសត្រូវជាចម្បងក្នុងការផ្តល់សេវាអប់រំតាមសាលារៀន គឺជាការទទួលខុសត្រូវរបស់រដ្ឋាភិបាល ឆ្នាំ ២០១៦



ប្រភព៖ Edlund and Lindh (2021) ផ្អែកតាមការអង្កេត ISSP ឆ្នាំ ២០១៦។

អ្នកដែលជំទាស់នឹងសកម្មភាពរបស់តួអង្គមិនមែនរដ្ឋក្នុងការងារអប់រំ អះអាងថា ប្រសិនបើមានការអនុវត្តដែលមានប្រសិទ្ធភាពចំណាយប្រាកដមែន ការអនុវត្តទាំងនេះ គួរបញ្ចូលទៅក្នុងប្រព័ន្ធអប់រំ និងត្រូវអនុវត្តដោយគ្រប់សាលារៀនទាំងអស់ ទាំងសាលារៀនរដ្ឋ ទាំងសាលារៀនមិនមែនរដ្ឋ។ ប្រសិនបើមានការលើកឡើងថា គ្រូបង្រៀននៅក្នុងប្រទេសមួយទទួលបានបៀវត្សច្រើនពេក នោះបញ្ហានេះ គួរតែជាអ្វីដែលគោលនយោបាយសាធារណៈត្រូវដោះស្រាយ តែវាមិនមែនជាហេតុផល ដើម្បីធ្វើការផ្លាស់ប្តូរគំរូនៃការផ្តល់សេវានោះឡើយ។ តួអង្គមិនមែនរដ្ឋអាចបង្កើនប្រសិទ្ធភាពចំណាយតាមរយៈការជួលគ្រូយែកក្មេង ឬគ្រូដែលពុំមានគុណវុឌ្ឍិដែលនេះមិនមែនជាដំណោះស្រាយដែលមានចីរភាពនោះឡើយ។ ការប្រៀបធៀបដែលអាចជឿទុកចិត្តបាននៃចំណាយរវាងសាលារៀនរបស់រដ្ឋ និងសាលារៀនដែលមិនមែនជារបស់រដ្ឋ គឺជារឿងពិបាក។ សាលារៀនសាធារណៈច្រើនតែផ្តល់សេវាដល់ក្រុមដែលជួបការលំបាកច្រើនជាងពោលគឺត្រូវអស់ចំណាយច្រើនជាងសម្រាប់ផ្តល់ការអប់រំដល់ពួកគេ។

តើតួអង្គមិនមែនរដ្ឋសម្រេចបាននូវសមធម៌ និងបរិយាបន្នក្នុងការអប់រំដែរឬទេ? អ្នកដែលគាំទ្រដល់សេវាផ្តល់ការអប់រំ ដោយតួអង្គមិនមែនរដ្ឋអះអាងថាអ្នកផ្តល់សេវារដ្ឋជួយបំពេញសិទ្ធិទទួលបានការអប់រំ។ ក្នុងបរិបទជាច្រើន តួអង្គមិនមែនរដ្ឋបានបំពេញគម្លាតក្នុងការផ្តល់សេវាអប់រំជារឿយៗសម្រាប់ក្រុមជួបការលំបាក ដែលពុំបានទទួលការយកចិត្តទុកដាក់ពីប្រព័ន្ធសាធារណៈ។

ជារឿយៗ រដ្ឋាភិបាលមានការស្ទាក់ស្ទើរមិនចង់បង្កើនសាលារៀននៅតាមតំបន់តាំងទីលំនៅមិនរៀបរយ ដូចក្នុងប្រទេសប៉ាគីស្ថានជាដើម។ តួអង្គមិនមែនរដ្ឋក៏រួមចំណែកយ៉ាងមានតម្លៃក្នុងពេលមានវិបត្តិ និងស្ថានភាពអាសន្ន ដូចជាក្រោយពេលមានគ្រោះរញ្ជួយដីដែលបង្កមហន្តរាយធ្ងន់ធ្ងរកាលពីឆ្នាំ ២០១៥ នៅក្នុងប្រទេសនេប៉ាល់ជាដើម។ នៅក្នុងប្រទេសអេលសាវ៉ាឌ័រ នៅតាមតំបន់ប្រជុំជន ដែលរងផលប៉ះពាល់ដោយសារអំពើហិង្សា និងក្រុមទំនើង ភាគរយនៃការចុះឈ្មោះចូលរៀន

ក្នុងសាលាមិនមែនរដ្ឋខ្ពស់ជាងអត្រាមធ្យមក្នុងប្រទេសដល់ទៅពីរដង។

អ្នកដែលជំទាស់នឹងសាលារៀនមិនមែនរដ្ឋ លើកឡើងពីបញ្ហាដែលបង្កឡើងដោយសារជម្រើសសាលារៀន។ ប្រសិនបើមាតាបិតាអាចជ្រើសរើសសាលារៀនដែលពួកគេចង់បាន ដោយពុំមានលិខិតបទដ្ឋានគតិយុត្តសម្រាប់ផ្តល់ការណែនាំឱ្យបានត្រឹមត្រូវនោះទេ នោះគ្រួសារដែលមានជីវភាពធូធារបំផុត មានលទ្ធភាពជាងគេ ក្នុងការឱ្យកូនទៅរៀននៅសាលាដែលល្អបំផុត ដែលជារឿយៗជាសាលាដែលមិនមែនជារបស់រដ្ឋ ដែលជាកត្តាធ្វើឱ្យវិសមភាព ការបែងចែកវណ្ណៈ និងការបែងចែកមនុស្សទៅតាមក្រុមកាន់តែមានវិសាលភាពធំទៅៗ។ ការសម្រេចចិត្តរបស់មាតាបិតាត្រូវការព័ត៌មានត្រឹមត្រូវ ប៉ុន្តែព័ត៌មានអំពីលក្ខណៈរបស់សាលារៀននៅមិនទាន់មានឱ្យបានគ្រប់គ្រាន់ ឬប្រសិនបើមាន ក៏ពុំត្រូវបានផ្តល់ឱ្យបានស្មើភាពនោះឡើយ ដោយក្រុមប្រជាជនដែលជួបការលំបាកទទួលបានព័ត៌មានតិចជាង។ លើសពីនេះ មានប្រជាជនដែលពិបាកទៅដល់ជាច្រើននាក់ ដែលអ្នកផ្តល់សេវាអាចមានការស្ទាក់ស្ទើរមិនចង់ផ្តល់សេវាឱ្យ។

មនុស្សមួយចំនួនដែលគិតថារដ្ឋាភិបាលមិនគួរបំពេញតួនាទីចម្បងក្នុងការផ្តល់សេវាអប់រំ ជំទាស់ទៅនឹងអំណាចរបស់រដ្ឋាភិបាលក្នុងការធ្វើសេចក្តីសម្រេចចិត្តអំពីខ្លឹមសារអប់រំ ឬសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការផ្តល់សេវាអប់រំឱ្យដល់កម្រិតស្តង់ដារដែលចង់បាន។ ឧទាហរណ៍អាចលើកហេតុផលគាំទ្រដល់ការផ្តល់សេវាដោយឡែកពីតួអង្គមិនមែនរដ្ឋ ដូចជាក្តីបារម្ភថាសាលារៀនសាធារណៈនៅក្នុងមូលដ្ឋាន បង្កការគំរាមកំហែងដល់គុណតម្លៃនៃសហគមន៍វប្បធម៌ ជាតិពន្ធុ ភាសា ឬសាសនា ដែលពួកគេមានបំណងចង់ឱ្យកូនរបស់ពួកគេទទួលបានគុណតម្លៃទាំងនេះ។ ប៉ុន្តែរដ្ឋាភិបាលអាចលើកឡើងថា ការផ្តល់សេវាបែបនេះ អាចមានភាពប្រទាំងប្រទើសជាមួយនឹងការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល ដើម្បីធានាឱ្យមានការអប់រំប្រកបដោយសមធម៌ និងបរិយាបន្ន និងជ្រៀតជ្រែកសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការអនុវត្តស្តង់ដារតែមួយ ក្នុងកិច្ចខិតខំប្រឹងប្រែងផ្តល់ការអប់រំប្រកបដោយគុណភាពដូចគ្នាចំពោះកុមារគ្រប់រូបដោយមិនមានករណីលើកលែង។

តើតួអង្គមិនមែនរដ្ឋនាំមកនូវនវានុវត្តន៍កាន់តែច្រើន សម្រាប់វិស័យអប់រំដែរឬទេ? អ្នកដែលគាំទ្រឱ្យមានការចូលរួមពីតួអង្គមិនមែនរដ្ឋក្នុងការងារអប់រំ អះអាងថាការចូលរួមរបស់ពួកគេជួយបង្កើននវានុវត្តន៍។ គំនិតជាច្រើនដែលនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមានចំពោះការយល់ដឹងអំពីគរុកោសល្យ លេចឡើងនៅតាមរឹមនៃប្រព័ន្ធអប់រំសាធារណៈ ឬនៅខាងក្រៅប្រព័ន្ធអប់រំសាធារណៈតែម្តង។ ប្រព័ន្ធអប់រំសាធារណៈបានរីកមាឧក្លាយជាការិយាធិបតេយ្យបែបមជ្ឈការដ៏ធំដែលលែងអាចមើលឃើញក្រុមគោលដៅ ដែលពួកគេត្រូវផ្តល់សេវាឱ្យ។ ការរិះគន់ដែលតែងតែកើតមាន គឺថាប្រព័ន្ធអប់រំសាធារណៈមិនខ្វល់នឹងគំនិតផ្តួចផ្តើមបង្ខំឱ្យគេអនុវត្តតាមស្តង់ដារតែមួយ និងបំបាក់ទឹកចិត្តសិស្ស និងគ្រូ។

ការផ្តល់នូវនវានុវត្តន៍ គឺជាកិច្ចការដ៏ស្មុគស្មាញសម្រាប់ប្រព័ន្ធអប់រំសាធារណៈ។ គេចាំបាច់ត្រូវធ្វើតេស្តសាកល្បងការផ្លាស់ប្តូរនានា ដើម្បីដឹងពីលទ្ធភាពពង្រីកវិសាលភាពនៃការអនុវត្តការផ្លាស់ប្តូរទាំងនេះ។ បញ្ហាប្រឈមអាចមានដូចជា ឧបសគ្គការិយាធិបតេយ្យ កង្វះសមត្ថភាពស្ថាប័នគ្រូបង្រៀន និងមាតាបិតាខ្វះការលើកទឹកចិត្ត មធ្យោបាយហិរញ្ញវត្ថុនៅមានកម្រិត ការជ្រៀតជ្រែក និងការជំទាស់នៅកម្រិតនយោបាយជាដើម។ ទោះជាយ៉ាងណាក៏ដោយ ប្រព័ន្ធអប់រំសាធារណៈមិនមែនមានឧបនិស្ស័យអវិជ្ជមានចំពោះនវានុវត្តន៍នោះឡើយ។ ហើយតួអង្គមិនមែនរដ្ឋមួយចំនួនកំពុងធ្វើតេស្ត ថាតើ នវានុវត្តន៍មួយចំនួនអាចមានប្រសិទ្ធភាពក្នុងការអប់រំសាធារណៈដែរឬទេ។


ជារឿយៗការជជែកវែកញែកអំពីនវានុវត្តន៍ពុំមានភាពច្បាស់លាស់ដោយសារតែមានការលើកឡើងពីទស្សនទានសំខាន់ៗបែបប្រទាំងប្រទើសគ្នា។ គំនិតបង្កើតជាស្តង់ដារត្រូវបានរិះគន់ដោយអ្នកដែលជំទាស់ជាមួយនឹងហេតុផលថា ពួកគេមើលឃើញពីភាពរឹងតឹង ការគោរពតាម និងការខ្វះការយល់ពីស្ថានភាពខុសៗគ្នានៃប្រព័ន្ធអប់រំសាធារណៈ ប៉ុន្តែអ្នកដែលគាំទ្រដល់គំនិតនេះ លើកឡើងថាចាំបាច់ត្រូវមានកម្មវិធីសិក្សា គោលតែមួយ ដើម្បីធានាឱ្យមានការបំពេញតាមស្តង់ដារក្នុងគ្រប់សាលារៀនទាំងអស់ហើយអ្នកដែលលើកឡើងថាការធ្វើបែបនេះគឺជាការដាក់សម្ពាធមកលើការប្រកួត ប្រជែង ជារឿយៗរងឥទ្ធិពលពីអ្នកផ្តល់សេវាឯកជនដែលចង់ពន្លឿនឱ្យមានការគោរពតាមស្តង់ដារទាំងនេះ។ ចុងក្រោយ ថាតើការរៀបចំជាស្តង់ដារមិនបានលើកទឹកចិត្តឱ្យមាននវានុវត្តន៍ដែរឬអត់នោះ គឺអាស្រ័យលើថាតើមានការកំណត់ស្តង់ដារអ្វីខ្លះ។ វាក្យស័ព្ទមួយចំនួនដូចជា 'គណនេយ្យភាព', 'ស្វ័យភាព' និង 'ជម្រើស' ត្រូវបានគេគាំទ្រផង និងរិះគន់ផង ថាជាគោលការណ៍សម្រាប់រៀបចំការអប់រំ។ ខណៈពេលដែលគេអាចពិនិត្យលើគំនិតទាំងនេះ ផ្អែកតាមគុណសម្បត្តិរបស់វា គំនិតទាំងនេះមិនចាំបាច់ ជាហេតុផលដែលជំរុញឱ្យតួអង្គមិនមែនរដ្ឋកាន់តែមានតួនាទីធំ ជាពិសេសក្នុងការផ្តល់សេវាអប់រំដល់លក្ខណៈឯកជននោះឡើយ។

ការយល់មិនត្រឹមត្រូវអំពីតួអង្គរដ្ឋ និងតួអង្គមិនមែនរដ្ឋក្នុងការងារអប់រំនៅតែបន្តមាន

ការយល់មិនត្រឹមត្រូវដែលបន្តកើតមានចំនួន ១០ អំពីតួអង្គរដ្ឋ និងតួអង្គមិនមែនរដ្ឋក្នុងការអប់រំ ត្រូវបានចោទសួរក្នុងរបាយការណ៍នេះ។

ការយល់ឃើញមិនត្រឹមត្រូវទី ១.


គេអាចញែកដាច់រវាងតួអង្គរដ្ឋ និងតួអង្គមិនមែនរដ្ឋ។



ការពិភាក្សាពីតួអង្គមិនមែនរដ្ឋក្នុងការងារអប់រំជាធម្មតាតែងតែមានការបែងចែកជាពីរដោច់ពីគ្នា៖ សាលារៀនសាធារណៈ និងសាលារៀនឯកជន។ ក្នុងការអនុវត្តជាក់ស្តែង ស្ថានភាពមានលក្ខណៈស្មុគស្មាញជាងនេះ ហើយគេមិនអាចធ្វើការបែងចែកឱ្យបានជាក់ច្បាស់បែបនេះនោះឡើយ។ តួអង្គមិនមែនរដ្ឋមានលក្ខណៈចម្រុះខុសៗគ្នាក្នុងកម្រិតមួយខ្ពស់។ ពួកគេចូលមកក្នុងវិស័យអប់រំដោយសារហេតុផលផ្សេងៗគ្នា ដូចជាគំនិត គុណតម្លៃ ជំនឿ និងផលប្រយោជន៍ជាដើម។ ពួកគេជាច្រើនចូលរួមក្នុងការរៀបចំរចនាសម្ព័ន្ធក្នុងប្រព័ន្ធ ឬក្រៅប្រព័ន្ធជាមួយនឹងរដ្ឋាភិបាល ដូចជាការជួលឱ្យផ្តល់សេវា និងភាពជាដៃគូរវាងរដ្ឋ និងឯកជន ដែលធ្វើឱ្យបន្ទាត់ខ័ណ្ឌចែកប្រភេទតួអង្គមិនមែនរដ្ឋពុំមានភាពច្បាស់លាស់។

ការយល់ឃើញមិនត្រឹមត្រូវទី ២.


គេដឹងពីវិសាលភាពនៃឯកជនភាវូបនីយកម្ម។



ការពណ៌នាពីនិន្នាការនៃតួនាទីរបស់តួអង្គមិនមែនរដ្ឋ ជារឿយៗពឹងអាស្រ័យលើភាគរយនៃគ្រឹះស្ថានឯកជនក្នុងចំនួនសិស្សដែលចុះឈ្មោះចូលរៀនសរុប។ តើប្រទេសនានាបានគិតបញ្ចូលគ្រូបង្រៀនតាមសាលាសាធារណៈដែលរកចំណូលបន្ថែមតាមរយៈការបង្រៀនសិស្សក្រៅម៉ោងដែរឬទេ? តើប្រព័ន្ធអប់រំដែលជួលអ្នកផ្តល់សេវាខាងក្រៅឱ្យផលិតសៀវភៅសិក្សា ធ្វើការវាយតម្លៃ ឬគ្រប់គ្រងទិន្នន័យ ឬផ្តល់សេវាអាហារដ្ឋាន និងដឹកជញ្ជូន ជាប្រព័ន្ធអប់រំដែលមានលក្ខណៈសាធារណៈកម្រិតណា? តើគោលនយោបាយរបស់រដ្ឋាភិបាល ដែលត្រូវបានសរសេរដោយអ្នកដែលបំពេញតួនាទីជាអ្នកបញ្ចុះបញ្ចូលដើម្បីសម្រេចគោលបំណងអ្វីមួយ (lobbyist) នៅតែត្រូវចាត់ទុកថាជាគោលនយោបាយសាធារណៈដែរឬទេ?

ការយល់ឃើញមិនត្រឹមត្រូវទី ៣.


គេគួរបន្ទោសវិស័យឯកជនដែលនាំឱ្យមានការធ្វើឯកជនភាវូបនីយកម្មការងារអប់រំ។



អ្នកផ្តល់សេវាឯកជនជាច្រើនលើសលុប គឺជាសាលារៀនបែបឯកកម្មសិទ្ធិ។ សាលារៀនទាំងនេះលេចចេញជារូបរាង ជាការឆ្លើយតបចំពោះក្តីបារម្ភពិតប្រាកដរបស់មាតាបិតាជុំវិញគុណភាពរបស់សាលារៀនសាធារណៈដែលមានការថយចុះ ដោយសារតែពុំមានការយកចិត្តទុកដាក់។ នៅពេលដែលការថមថយគុណភាព ជាអ្វីដែលគេឃើញច្បាស់គ្រួសារដែលមានជីវភាពធូរធារ និងគ្រួសារដែលមានជីវភាពខ្សត់ខ្សោយមួយចំនួនតូច បានចាកចេញពីប្រព័ន្ធសាធារណៈ ដែលធ្វើឱ្យប្រព័ន្ធនេះពុំបានទទួលការគាំទ្រពីគ្រួសារទាំងនេះ និងធ្វើឱ្យប្រព័ន្ធអប់រំសាធារណៈពុំមានថវិកាគ្រប់គ្រាន់។ ក្រុមឥស្សរជនដែលជាអ្នកដឹកនាំនយោបាយកាន់តែអត់ធ្មត់ចំពោះបញ្ហាវិសមភាព និងមានការប្តេជ្ញាចិត្តតិចជាងមុនក្នុងការពារការអប់រំសាធារណៈ ដែលផ្តល់ជាប្រយោជន៍ដល់ក្រុមប្រជាពលរដ្ឋដែលជួបការលំបាក។

ការយល់ឃើញមិនត្រឹមត្រូវទី ៤.


ការអប់រំសាធារណៈមានសមធម៌។



ជារឿយៗ គ្រួសារត្រូវចំណាយខ្ពស់លើការអប់រំ តាមរយៈថ្លៃសេវាលាក់កំបាំង ការចំណាយពីហោប៉ៅផ្ទាល់ខ្លួនដែលអាចបញ្ចៀសបាន និងចំណាយបន្ថែម ដើម្បីប៉ះបូអ្វីដែលសាលារៀនសាធារណៈមិនបានផ្តល់ឱ្យ។ ខណៈពេលដែលគេតែងតែរិះគន់ប្រព័ន្ធអប់រំ ថាបានបើកទ្វារឱ្យអ្នកផ្តល់សេវាដែលជាតួអង្គមិនមែនរដ្ឋ ដែលជាអ្នកធ្វើឱ្យវិសមភាពមានការកើនឡើង ប្រព័ន្ធអប់រំសាធារណៈជាច្រើនខកខានពុំបានទប់ស្កាត់ការបែងចែកវណ្ណៈ និងការបែងចែកសិស្សជាក្រុមនោះឡើយ។

ការយល់ឃើញមិនត្រឹមត្រូវទី ៥.

ឪពុកម្តាយធ្វើការសម្រេចចិត្តជ្រើសរើសសាលារៀនផ្អែកតាមព័ត៌មានច្បាស់លាក់អំពីគុណភាព។




ការសន្មតគិមួយរបស់អ្នកដែលគាំទ្រដល់សាលារៀនដែលមិនមែនជាសាលារៀនរបស់រដ្ឋ និងជម្រើសសាលារៀន គឺថា មាតាបិតាក្នុងនាមជាអ្នកប្រើប្រាស់សេវា បានទទួលព័ត៌មានអំពីសាលារៀនដែលល្អបំផុត និងប្រើប្រាស់ព័ត៌មាននេះយ៉ាងមានប្រសិទ្ធភាព។ ក្នុងការអនុវត្តជាក់ស្តែង ទិន្នន័យអំពីផលជះរបស់សាលារៀនមានលក្ខណៈស្មុគស្មាញខ្លាំងពេកសម្រាប់ប្រទេសភាគច្រើន ក្នុងការគ្រប់គ្រង និងផ្សព្វផ្សាយ។ លើសពីនេះមាតាបិតាជារឿយៗមិនខ្វះនឹងព័ត៌មានទាំងនេះឡើយ ដោយពួកគេជ្រើសរើសសាលារៀនដែលមានភាពទាក់ទាញចំពោះពួកគេ ដោយសារហេតុផលផ្សេងទៀតដូចជាៈ ជំនឿសាសនា ភាពងាយស្រួល លក្ខណៈប្រជាសាស្ត្ររបស់សិស្សជាដើម។

ការយល់ឃើញមិនត្រឹមត្រូវទី ៦.

ការប្រកួតប្រជែងនាំឱ្យសាលារៀនមានការកែលម្អ។

សាលារៀនមិនចាំបាច់ធ្វើការកែលម្អឡើយ នៅពេលដែលសាសារៀនត្រូវប្រកួតប្រជែងជាមួយគ្នា



គណនេយ្យភាព និងការប្រកួតប្រជែងដែលល្អ លើកទឹកចិត្តឱ្យមនុស្សមួយចំនួនធ្វើការកែលម្អ។ នៅក្នុងវិស័យសេដ្ឋកិច្ច ក្រុមហ៊ុនប្រកួតប្រជែងដើម្បីរស់ ព្រោះថាការរកប្រាក់ចំណេញ គឺជាហេតុផលដែលធ្វើឱ្យពួកគេមានអត្ថិភាព។ ប៉ុន្តែវាមិនច្បាស់ឡើយថាតើការប្រកួតប្រជែងនេះមានលក្ខណៈបែបណានៅក្នុងការអប់រំនោះ។ កម្រមានការសិក្សាណាដែលបង្ហាញពីឥទ្ធិពលនៃការប្រកួតប្រជែងមកលើប្រព័ន្ធទាំងមូលណាស់ ដោយសារតែនេះគឺជាប្រធានបទដែលមានលក្ខណៈស្មុគស្មាញ ហើយលទ្ធផលរកឃើញទៀតសោត ក៏ពុំបង្ហាញពីសេចក្តីសន្និដ្ឋានឱ្យបានដាច់ណាត់។ អ្វីដែលពឹតតែធ្ងន់ធ្ងរទៅទៀតនោះ ការប្រកួតប្រជែងអាចធ្វើឱ្យសាលារៀនមិនមែនរដ្ឋធ្វើអ្វីទៅតាមការចង់បានរបស់មាតាបិតាចៀសជាងទៅតាមការអនុវត្តល្អផ្នែកគរុកោសល្យ។

ការយល់ឃើញមិនត្រឹមត្រូវទី ៧.

សាលារៀន និងសាកលវិទ្យាល័យឯកជន គឺជាគ្រឹះស្ថានដែលល្អជាង។



ការប្រៀបធៀបអត្រាប្រឡងជាប់រវាងសាលាសាធារណៈនិងសាលាឯកជន គឺជាកស្តុតាងជាធម្មតាដែលគេប្រើប្រាស់សម្រាប់រៀបចំតារាងចំណាត់ថ្នាក់សាលារៀន ដែលត្រូវបានសារព័ត៌មានរាយការណ៍ និងអានដោយមាតាបិតា។ នៅក្នុងការអនុវត្តវាជាក់ស្តែង ការទទួលយកសិស្ស ឱ្យរៀនឱ្យចូលរៀនមានលក្ខណៈផ្សេងៗគ្នាដោយមាតាបិតាដែលមានជីវភាពធូរធារ មានការអប់រំខ្ពស់ និងមានបំណងប្រាថ្នាខ្ពស់ច្រើនតែជ្រើសរើសយកសាលាឯកជន។ ដូច្នេះ សាលាឯកជនប្រហែលជាអាចជ្រើសរើសយកសិស្សដែលអាចជួយឱ្យពួកគេសម្រេចបានលទ្ធផលខ្ពស់បំផុត។ នៅពេលដែលគេទៅពិនិត្យលើកត្តាទាំងនេះ គម្លាតរវាងសាលាសាធារណៈ និងសាលាឯកជន ជាធម្មតា មានការថយចុះ ឬលែងមានតែម្តង។

ការយល់ឃើញមិនត្រឹមត្រូវទី ៨.


វិស័យឯកជន គឺជាដំណោះស្រាយចំពោះបញ្ហាប្រឈមនៅក្រៅសាលា។



ជាមួយនឹងសិស្សកម្រិតបឋមសិក្សា និងមធ្យមសិក្សាជាង ៣៥០ នាក់កំពុងរៀននៅតាមគ្រឹះស្ថានឯកជន វិបត្តិប្រាក់ដជាមិនអាចគេចរួចឡើយ ប្រសិនបើសិស្សទាំងនេះប្តូរមករៀននៅក្នុងប្រព័ន្ធអប់រំសាធារណៈវិញ។ ប៉ុន្តែសាលាឯកជនកំពុងរីកដូចផ្សិតនៅតាមតំបន់ប្រជុំជន ដែលកម្រិតនៃការចុះឈ្មោះចូលរៀនស្ទើរតែកៀកនឹងកម្រិតសកលទៅហើយ។ សាលារៀនឯកជនស្ទើរតែអវត្តមានតែម្តងនៅតំបន់ជនបទ។ ហើយនៅក្នុងប្រទេសដែលមានចំណូលទាប និងចំណូលមធ្យមវិញ កុមារមកពីគ្រួសារដែលមានជីវភាពធូរធារជាងគេ ២០% ទំនងជាចូលរៀននៅក្នុងសាលាឯកជនច្រើនជាងកុមារមកពីគ្រួសារដែលមានជីវភាពខ្សត់ខ្សោយជាងគេ ២០% ដល់ទៅ ១០ ដង។

ការយល់ឃើញមិនត្រឹមត្រូវទី ៩.

វិស័យឯកជនគឺជាដំណោះស្រាយចំពោះគម្លាតហិរញ្ញប្បទានអប់រំ។



ជារឿយៗ មានការលើកឡើងពីក្តីសង្ឃឹមខ្ពស់ថាវិស័យឯកជនអាចបំពេញតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ហិរញ្ញប្បទានដល់សកម្មភាពអប់រំ ដើម្បីជួយសម្រេចគោលដៅអភិវឌ្ឍន៍ដោយចីរភាពទី ៤។ កន្លងមកពុំមានកស្តុតាងបង្ហាញថាវិស័យអប់រំមានបំណង ឬមានសមត្ថភាពបំពេញតួនាទីនេះឡើយ។ ប៉ុន្តែវិស័យអប់រំអាចចូលរួមចំណែកផ្សេងទៀត ដូចជា តាមរយៈការបង់ពន្ធ ជាពិសេសនៅក្នុងប្រទេសដែលមានចំណូលទាប និងចំណូលមធ្យមកម្រិតទាបដែលអត្រាកៀរគរចំណូលក្នុងស្រុកមានកម្រិតទាប ហើយឱកាសគេចវេះពីការបង់ពន្ធមានកម្រិតខ្ពស់។ វិស័យឯកជនក៏អាចបំពេញតួនាទីដឹកនាំឱ្យបានរឹតតែខ្លាំងក្លាក្នុងសេវាអភិវឌ្ឍន៍ជំនាញ និងសេវាថែទាំកុមារ ស្របតាមលិខិតបទដ្ឋានគតិយុត្តរបស់ជាតិផងដែរ។

ការយល់ឃើញមិនត្រឹមត្រូវទី ១០.

លិខិតបទដ្ឋានគតិយុត្តអាចឆ្លើយតបចំពោះគ្រប់ក្តីបារម្ភទាំងអស់ ជុំវិញការផ្តល់សេវារបស់តួអង្គមិនមែនរដ្ឋ



មានការយល់ឃើញដូចៗគ្នាថា គួរមានការធ្វើបញ្ញត្តិកម្មលើសកម្មភាពរបស់តួអង្គមិនមែនរដ្ឋក្នុងវិស័យអប់រំ។ ប៉ុន្តែលិខិតបទដ្ឋានគតិយុត្តនានាពុំបានឆ្លើយតបប្រកបដោយអត្ថន័យជុំវិញរបៀបលើកកម្ពស់សមធម៌និងគុណភាពក្នុងប្រព័ន្ធទាំងមូលនោះឡើយ។ រដ្ឋាភិបាលមួយចំនួនតូចប៉ុណ្ណោះដែលធ្វើការពិនិត្យតាមដាន ថាតើការជ្រើសរើសយកសាលារៀនឯកជនរបស់គ្រួសារដែលមានជីវភាពធូរធារ នាំឱ្យមានការបែងចែកសិស្សជាក្រុមនៅក្នុងប្រព័ន្ធអប់រំ ឬតាមដានថាតើការចំណាយលើការអប់រំរបស់គ្រួសារនាំឱ្យមានការកើនឡើងបញ្ហាវិសមភាពបែបណានោះ។ រដ្ឋាភិបាលជាច្រើនអនុញ្ញាតឱ្យមានការជ្រើសរើសសិស្ស ដើម្បីចុះឈ្មោះចូលរៀនតាមសាលា។ រដ្ឋាភិបាលមួយចំនួនតូចប៉ុណ្ណោះ ធ្វើបញ្ញត្តិកម្មលើការបង្រៀនបន្ថែមជាលក្ខណៈឯកជន ឬការបញ្ចុះបញ្ចូល ដើម្បីសម្រេចគោលបំណងអ្វីមួយ ដែលភាគច្រើនពុំមានការកំណត់ឱ្យបានច្បាស់លាស់និងកើតឡើងក្នុងទម្រង់បំភាន់ភ្នែកថាជាភាពជាដៃគូ។ មានរដ្ឋាភិបាលតែតែតិចទៅទៀតដែលមានធនធាន សម្រាប់អនុវត្ត និងពង្រឹងការអនុវត្តលិខិតបទដ្ឋានគតិយុត្តនានាឱ្យមានប្រសិទ្ធភាព។

កាលពីប្រហែលជា ២៥ ឆ្នាំមុននៅសហរដ្ឋអាមេរិក នៅពេលកសិករតាងនានា ចាប់ផ្តើមលេចចេញបង្ហាញឱ្យឃើញពីផលវិបាកមិនស្មើគ្នាដែលកើតចេញទម្រង់គ្រឹះស្ថានថ្មីៗ ដែលផ្តល់សេវាអប់រំផ្អែកតាមជម្រើសសាលារៀន អ្នកនិពន្ធនៃការសិក្សាដំបូងៗ បានសង្ខេបលទ្ធផលរកឃើញចេញពីសំណួរ៖ តើនរណាជាអ្នករើសរើស? នរណាជាអ្នកខាតបង់? (Fuller and Elmore, 1996)។ ខណៈពេលដែលកសិករតាងមានកាន់តែច្រើនអំពីលក្ខណៈ ប្រសិទ្ធភាព និងផលវិបាកនៃជម្រើសរើសសាលារៀនទូទាំងសកលលោក របាយការណ៍តាមដានការអប់រំជាសកលនេះ បានយកសំណួរនេះទៅសួរក្រុមគោលដៅក្នុងសកលលោកទាំងមូល។ ទិដ្ឋភាពសំខាន់ៗចំនួន ៤ នៃសកម្មភាពរបស់តួអង្គមិនមែនរដ្ឋ – ដូចជាការផ្តល់សេវាអប់រំ ការធ្វើបញ្ញត្តិកម្ម ការផ្តល់ហិរញ្ញប្បទាន និងឥទ្ធិពល – ត្រូវបានវិភាគផ្តោតលើការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សាបន្ទាប់មកមានការវិភាគកាន់តែស៊ីជម្រៅលើទិដ្ឋភាពទាំងនេះ សម្រាប់កម្រិតអប់រំដទៃទៀត ដែលច្រើនតែទទួលបានការយកចិត្តទុកដាក់តិចតួច៖ ដូចជាការអប់រំកុមារតូច ការអប់រំកម្រិតឧត្តមសិក្សា និងការអប់រំបច្ចេកទេស វិជ្ជាជីវៈ និងការអប់រំមនុស្សពេញវ័យ។

ការផ្តល់សេវាអប់រំ

ការចូលរៀននៅតាមសាលារៀនមិនមែនរដ្ឋ បាននឹងកំពុងមានការកើនឡើង។ ភាគរយនៃគ្រឹះស្ថានឯកជនទូទាំងសកលលោកកើនឡើង ៧ ភាគរយចំណុចក្នុងរយៈពេលប្រហែលជា ១០ ឆ្នាំ, ពី ១០% ក្នុងឆ្នាំ ២០០២ ដល់ ១៧% ក្នុងឆ្នាំ ២០១៣ សម្រាប់ការអប់រំកម្រិតបឋមសិក្សា និងពី ១៩% ក្នុងឆ្នាំ ២០០៤ ដល់ ២៦% ក្នុងឆ្នាំ ២០១៤ សម្រាប់ការអប់រំកម្រិតមធ្យមសិក្សា ប៉ុន្តែនៅបន្តទ្រឹងក្នុងកម្រិតនេះចាប់តាំងពីពេលនោះមក (**រូបភាពទី ២**)។


កម្មសិទ្ធិការគ្រប់គ្រង និងហិរញ្ញប្បទានគឺជាលក្ខណៈនិយ័តកម្មតាសម្រាប់កំណត់ពីវិស័យមិនមែនរដ្ឋ។ គេអាចប្រើប្រាស់ទំនាក់ទំនងរវាងអ្នកផ្តល់សេវាជាមួយរដ្ឋ កត្តាដែលជំរុញលើកទឹកចិត្តពួកគេ ព្រមទាំងតម្លៃរបស់ពួកគេ ដើម្បីបែងចែកអ្នកផ្តល់សេវាទាំងនេះជាក្រុម។ ការវិភាគលើរបាយការណ៍នេះបានរកឃើញថា សាលារៀនបែបជំនឿសាសនាអាចត្រូវបានរកឃើញក្នុងប្រទេសចំនួន ១២៤ លើ ១៩៦។ សាលារៀនរបស់អង្គការក្រៅរដ្ឋាភិបាល (NGO) និងសាលារៀនសហគមន៍អាចរកឃើញនៅក្នុងប្រទេសចំនួន ៧៤ លើ ១៩៦ ជារឿយៗនៅក្នុងបរិបទនៃស្ថានភាពអាសន្ន។ សាលារៀនរកប្រាក់ចំណេញមានភាគតិចប៉ុណ្ណោះលើកលែងក្នុងបរិបទមួយចំនួនតូចដូចជានៅប្រទេសអារ៉ាប់រួមជាដើម។ សាលារៀនជាច្រើនប្រភេទដែលយកតម្លៃតិចតួច ហើយភាគច្រើនជាសាលារៀនបែបឯកកម្មសិទ្ធិនៅតាមប្រទេសចំណូលទាប និងចំណូលមធ្យម នៅអាហ្វ្រិក សាប់សាហារ៉ា និងអាស៊ីត្រូវបានគេស្គាល់ថាជាសាលារៀនឯកជនដែលយកថ្លៃសេវាទាប។

សាលារៀនរដ្ឋ និងសាលារៀនមិនមែនរដ្ឋខុសគ្នាត្រង់ការទទួលយកសិស្សឱ្យចូលរៀន និងធនធាន។ កុមារដែលមានជីវភាពក្រីក្រមួយចំនួនតូចមានជម្រើសចូលរៀននៅក្នុងសាលាឯកជន។ ដើម្បីវាយតម្លៃលើគុណភាពនៃការអប់រំដែលទទួលបាន មាតាបិតាតែងពិចារណាលើចំនួនសិស្សក្នុងថ្នាក់ គុណភាព និងកិច្ចខិតខំប្រឹងប្រែងរបស់គ្រូ ភាពឆ្លើយតបរបស់សាលារៀន វិន័យ និងសុវត្ថិភាព ភាសាដែលប្រើប្រាស់សម្រាប់ការបង្រៀន សាសនា ជាតិពន្ធ និងវប្បធម៌។ នៅចក្រភពអង់គ្លេស ការវិភាគលើសាលារៀននៅអង់គ្លេសចំនួន ១៨.០០០ កន្លែង ដែលធ្វើការប្រៀបធៀបសាលាសាធារណៈជាមួយនឹងសាលាសាធារណៈដែលគ្រប់គ្រងដោយឯកជន បានរកឃើញថាសាលាសាធារណៈដែលគ្រប់គ្រងដោយឯកជនមានគ្រូដែលពុំមានគុណវុឌ្ឍិក្នុងភាគរយមួយខ្ពស់ជាង។

រូបភាពទី ២៖

ភាគរយនៃការចុះឈ្មោះចូលរៀនក្នុងសាលាឯកជនមានខ្ពស់បំផុតនៅអាស៊ីខាងត្បូង

ភាគរយនៃការចុះឈ្មោះចូលរៀននៅតាមក្រឹត្យសាស្ត្រឯកជន បែងចែកតាមកម្រិតអប់រំ ១៩៩០–២០១៩



ប្រភព៖ ប្រព័ន្ធទិន្នន័យ UIS។

សាលារៀនសាធារណៈ និងសាលារៀនឯកជនអាចខុសគ្នា ទៅតាមធនធានដទៃទៀត។ នៅអាមេរិកឡាទីនចំនួនកុំព្យូទ័រគិតជាមធ្យមសម្រាប់សិស្សម្នាក់នៅសាលាឯកជន គឺស្មើនឹងពីរដងច្រើនជាងនៅសាលាសាធារណៈ។

កស្តុតាងភាគច្រើនបង្ហាញថា គុណសម្បត្តិចំពោះការសិក្សារៀនសូត្រដែលបានពីការចូលរៀននៅសាលាឯកជននៅមានកម្រិត។ ទិន្នន័យសម្រាប់ប្រទេសប្រាក់ចំណូលទាប និងចំណូលមធ្យមចំនួន ៣១ បានបង្ហាញថាបុព្វលាភប៉ាន់ប្រមាណដែលទទួលបានពីការចូលរៀននៅសាលាឯកជនថយចុះពីពាក់កណ្តាលដល់ ២ ភាគ ៣ ក្រោយពីបានកែសម្រួលទៅតាមទ្រព្យធនរបស់គ្រួសាររួចមក។ លើសពីនេះ ខណៈពេលដែលការផ្តល់សេវាអប់រំស្នូលរបស់តួអង្គមិនមែនរដ្ឋ អាចបំពេញគម្លាតក្នុងរយៈពេលខ្លី ឬមធ្យម វាអាចនាំឱ្យមានការបែងចែកសិស្សជាក្រុម និងវិសមភាពទៅវិញទេ។ ក្នុងប្រទេសស៊ុយអែត ក្រុងចំនួន ២៩ លើ ៣០ មានសាលាបឋមសិក្សាបឋមភូមិដែលបែងចែកសិស្សជាក្រុមក្នុងកម្រិតមួយខ្ពស់។ ក្នុងក្រុងចំនួន ១៦ ការបែងចែកសិស្សជាក្រុមហាក់បីដូចជាកើតដោយសារតែជម្រើសសាលារៀន។ ខណៈពេលដែលការប្រកួតប្រជែងជាមួយនឹងសាលារៀនមិនមែនរដ្ឋជួយជំរុញឱ្យសាលាសាធារណៈមានការកែលម្អ វត្តមានរបស់សាលាឯកជន ឬសាលារៀនផ្សេងទៀតតែមួយមុខគត់ នៅជិតនឹងសាលាសាធារណៈអាចមិនមែនជាកត្តាលើកទឹកចិត្តគ្រប់គ្រាន់ឱ្យអាជ្ញាធរនៃសាលាសាធារណៈចាត់វិធានការនោះឡើយ ប្រសិនបើពួកគេពុំមានធនធានហិរញ្ញវត្ថុ ឬស្វ័យភាព ដើម្បីធ្វើការឆ្លើយតបនោះ។

ការបង្រៀនបន្ថែមជាលក្ខណៈឯកជន កើតមានស្ទើរតែទូទៅ។ ការបង្រៀនបន្ថែមជាលក្ខណៈឯកជនដែលកើតមានជាទូទៅនៅតាមប្រទេសជាច្រើននៅអាស៊ីបូព៌ា និងរដ្ឋអារ៉ាប់ ក៏កំពុងសាយភាយនៅតាមតំបន់ដែលពុំមានការបង្រៀនបែបនេះកន្លងមក ដូចជានៅអាហ្វ្រិកសាប់សាហារ៉ា និងអឺរ៉ុបខាងជើងជាដើម។ តម្រូវការការបង្រៀនបន្ថែមមានភាពពាក់ព័ន្ធច្រើនបំផុតជាមួយភាពចាំបាច់របស់សិស្ស ដើម្បីត្រៀមចូលរួមក្នុងការប្រឡងកម្រិតខ្ពស់ដើម្បីឱ្យពួកគេអាចមានឧត្តមភាពប្រកួតប្រជែង។ ប៉ុន្តែផលជះនៃការបង្រៀនបែបនេះ មកលើលទ្ធផលរបស់សិស្សម្នាក់ៗនៅមានភាពចម្រុះនៅឡើយ៖ ការសិក្សាមួយចំនួនបានរកឃើញពីផលវិជ្ជមានសម្រាប់អ្នកដែលស្ថិតនៅខាងក្រោយគេបំផុត ខណៈពេលដែលការសិក្សាផ្សេងទៀត រកឃើញថាការបង្រៀនក្រៅម៉ោងបែបនេះពុំបានផ្តល់ផលវិជ្ជមានក្នុងលក្ខណៈជាប្រព័ន្ធលើលទ្ធផលសិក្សារបស់សិស្សឡើយ។ ទោះជាយ៉ាងនេះក្តី ការបង្រៀនក្រៅអាចធ្វើឱ្យប៉ះពាល់សមិទ្ធកម្មនៃប្រព័ន្ធអប់រំទាំងមូលព្រោះថាវាអាចជះឥទ្ធិពលអវិជ្ជមានលើឥរិយាបថរបស់សិស្ស និងគ្រូទៅវិញ។

គោលនយោបាយលទ្ធកម្ម និងការបែងចែកសៀវភៅសិក្សាមានការចូលរួមពីរដ្ឋខុសៗគ្នា។ នៅតាមប្រទេសមួយចំនួនការងារបោះពុម្ពផ្សាយធ្វើឡើងជាចម្បងដោយសហគ្រាសរបស់រដ្ឋ និងគ្រប់គ្រងដោយរដ្ឋ។ នៅក្នុងប្រទេសផ្សេងទៀត មានការប្រើប្រាស់ប្រព័ន្ធចម្រុះដែលមានការបោះពុម្ពផ្សាយពីស្ថាប័នសាធារណៈផង និងស្ថាប័នឯកជនផង។ ប្រទេសដែលមានចំណូលខ្ពស់ជាច្រើន ដូចជាប្រទេសអេស្ប៉ាញជាដើម ទុកការងារបោះពុម្ពផ្សាយសៀវភៅសិក្សាឱ្យអ្នកផ្តល់សេវាជាលក្ខណៈ

ពាណិជ្ជកម្ម ដោយរដ្ឋាភិបាលចូលរួមផ្តល់ជាការណែនាំ និងអនុម័តលើសំណើនានា។ ទំនាក់ទំនងរវាងក្រុមហ៊ុនបោះពុម្ពផ្សាយអន្តរជាតិ អ្នកផ្តល់ជំនួយ និងផលប្រយោជន៍ក្នុងស្រុកធ្វើឱ្យអន្តរកាលឆ្ពោះទៅប្រើប្រាស់ការបោះពុម្ពផ្សាយក្នុងស្រុកនៅតាមប្រទេសក្រីក្រមានលក្ខណៈស្មុគស្មាញ។ ឧទាហរណ៍ ឧស្សាហកម្មបោះពុម្ពសៀវភៅសិក្សានៅក្នុងប្រទេសហ្គាប៊ីនភាគច្រើនទទួលសេវាពី Edicef ជាសាខាបោះពុម្ពផ្សាយសៀវភៅសិក្សារបស់ក្រុមហ៊ុន Hachette Livre ដែលជាក្រុមហ៊ុនរបស់ប្រទេសបារាំង និងជាក្រុមហ៊ុនបោះពុម្ពផ្សាយធំជាងគេក្នុងសកលលោក។

ក្រុមហ៊ុនបោះពុម្ពផ្សាយ និងក្រុមហ៊ុនបច្ចេកវិទ្យាធំៗជាអ្នកជំរុញការធ្វើឌីជីថលនីយកម្មមាតិកា។ ក្រុមហ៊ុន Pearson ដែលជាក្រុមហ៊ុននាំមុខគេក្នុងសកលលោកខាងបោះពុម្ពផ្សាយឯកសារអប់រំ បានប្តូរពាក្យស្លោករបស់ខ្លួនពី ក្រុមហ៊ុនបោះពុម្ពផ្សាយធំជាងគេលើពិភពលោកនៃសៀវភៅសិក្សា និងឯកសារបង្រៀនតាមប្រព័ន្ធអនឡាញទៅជា "ក្រុមហ៊ុនផ្តល់សេវារៀនសូត្រតាមប្រព័ន្ធឌីជីថលរបស់ពិភពលោក" ជាមួយនឹងការផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងលើការរៀនតាមប្រព័ន្ធអនឡាញ និងការវាយតម្លៃតាមប្រព័ន្ធអនឡាញ។ ក្រៅតែពីក្រុមហ៊ុនបោះពុម្ពផ្សាយសៀវភៅសិក្សាធំៗលើសកលលោក និងក្នុងតំបន់ ក្រុមហ៊ុនយក្សខាងបច្ចេកវិទ្យាបានចូលខ្លួនមកក្នុងវិស័យអប់រំតាមប្រព័ន្ធអនឡាញ ដែលមានតម្រូវការកាន់តែខ្លាំង ក្នុងអំឡុងពេលនៃការរាតត្បាតជាសកលនៃជំងឺកូវីដ ១៩។ ការវិភាគលើបទពិសោធន៍ជាមួយនឹងដំណើរការធ្វើកិច្ចទូកម្មបច្ចេកវិទ្យាអប់រំនៅសហរដ្ឋអាមេរិកបានរកឃើញថា ការិយាល័យអប់រំស្រុក (school districts) និងសាលារៀនធម្មតាទទួលបានព័ត៌មានច្រើនលើសលុបពីអ្នកផ្តត់ផ្តង់សេវាបច្ចេកវិទ្យាអប់រំរាប់ពាន់ ដែលធ្វើការផ្សព្វផ្សាយពីផលិតផលជាច្រើន។

រដ្ឋាភិបាលកាន់តែជួលឱ្យអ្នកផ្តល់សេវាខាងក្រៅផ្តល់សេវាគាំទ្របន្ថែមទៀតក្នុងវិស័យអប់រំ។ អ្នករិះគន់ការជួលឱ្យអ្នកខាងក្រៅផ្តល់សេវាបែបនេះ បារម្ភថាការធ្វើឯកជនភាវូបនីយកម្មអាចធ្វើឱ្យប៉ះពាល់ដល់សេវាសាធារណៈ និងការបំពេញវិជ្ជាជីវៈ។ ការវិភាគមួយនៅអូស្ត្រាលីបានរកឃើញថា ការជួលបុគ្គលិកសម្អាតពីខាងក្រៅកាន់តែច្រើននាក់ នាំឱ្យមានការកែសាយភាយក្រុមហ៊ុនទទួលការងារបែបនេះ បង្កើនចំនួនករណីផ្តល់ប្រាក់ឈ្នួលតិចតួច ការថយចុះនៅចំនួនម៉ោងសម្អាត និងការសម្រេចបានស្តង់ដារសុខភាព និងសុវត្ថិភាពការងារទាបជាមុន។

អភិបាលកិច្ច និងការធ្វើនិយ័តកម្ម

អភិបាលកិច្ចអ្នកផ្តល់សេវាអប់រំមិនមែនរដ្ឋ ជារឿយៗ មានភាពបែកខ្ញែកពីគ្នា។ អភិបាលកិច្ចល្អ និងការធ្វើបញ្ញត្តិកម្មដែលមានប្រសិទ្ធភាព គឺជាកត្តាគន្លឹះដែលកំណត់ពីសមត្ថភាពរបស់រដ្ឋាភិបាល ក្នុងផ្តល់សេវាអប់រំដែលមានគុណភាពល្អប្រកបដោយសមធម៌។ នៅក្នុងប្រទេសចំនួន ៩៤ ផែនការ ឬយុទ្ធសាស្ត្រតាមវិស័យ លើកឡើងពីអន្តរាគមន៍ ពីសំណាក់តួអង្គមិនមែនរដ្ឋក្នុងការផ្តល់សេវាអប់រំឬការផ្តល់សេវាផ្សេងទៀត។ ក្រសួងឬនាយកដ្ឋានចែករំលែកការទទួលខុសត្រូវក្នុងប្រទេសមួយចំនួន។ ភាពបែកខ្ញែកគ្នា ការខ្វះការសម្របសម្រួល និងការធ្វើការត្រួតគ្នា ឬការកំណត់ការទទួលខុសត្រូវមិនច្បាស់លាស់ អាចមានឥទ្ធិពលជាអវិជ្ជមានលើសមធម៌ និងគុណភាព។ មានប្រទេសត្រឹមតែ ៣៩% ប៉ុណ្ណោះ ដែលមាននាយកដ្ឋាន ផ្នែក ឬស្ថាប័នទទួលបន្ទុកការអប់រំឯកជននៅថ្នាក់ជាតិ ដែលស្ថិតក្រោមផ្នែកទទួលបន្ទុកការអប់រំកម្រិតបឋមសិក្សា ឬមធ្យមសិក្សា។ ក្រសួងអប់រំ គឺជាស្ថាប័នតែមួយគត់ ដែលទទួលខុសត្រូវលើការធានាគុណភាពរបស់តួអង្គមិនមែនរដ្ឋក្នុងប្រទេសចំនួន ៨៣% ខណៈពេលដែល ១៣% ទៀតជាការទទួលខុសត្រូវរបស់អាជ្ញាធរជាច្រើន។ ក្រសួងទទួលបន្ទុកកិច្ចការសាសនា ដែលមិនមែនជាក្រសួងអប់រំ ជាស្ថាប័នទទួលខុសត្រូវលើសាលារៀនដែលផ្តល់ការអប់រំតាមបែបជំនឿសាសនាក្នុងប្រទេសចំនួន ២២% – និង ៧0% នៅអាហ្វ្រិកខាងជើង និងអាស៊ីខាងលិច។

យន្តការផ្តល់ហិរញ្ញប្បទាន មានឥទ្ធិពលលើអភិបាលកិច្ច។ តួអង្គមិនមែនរដ្ឋទទួលបានការគាំទ្រហិរញ្ញវត្ថុផ្ទាល់ និងប្រយោលពីរដ្ឋាភិបាលក្នុងទម្រង់ជាច្រើន៖ ជាឧបត្ថម្ភធន សម្រាប់សិស្សម្នាក់ (ក្នុងប្រទេសចំនួន ៧៩%), ឧបត្ថម្ភធនសម្រាប់មាតាបិតា (២៣%), ការឧបត្ថម្ភបៀវត្សដល់គ្រូបង្រៀន ឬចំណាយប្រតិបត្តិការដទៃទៀត (ប្រហែលជា ៧0%) និងកម្ចី ឬអំណោយ (២៧%)។ ភាពជាដៃគូរដ្ឋ និងឯកជន រួមមានការចូលរួមសហការគ្នានៅកម្រិតផ្សេងៗរវាងតួអង្គ៣ក់ព័ន្ធនីមួយៗ ក៏ដូចជាការរៀបចំគោលនយោបាយ និងការរៀបចំគិតយុត្តដែលមានលក្ខណៈចម្រុះ។ ការពិនិត្យលើការសិក្សាអំពីយន្តការផ្តល់ថវិកាគាំទ្ររកឃើញថា ជារឿយៗ ផលជះមានលក្ខណៈអវិជ្ជមាន។ នៅក្នុងការសិក្សាយ៉ាងហោចណាស់ ២ ភាគ ៣ នៃការសិក្សាចំនួន ៩៨ មានការរកឃើញថា ផលជះមកលើសមធម៌នៃឧបត្ថម្ភធន កម្មវិធីឧបត្ថម្ភតាមរយៈការចេញប័ណ្ណជូនអ្នកទទួលផល និងកម្មវិធីអប់រំដែលមានផ្តល់ការស្នាក់នៅជូនមានលក្ខណៈអវិជ្ជមាន។

លិខិតបទដ្ឋានគតិយុត្តគួរជួយបង្កើនគុណភាព និងសមធម៌ក្នុងការអប់រំ។ ប្រទេសស្ទើរតែទាំងអស់មានលិខិតបទដ្ឋានគតិយុត្តដែលចែងពីលក្ខខណ្ឌតម្រូវសម្រាប់ការចូលរៀន និងប្រតិបត្តិការរបស់សាលាមិនមែនរដ្ឋ រួមនឹងការចុះឈ្មោះ និងការចេញអាជ្ញាប័ណ្ណផងដែរ។ នៅក្នុងប្រទេសចំនួន ៨0% មានលិខិតបទដ្ឋានគតិយុត្ត ដែលកំណត់ពីក្រឡាផ្ទៃដែលត្រូវមាន ដូចជាទំហំទីតាំង ឬទំហំអាគារ និងក្រឡាផ្ទៃបន្ទប់ថ្នាក់អប្បរមាជាដើម។ នៅក្នុងរដ្ឋហាយ៉ាណា នៃប្រទេសឥណ្ឌា អាគារត្រូវតែជាកម្មសិទ្ធិផ្ទាល់ ឬជួលក្នុងរយៈយ៉ាងហោចណាស់ ២0 ឆ្នាំ ដើម្បីបង្កើតជាសាលារៀនបាន។ រដ្ឋមួយទៀត គឺរដ្ឋអ៊ុតារ៉ាប្រាដេស ប្រើប្រាស់លក្ខណៈវិនិច្ឆ័យចំនួន ២ ដើម្បីផ្តល់ការទទួលស្គាល់ដល់សាលារៀនណាមួយ៖ ក្រឡាផ្ទៃអប្បរមាក្នុងសិស្សម្នាក់ (៩ ម៉ែត្រការ៉េ) និងទំហំបន្ទប់រៀន (១៨0 ម៉ែត្រការ៉េ)។ លិខិតបទដ្ឋានគតិយុត្តក៏ត្រូវចែងពីទឹក និងអនាម័យផងដែរ។ ក្នុងប្រទេស ៤៧% ដែលមានទិន្នន័យ ចាំបាច់ត្រូវមានបង្គន់សម្រាប់ភាជន៍តែមួយនៅតាមសាលារៀនមិនមែនរដ្ឋ។ នៅក្នុងប្រទេស ៧៤% មានការកំណត់ពីផលធៀបសិស្ស/គ្រូ។ ប្រទេសប្រមាណ ៥៥% មានលិខិតបទដ្ឋានគតិយុត្ត ចែងពីនីតិវិធីសម្រាប់ទទួលយកសិស្សឱ្យចូលរៀននៅតាមសាលាមិនមែនរដ្ឋ ខណៈពេលដែល ៦៧% ចែងពីថ្លៃសិក្សានៅតាមសាលាមិនមែនរដ្ឋ សម្រាប់ការអប់រំដែលត្រូវបានកំណត់ជាកាតព្វកិច្ច។ ប្រទេស ២ ភាគ ៣ មានលិខិតបទដ្ឋានគតិយុត្ត ស្តីពីកម្មវិធីសិក្សា។ នៅក្នុងរយៈពេល ១0 ឆ្នាំចុងក្រោយនេះ ប្រទេសចំនួន ២១ បានដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តស្តីពីការកកប្រាក់ចំណេញ និងប្រទេសចំនួន ៨0 មានលិខិតបទដ្ឋានគតិយុត្តស្តីពីការផ្តល់វិញ្ញាបនបត្របញ្ជាក់ដល់គ្រូបង្រៀន។

ការអនុវត្តដែលមានកម្រិតខ្សោយ និងគណនេយ្យភាពមិនគ្រប់គ្រាន់ ធ្វើឱ្យប៉ះពាល់ដល់គុណភាព និងសមធម៌នៃការអប់រំ។ ការដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តពុំមានន័យថាអ្នកផ្តល់សេវាមិនមែនរដ្ឋប្រាកដជាអនុវត្តតាមនោះឡើយ។ នៅក្នុងប្រទេសចំណូលទាប និងចំណូលមធ្យមកម្រិតទាបមួយចំនួន នីតិវិធីចុះឈ្មោះដែលមានលក្ខណៈស្មុគស្មាញ អស់ចំណាយច្រើន ឬត្រូវការពេលយូរជាកត្តាដែលរារាំងអ្នកផ្តល់សេវា មិនឱ្យដាក់ពាក្យសុំការទទួលស្គាល់ជាផ្លូវការ។ នៅក្នុងរដ្ឋ Lagos ប្រទេសនីហ្សេរីយ៉ាមានសាលារៀនឯកជនប្រមាណ ២០.០០០ កន្លែងគិតត្រឹមឆ្នាំ ២០២១ ហើយមានសាលារៀនតែ ១ ក្នុងចំណោមសាលារៀន ៤ ប៉ុណ្ណោះដែលបានទទួលការទទួលស្គាល់ពីរដ្ឋាភិបាល។ ស្ថិតិរបស់ប្រទេសយ៉ាងហោចណាស់ ២៧ ទទួលស្គាល់សាលារៀនដែលមិនបានចុះបញ្ជី។ ប្រទេសអូហ្គង់ដាចាត់ចំណាត់ថ្នាក់សាលាមិនមែនរដ្ឋថាជាសាលារៀនដែលមានអាជ្ញាប័ណ្ណ សាលារៀនដែលបានចុះបញ្ជី និងសាលារៀនដែលពុំបានចុះបញ្ជីៈ សាលាបឋមសិក្សា ១៤% និងសាលាមធ្យមសិក្សា ១៣% ពុំបានចុះបញ្ជីឡើយ។ ការខ្វះការត្រួតពិនិត្យអាចនាំឱ្យមានការជ្រើសរើសសិស្សមិនផ្លូវការ។ នៅក្នុងទីក្រុង Bogotá ប្រទេសកូឡុំប៊ីកម្មវិធីសាលារៀនសម្បទាន ដែលអនុវត្តដោយសាលារៀនដែលទទួលយកសិស្សឱ្យស្នាក់នៅ (charter schools) ដែលត្រូវបានបង្កើតឡើង ដើម្បីផ្តល់សេវាដល់សិស្សដែលងាយរងគ្រោះ មានគោលនយោបាយទទួលយកសិស្សឱ្យចូលរៀន ផ្អែកតាមគោលការណ៍មិនរើសអើង និងភាពនៅជិតនៃអាសយដ្ឋានរបស់សិស្ស នៅក្នុងស្ថានភាពជាក់ស្តែង បើទោះជាវាមានលក្ខណៈមិនផ្លូវការក៏ដោយ ការជ្រើសរើសសិស្ស គឺផ្អែកតាមលទ្ធផលសិក្សារបស់សិស្ស។

ជំណើរការ និងស្តង់ដារសម្រាប់ធានាគុណភាព មានការប្រែប្រួលខុសៗគ្នា។ ក្នុងការអនុវត្តជាក់ស្តែងគ្រប់ប្រទេសទាំងអស់ពង្រឹងការអនុវត្តស្តង់ដារសម្រាប់សាលារៀនមិនមែនរដ្ឋ តាមរយៈអធិការកិច្ចសាលារៀន។ ក្នុងប្រទេសចំនួន ៨១% កាតព្វកិច្ចនេះ គឺពាក់ព័ន្ធជាមួយនឹងសាលារៀនរដ្ឋគ្រប់ប្រភេទទាំងអស់ ក្នុងប្រទេសចំនួន៣% កាតព្វកិច្ចនេះពាក់ព័ន្ធតែជាមួយនឹងសាលារៀនដែលទទួលបានជំនួយពីរដ្ឋតែប៉ុណ្ណោះ។ លើសពីនេះប្រទេស ៨១% មានលិខិតបទដ្ឋានគតិយុត្ត ដែលតម្រូវឱ្យសាលារៀនមិនមែនរដ្ឋចូលរួមនៅក្នុងការវាយតម្លៃទ្រង់ទ្រាយធំ។ ក្នុងប្រទេសជាងពាក់កណ្តាលនៃប្រទេសទាំងនេះ កាតព្វកិច្ចនេះគ្របដណ្តប់លើសាលារៀនមិនមែនរដ្ឋគ្រប់ប្រភេទទាំងអស់ ខណៈពេលដែលនៅក្នុងប្រទេសចំនួន ១២%កាតព្វកិច្ចនេះ គឺពាក់ព័ន្ធតែជាមួយនឹងសាលារៀនដែលទទួលបានជំនួយគាំទ្រពីរដ្ឋាភិបាលតែប៉ុណ្ណោះ។

យន្តការគណនេយ្យភាព ការដាក់ទោស និងយន្តការដោះស្រាយដែលមានប្រសិទ្ធភាពក៏អាចជំរុញលើកកម្ពស់ភាពអនុលោមផងដែរ។ រដ្ឋាភិបាលគួរទាមទារគណនេយ្យភាពពីអ្នកផ្តល់សេវាអប់រំ ដើម្បីឱ្យពួកគេអនុលោមតាមស្តង់ដារស្តីពីគុណភាព ធាតុចូល សុវត្ថិភាព និងបរិយាបន្ន។ ប្រទេសស្ទើរតែទាំងអស់អនុវត្តការដាក់ទោស ការបិទសាលារៀន ឬការដកហូតអាជ្ញាប័ណ្ណ ប្រសិនបើសាលារៀនមិនមែនរដ្ឋមិនអនុលោមតាមលិខិតបទដ្ឋានគតិយុត្តនានា។ សាលារៀនប្រមាណ ៥៤% ក៏ធ្វើនិយ័តកម្មនៃរយៈពេលនៃការបិទសាលារៀនផងដែរ។ ប្រទេសប្រមាណ ៩០% មានក្រមសីលធម៌ឬក្រមប្រតិបត្តិសម្រាប់គ្រូបង្រៀន និងបុគ្គលិកសាលារៀន ដែលក្រមសីលធម៌ទាំងនេះ ជារឿយៗក៏គ្របដណ្តប់អ្នកផ្តល់សេវាមិនមែនរដ្ឋផងដែរ។

កម្រមានការធ្វើនិយ័តកម្មលើការបង្រៀនបន្ថែមជាលក្ខណៈឯកជនណាស់។ ការបង្រៀនបន្ថែមជាលក្ខណៈឯកជនពុំមានការគ្រប់គ្រងឱ្យបានត្រឹមត្រូវ ក្នុងប្រទេសចំនួន ៤៨%។ មានប្រទេសតែ ៥៣% ប៉ុណ្ណោះ ដែលចែងពីការបង្រៀនបន្ថែមជាលក្ខណៈឯកជន នៅក្នុងច្បាប់អប់រំ ខណៈពេលដែលប្រទេសចំនួន ១៩ ចែងពីការបង្រៀនបន្ថែមជាលក្ខណៈឯកជននៅក្នុងច្បាប់ពាណិជ្ជកម្ម។ ក្នុងប្រទេស ៣១% មានលិខិតបទដ្ឋានគតិយុត្តដែលចែងពីគុណវុឌ្ឍិ ដែលគ្រូបង្រៀនឯកជនត្រូវមាន ប្រទេសចំនួន ១០ ហាមប្រាមគ្រូបង្រៀនមិនឱ្យផ្តល់សេវាបង្រៀនជាលក្ខណៈឯកជន។ នៅក្នុងប្រទេសចិន ច្បាប់ឆ្នាំ ២០២១ ហាមក្រុមហ៊ុនមិនឱ្យបង្រៀនដោយប្រើប្រាស់កម្មវិធីសិក្សាជាកាតព្វកិច្ចមិនឱ្យរកប្រាក់ចំណេញ និងមិនឱ្យរៃអង្គាសប្រាក់ ដើម្បីបង្កើនមូលធនរបស់ខ្លួន និងហាមប្រាមមិនឱ្យមានការចេញអាជ្ញាប័ណ្ណថ្មីៗឡើយ។ ក្រុមហ៊ុនទាំងនេះចាំបាច់ត្រូវតែមិនរកប្រាក់ចំណេញទើបអាចបន្តប្រតិបត្តិការរបស់ខ្លួនទៀត។ រដ្ឋាភិបាលក៏បានបង្កើតនាយកដ្ឋានពិសេសមួយ ដើម្បីធ្វើនិយ័តកម្ម និងពិនិត្យតាមដានក្រុមហ៊ុនដែលផ្តល់សេវាបង្រៀនបន្ថែមជាលក្ខណៈឯកជនផងដែរ។

ហិរញ្ញវត្ថុ

រដ្ឋាភិបាលធ្វើការសម្រេចចិត្តខុសៗគ្នា ថាតើត្រូវផ្តល់ថវិកាគាំទ្រដល់អ្នកផ្តល់សេវាមិនមែនរដ្ឋដែរឬទេ និងត្រូវផ្តល់ថវិកាគាំទ្រដោយរបៀបណា។ នៅក្នុងប្រទេសកាណាដារដ្ឋាភិបាលរ៉ាប់រង ៣០% នៃចំណាយរបស់សាលាឯកជន ប៉ុន្តែ ៩៤% នៃចំណាយរបស់សាលាសាធារណៈ។ នៅក្នុងប្រទេសហូឡង់ សាលារៀនទាំងអស់ មិនថាប្រភេទណានោះឡើយ ទទួលបានថវិកាសម្រាប់រ៉ាប់រងចំណាយបុគ្គលិក និងចំណាយប្រតិបត្តិព្រមទាំងថវិកាបន្ថែមសម្រាប់សិស្ស ដែលជួបការលំបាកផ្នែកសង្គម និងសេដ្ឋកិច្ច និងសិស្សដែលមានតម្រូវការអប់រំពិសេស។ ចាប់តាំងពីឆ្នាំ ២000 មកប្រទេសជាច្រើន ដូចជាឈីលី ហុងគ្រី ស៊ុយអែត និងចក្រភពអង់គ្លេស មានភាគរយនៃការចុះឈ្មោះចូលរៀនក្នុងសាលាឯកជន ដែលពឹងផ្អែកលើការគាំទ្រពីរដ្ឋាភិបាលច្រើនជាងមុន ពោល គឺសាលាដែលបានទទួលថវិកាគាំទ្រពីរដ្ឋាភិបាលយ៉ាងហោចណាស់ ៥0%។

រដ្ឋាភិបាលផ្តល់ហិរញ្ញប្បទាន ដើម្បីរ៉ាប់រងចំណាយខ្លះៗរបស់សាលារៀនមិនមែនរដ្ឋតែប៉ុណ្ណោះ។ ក្នុងប្រទេសបង់ក្លាដែសមានសាលាមធ្យមសិក្សាមិនមែនរដ្ឋជាង ១៦.000 កន្លែង និងសាលា madrasas ចំនួន ៧.៦00 កន្លែង ដែលរួមគ្នាស្រូបយកសិស្ស ៩៦% ទទួលបានថវិកាប្រចាំខែសម្រាប់រ៉ាប់រងចំណាយលើបៀវត្សគ្រូ។ ប៉ុន្តែប្រទេសហៃទី ដែលសាលាបឋមសិក្សា ៨៥% គឺជាសាលាមិនមែនរដ្ឋ ពុំបានរ៉ាប់រងលើចំណាយសម្រាប់បៀវត្សនោះឡើយ។ នៅក្នុងប្រទេសឥណ្ឌា មានសាលាបឋមសិក្សា និងមធ្យមសិក្សាតែ ៦% ប៉ុណ្ណោះ ដែលបានទទួលថវិកាគាំទ្រសម្រាប់រ៉ាប់រងបៀវត្សរបស់គ្រូក្នុងឆ្នាំ ២០១៩/២០។ នៅក្នុងប្រទេសឥណ្ឌូនេស៊ី សាលារៀន madrasas និងសាលាសាសនាឥស្លាម ដែលគេហៅថា pesantren ស្រូបយកសិស្ស ៣៥% ក្នុងចំណោមសិស្សដែលរៀននៅសាលាឯកជន ត្រូវបានដាត់ចេញពីយន្តការផ្តល់ថវិកាគាំទ្រមួយចំនួន។

រដ្ឋាភិបាលគាំទ្រដល់ការទទួលយកសិស្សជួបការលំបាកឱ្យរៀនតាមសាលាមិនមែនរដ្ឋ។ នៅក្នុងប្រទេសឥណ្ឌា ច្បាប់ស្តីពីសិទ្ធិទទួលបានការអប់រំឆ្នាំ ២00៩ តម្រូវឱ្យសាលាឯកជនកៅអី ២៥% សម្រាប់ថ្នាក់ទី ១ ដល់កុមារមកពីគ្រួសារដែលមានចំណូលទាប។ ជាថ្នូរនឹងការ

ធ្វើបែបនេះ រដ្ឋាភិបាលទូទាត់ចំណាយជូននៅចំណាយសម្រាប់ការសិក្សារបស់កុមារទាំងនេះ។ ផ្ទុយទៅវិញប្រទេសកូដូវ័រ ដែលចំនួនសិស្សនៅសាលារៀនមធ្យមសិក្សាដែលទទួលបានឧបត្ថម្ភធនពីរដ្ឋាភិបាលកើនឡើង ៤ ដងចន្លោះពីឆ្នាំ ២០១០/១១ និង ២០១៧/១៨ ពុំបានផ្តោតគោលដៅលើការចូលរៀនប្រកបដោយសមធម៌នោះឡើយ។

គ្រួសារទទួលរងបន្ទុកយ៉ាងច្រើន និងការសម្រេចចិត្តដែលពិបាក។ បើគិតជាភាគរយនៃ ផ.ស.ស. ការចំណាយលើការអប់រំរបស់គ្រួសារកើនឡើងដល់ ០.៣% ក្នុងប្រទេសដែលមានចំណូលខ្ពស់ និង ១% ក្នុងប្រទេសដែលមានចំណូលទាប និងប្រទេសដែលមានចំណូលមធ្យម។ បន្ទុកចំណាយនេះស្មើនឹង ១,២% នៃ ផ.ស.ស. នៅក្នុងប្រទេសអេសាវ៉ាឌ័រ, ១,៥% នៅក្នុងប្រទេសម៉ារ៉ុក, ១,៨% នៅក្នុងឥណ្ឌា និង ២,៥% នៅក្នុងប្រទេសហ្គាណា។ ខណៈពេលដែលគ្រួសារក្រីក្រជាងគេ ២០% មិនស្វែរតែចំណាយអ្វីសោះលើការអប់រំក្នុងប្រទេសអាហ្សង់ទីន កូស្តារីកា ហ្វីលីពីន និងសាំបៀ គ្រួសារដែលមានជីវភាពធូធារជាងគេ ២០% ចំណាយចន្លោះពី ០,៥% និង ១,៧% នៃ ផ.ស.ស.។

ការអប់រំសាធារណៈជារឿយៗមិនមែនផ្តល់ជូនដោយមិនគិតថ្លៃនោះឡើយ។ ចំណាយគ្រួសារប្រមាណ ១ ភាគ ៣ នៅក្នុងប្រទេសចំណូលទាប និងមធ្យមមានប្រភពពីគ្រួសារដែលមានកូនរៀននៅសាលាសាធារណៈ។ គ្រួសារដែលមានកូនរៀននៅសាលាឯកជនចំណាយប្រហែលជា ៨០% នៃចំណាយនៅការអប់រំសរុបក្នុងប្រទេស ហ្គីវតេម៉ាឡា និងប៉ាគីស្ថាន។ គ្រួសារដែលមានកូនរៀននៅសាលាសាធារណៈ ចំណាយប្រមាណស្មើនឹង ៦០% នៃចំណាយក្នុងប្រទេសចិន និង កេនយ៉ា។ នៅតំបន់ជនបទនៃសាធារណៈរដ្ឋតង់ហ្សានៀ គ្រួសារជាង ៣ ភាគ ៤ ចាត់ទុកការបង់វិភាគទាននៅសាលាបឋមសិក្សាថាជាកាតព្វកិច្ច ដោយមានការលើកឡើងថាកុមារអាចទទួលរងទណ្ឌកម្មប្រសិនបើការបង់វិភាគទាននេះ មានភាពយឺតយ៉ាវ។ នៅក្នុងប្រទេសអូស្ត្រាលី ការរួមភាគទានរបស់ឪពុកម្តាយធ្វើឱ្យវិសមភាពរវាងសាលាមួយ និងសាលាមួយទៀតកាន់តែមានការកើនឡើង។

ការបង្រៀនបន្ថែមជាលក្ខណៈឯកជន គឺជាចំណាយមួយដ៏ធំនៅតាមគ្រួសារជាច្រើន។ នៅក្នុងប្រទេសចិន គ្រួសារបែងចែកចំណាយប្រហែលជា ១ ភាគ ៣ នៃចំណាយសរុបសម្រាប់ការអប់រំ លើចំណាយក្រៅសាលារៀនក្នុងឆ្នាំ ២០១៧ ពេលគឺចាប់ពី ១៧% សម្រាប់គ្រួសារជនបទ រហូតដល់ ៤២% សម្រាប់គ្រួសារនៅតំបន់ប្រជុំជន។ នៅក្នុងប្រទេសអេហ្ស៊ីបបើគិតជាភាគរយនៃចំណាយជាមធ្យមក្នុងប្រជាជនម្នាក់ ក្នុងចំណោមសិស្សដែលរៀននៅកម្រិតមធ្យមសិក្សាចំណេះទូទៅ សិស្សដែលមកពីគ្រួសារដែលស្ថិតនៅបញ្ចាភាគដែលមានជីវភាពធូធារជាងគេ ចំណាយ ៥១% លើការបង្រៀនឯកជន ហើយគ្រួសារដែលមានជីវភាពក្រីក្រជាងគេ ចំណាយ ២៩%។ នៅក្នុងប្រទេសមីយ៉ាន់ម៉ា ការបង្រៀនបន្ថែមស្មើនឹង ៤២% នៃចំណាយសរុបលើការអប់រំរបស់គ្រួសារ។

អ្នកផ្តល់សេវាឯកជនពឹងអាស្រ័យលើចំណាយពីហោប៉ៅផ្ទាល់ខ្លួនរបស់គ្រួសារ។ សាលាមធ្យមសិក្សាឯកជនភាគច្រើនទទួលបានចំណូលរបស់ខ្លួនយ៉ាងហោចណាស់ ៨០% ពីថ្លៃសេវា ក្នុងប្រព័ន្ធអប់រំនៅប្រទេសចំណូលមធ្យមកម្រិតខ្ពស់ និងប្រទេសចំណូលខ្ពស់ ២៨ លើ ៥១។ ដោយឡែកនៅក្នុងប្រទេសដែលមានចំណូលទាប និងចំណូលមធ្យមកម្រិតទាបវិញ ឪពុកម្តាយដែលមានជីវភាពក្រីក្រ ប្រើប្រាស់យុទ្ធសាស្ត្រជាច្រើនប្រភេទ ដើម្បីរ៉ាប់រងចំណាយលើសាលាឯកជន។ នៅក្នុងសកលលោកទាំងមូល ក្នុងចំណោមគ្រួសារចំនួន ៦ មានគ្រួសារចំនួន ១ ត្រូវសន្សំប្រាក់ដើម្បីបង់ថ្លៃសាលា។ ខណៈពេលដែលគ្រួសារប្រមាណ ៨% ត្រូវខ្ចីបុលគេ។ នៅក្នុងប្រទេសហៃទី កេនយ៉ា ហ្វីលីពីន និងអ៊ូហ្គង់ដា គ្រួសារចាប់ពី ៣០% ឡើងទៅត្រូវខ្ចីបុល ដើម្បីរ៉ាប់រងលើថ្លៃសាលារៀន។

ការផ្តល់ថវិកាគាំទ្រដល់សាលារៀនឯកជន រងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារជំងឺកូវីដ ១៩។ ការរាតត្បាតជាសកលបានបង្កការផលប៉ះពាល់ដល់សាលាឯកជន ជាពិសេសសាលាដែលពឹងអាស្រ័យលើការប្រមូលថ្លៃសេវា។ ប្រទេសនីហ្សេរីយ៉ាបានដាក់ឱ្យអនុវត្តនូវកញ្ចប់ថវិកាសង្គ្រោះមួយ តាមរយៈការផ្តល់កម្ចីដែលមានអត្រាការប្រាក់ទាប ដើម្បីរ៉ាប់រងលើចំណាយរបស់គ្រូនៅសាលាឯកជន។ នៅក្នុងប្រទេសហ្គាណា សាលាឯកជនបានទទួលការគាំទ្រជាផ្នែកមួយនៃកម្មវិធីទូទៅសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម។ ប្រទេសវៀតណាមបានពង្រីកកម្មវិធីឧបត្ថម្ភសាច់ប្រាក់ ដើម្បីរ៉ាប់រងចំណាយលើគ្រូបង្រៀននៅតាមសាលាឯកជន។ នៅក្នុងប្រទេសប៉ាណាម៉ា មាតាបិតាពី ៣៥% ទៅ ៤០% ពុំមានលទ្ធភាពបង់ថ្លៃសេវាប្រចាំខែនោះឡើយ។ ក្នុងប្រទេសអេហ្វាឌ័រការចុះឈ្មោះចូលរៀននៅតាមសាលាឯកជនកើនឡើង ៦,៥% ឬមានសិស្សចំនួន ១២០.០០០ នាក់ដែលជាអ្នកប្តូរចេញពីសាលាឯកជន។

ការប្រើប្រាស់ថវិកាជំនួយសម្រាប់ផ្តល់ហិរញ្ញប្បទានដល់ការអប់រំឯកជនត្រូវបានលើកយកមកជជែកវែកញែក។ ក្នុងចំណោមថវិកាអប់រំដែលស្មើនឹងជិត ១,២ ៣ន់លានដុល្លារសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិវិភាជន៍ន៍ថវិកា ១៥% ទៅឱ្យសាលាឯកជនដែលមានសាខាច្រើន ប៉ុន្តែបង្កកការវិនិយោគរបស់ខ្លួនលើសាលាឯកជនដែលគិតថ្លៃសេវាកាលពីឆ្នាំ ២០១៩ ក្រោយពីរងសម្ពាធពីអង្គការសង្គមស៊ីវិល។ ភាពជាដៃគូសកលសម្រាប់ការអប់រំបានរៀបចំយុទ្ធសាស្ត្រមួយសម្រាប់វិស័យឯកជន ប៉ុន្តែការជំទាស់ទៅនឹងយុទ្ធសាស្ត្រនេះក្នុងអំឡុងពេលចរចារនាំឱ្យមានការបញ្ចូលខចែងដែលហាមប្រាមមិនឱ្យមានការប្រើប្រាស់មូលនិធិរបស់ស្ថាប័ននេះ ដើម្បីគាំទ្រដល់ការផ្តល់សេវាអប់រំដែលជាសេវាសួល ដើម្បីគោលបំណងរកប្រាក់ចំណេញ។

អ្នកផ្តល់ជំនួយកំពុងឯកស្រង់បទពិសោធន៍ជាមួយនឹងភាពជាដៃគូរវាងរដ្ឋ និងឯកជន។ រដ្ឋាភិបាលដែលជួបការលំបាកជាមួយនឹងសាច់ប្រាក់បានរៃអង្គាសមូលធនពីវិស័យឯកជន ដើម្បីកែលម្អ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធសាធារណៈនៅក្នុងប្រទេសអេហ្ស៊ីប ហ្វីលីពីន និងអាហ្វ្រិកខាងត្បូង។ អ្នកផ្តល់ជំនួយមួយចំនួនបានរិះរកវិធីប្រើប្រាស់មូលនិធិរបស់ខ្លួនជាមូលនិធិកត្តាលីករ ដើម្បីរាយអង្គាសថវិកាតាមរយៈភាពជាដៃគូបែបនេះ។ ប៉ុន្តែមានការបារម្ភខ្លាចក្រែងរដ្ឋាភិបាលដែលមានលទ្ធភាពអាចរៀបចំអនុវត្ត និងធ្វើបញ្ញត្តិកម្មលើភាពជាដៃគូដែលអាចធ្វើបានល្អជាងក្នុងការប្រើប្រាស់កិច្ចលទ្ធកម្មសាធារណៈ ដើម្បីសម្រេចគោលដៅរបស់ខ្លួន។

ការរួមចំណែកជាថវិកាពីសប្បុរសជន និងក្រុមហ៊ុនឯកជនក្នុងសកម្មភាពអប់រំនៅមានកម្រិតតិចតួច។ បើទោះជាមានការយល់ឃើញថាចំនួនទឹកប្រាក់ដែលមូលនិធិសប្បុរជនចំណាយលើសកម្មភាពមានការកើនឡើងក៏ដោយចំនួននេះនៅមានតិចតួចប៉ុណ្ណោះ។ ការវិភាគក្នុង

លក្ខណៈជាប្រព័ន្ធលើការបរិច្ចាគពីមូលនិធិសប្បុរសជនចំនួន ១៤៣ ក្នុងបណ្តាញមូលនិធិដែលធ្វើការងារដើម្បីកិច្ចអភិវឌ្ឍន៍ដែលជាគំនិតផ្តួចផ្តើមមួយរបស់អង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD) ប៉ាន់ប្រមាណថា សកម្មភាពអប់រំបានទទួលថវិកា ២,១ ពាន់លានដុល្លារក្នុងរយៈពេល ៣ ឆ្នាំចាប់ពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៥។ នេះស្មើនឹង ៩% នៃការបរិច្ចាគសរុបសប្បុរសជន។

ឥទ្ធិពល

ទម្លាប់ការណ៍ពាក់ព័ន្ធនឹងប្រសិទ្ធភាព នវានុវត្តន៍ និងសមធម៌ គឺជាចំណុចស្នូលនៃការជជែកវែកញែកអំពីតួនាទីរបស់តួអង្គមិនមែនរដ្ឋក្នុងវិស័យអប់រំ។ ជារឿយៗការជជែកវែកញែកទាំងនេះ គឺពោរពេញទៅដោយភាពល្វីងជូចត់ និងការមិនជឿទុកចិត្តគ្នា ព្រោះថាវាជាការប៉ះទង្គិចរវាងការយល់ឃើញខុសគ្នាស្រឡះចំនួន ២ របស់ពិភពលោក។ ក្រុមតួអង្គពាក់ព័ន្ធនានាព្យាយាមមានឥទ្ធិពលលើការយល់ឃើញជាសាធារណៈ និងគោលនយោបាយអប់រំ ដែលគាំទ្រ ឬប្រឆាំងនឹងការផ្តល់តួនាទីបន្ថែមដល់តួអង្គមិនមែនរដ្ឋ។ ឧបករណ៍ដែលតួអង្គទាំងនេះប្រើប្រាស់រួមមានបណ្តាញតស៊ូមតិ និងបញ្ចុះបញ្ចូល ការស្រាវជ្រាវ និងមូលនិធិគាំទ្រដែលជារឿយៗត្រូវបានផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹងការលក់ទំនិញ និងសេវាកម្ម។ ក្នុងការប្រកួតប្រជែងគំនិតនយោបាយ និងផលប្រយោជន៍សេដ្ឋកិច្ចបែបនេះ ដែលក្នុងនោះតួអង្គពាក់ព័ន្ធប្រើប្រាស់ទាំងមធ្យោបាយស្របច្បាប់ និងមធ្យោបាយមិនស្របច្បាប់ ដើម្បីបង្ហាញពីការយល់ឃើញរបស់ខ្លួន បញ្ហាប្រឈម គឺនៅត្រង់ថាគេត្រូវបន្តរក្សាតម្លាភាព និងសុចរិតភាពនៃដំណើរការរៀបចំគោលនយោបាយអប់រំសាធារណៈ និងបញ្ចៀសមិនឱ្យមានការជាប់ពាក់ព័ន្ធនឹងផលប្រយោជន៍របស់បុគ្គល។

ក្រុមតួអង្គភាគច្រើនពុំមានគោលជំហរដូចគ្នា ជុំវិញតួនាទីរបស់អ្នកផ្តល់សេវាមិនមែនរដ្ឋក្នុងការងារអប់រំនោះឡើយ។ អង្គការសង្គមស៊ីវិលជារឿយៗតែងសំដែងការរិះគន់ ដោយលើកឡើងពីក្តីបារម្ភជុំវិញការធ្វើឯកជនភាវូបនីយកម្ម និងការចាត់ទុកការអប់រំថាជាទំនិញ និងលើកឡើងថា ការអប់រំត្រូវតែបន្តស្ថិតនៅក្រោមការគ្រប់គ្រងបែបប្រជាធិបតេយ្យ។ ទោះជាយ៉ាងនេះក្តី សូម្បីតែនៅក្នុងក្របខ័ណ្ឌនៃចលនាដែលឈរលើគោលការណ៍សិទ្ធិ ដូចជា យុទ្ធនាការអប់រំសកលដើម សមាជិកនៅតែមានការយល់ឃើញខុសៗគ្នា ទៅតាមស្ថានភាពនៃប្រទេសរៀងៗខ្លួនរបស់ពួកគេ។ ក្នុងការអង្កេតជាមួយសមាជិក ដែលធ្វើឡើងសម្រាប់រៀបចំរបាយការណ៍នេះ ៤៣% បានលើកឡើងពីការយល់ឃើញបែបអវិជ្ជមាន ចំពោះការផ្តល់សេវាមិនរកប្រាក់ចំណេញ ប៉ុន្តែ ១២% ផ្តល់ការគាំទ្រសម្រាប់ភាពជាដៃគូរវាងរដ្ឋ និងឯកជន ជាមួយនឹងភាគរយ ៤១% និង២០% ហើយអ្នកដែលនៅសេសសល់ លើកឡើងពីការយល់ឃើញចម្រុះ។

បណ្តាញតស៊ូមតិសកលបានចាត់ទុកការធ្វើឯកជនភាវូបនីយកម្ម និងការធ្វើពាណិជ្ជភាវូបនីយកម្ម ថាជាការគំរាមកំហែងចំពោះសិទ្ធិទទួលបានការអប់រំ។ ទស្សនយល់ឃើញបែបនេះ ត្រូវបានលើកឡើងនៅក្នុងគោលការណ៍ Abidjan ស្តីពីភាតព្វកិច្ចសិទ្ធិមនុស្សរបស់រដ្ឋក្នុងការផ្តល់ការអប់រំជាសាធារណៈ និងធ្វើនិយ័តកម្មលើការចូលរួមរបស់វិស័យឯកជនក្នុងសកម្មភាពអប់រំ។ ក្នុងឆ្នាំ ២០១៨ ពលរដ្ឋកេនយ៉ាចំនួន ១០ នាក់ បានដាក់ពាក្យបណ្តឹងទៅកាន់ការិយាល័យពលរដ្ឋ ដែលទទួលបន្ទុកផ្តល់ដំបូន្មានអំពីភាពអនុលោមតាមច្បាប់ ដែលជាយន្តការគណនេយ្យភាពឯករាជ្យសម្រាប់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ដែលចោទប្រកាន់ថាក្រុមហ៊ុន Bridge International Academies ដែលជាសាលាមានច្រើនសាខា បង្កើនឡើង ដើម្បីគោលបំណងរកប្រាក់ចំណេញ កំពុងបំពានស្តង់ដារកម្មវិធីសិក្សា សុខភាព សុវត្ថិភាព និងស្តង់ដារការងារ។ ក្នុងឆ្នាំ ២០២០ IFC បានបង្កការវិនិយោគលើសាលារៀនដែលមានច្រើនសាខា ខណៈពេលដែលក្រុមវាយតម្លៃឯករាជ្យរបស់ធនាគារពិភពលោក បានប្រកាសធ្វើការវាយតម្លៃលើការវិនិយោគក្នុងសាលាឯកជន។

ការគាំទ្រមិនសំខាន់ និងធនធានដែលបានពីអង្គការអន្តរជាតិជាច្រើនសម្រាប់អ្នកផ្តល់សេវាមិនមែនរដ្ឋមានឥទ្ធិពលលើរបៀបវារៈនានា។ ក្នុងចំណោមវិធីសាស្ត្រដែលធនាគារពិភពលោកប្រើប្រាស់ ដើម្បីមានឥទ្ធិពលលើការធ្វើគោលនយោបាយ គឺការប្រើប្រាស់ម៉ូឌុលមួយស្តីពីការចូលរួមសហការជាមួយវិស័យឯកជន ដែលត្រូវបានចាត់ទុកថាជាផ្នែកគោលនយោបាយមួយក្នុងចំណោមផ្នែកគោលនយោបាយសំខាន់ៗជាងគេចំនួន ១៣ ដើម្បីលើកកម្ពស់ការសិក្សារៀនសូត្រ ក្រោមក្របខ័ណ្ឌអភិក្រមជាប្រព័ន្ធ ដើម្បីលើកកម្ពស់លទ្ធផលអប់រំឱ្យកាន់តែប្រសើរ។ ធនាគារពិភពលោកបានផ្តល់អនុសាសន៍ឱ្យមានការពង្រីកការផ្តល់សេវាពីវិស័យឯកជនក្នុងចំណោមប្រទេស ៩ លើ ១០។ មូលនិធិលទ្ធផលនៃការអប់រំដែលទទួលរៀបចំដោយយូនីសេហ្វទាក់ទាញវិនិយោគិន មកចូលរួមក្នុងគម្រោងផ្តល់ហិរញ្ញប្បទានផ្អែកលើលទ្ធផល បើទោះជាវិនិយោគិនទាំងនេះមិនមានបទពិសោធន៍ច្រើន ក្នុងគម្រោងអប់រំក៏ដោយ។ អង្គការនានាដែលបានទទួលប្រយោជន៍ពីការគាំទ្រពីអន្តរជាតិរួមមាន Ark ដែលបានពង្រីកខ្លួនពីប្រតិបត្តិការសាលាសាធារណៈក្នុងប្រទេសអង់គ្លេស (ចក្រភពអង់គ្លេស) ទៅជាអង្គការដែលផ្តល់ជំបូន្មាន និងជួយអនុវត្តភាពជាដៃគូដ្ឋ និងឯកជនតាមប្រទេសនានា ដូចជា លីបេរីយ៉ា និងអាហ្វ្រិកខាងត្បូងជាដើម។

មូលនិធិនានា មានគោលជំហរផ្សេងគ្នាជុំវិញតួនាទីដែលពួកគេគិតថា តួអង្គមិនមែនរដ្ឋគួរបំពេញនៅក្នុងការងារអប់រំ។ កត្តាលើកទឹកចិត្តផ្សេងៗគ្នារបស់មូលនិធិសាជីវកម្ម និងមូលនិធិសប្បុរសជន ធ្វើឱ្យគេពិបាកនឹងចាត់ថ្នាក់មូលនិធិទាំងនេះថាស្ថិតនៅក្នុងក្រុមតែមួយ។ ជារឿយៗមូលនិធិនានាទទួលរងការរិះគន់ថាព្យាយាមមានឥទ្ធិពលលើគោលនយោបាយក្នុងទិសដៅណាមួយ។ មូលនិធិ Lemann Foundation ដែលជាមូលនិធិសប្បុរសធម៌បានជួយដាក់ឱ្យអនុវត្តនូវស្តង់ដារសិក្សាថ្នាក់ជាតិនៅក្នុងប្រទេសប្រេស៊ីល ក្រោយពីបានរៀបចំកិច្ចពិគ្រោះយោបល់ជាច្រើនលើកជាច្រើនសារួចមក។

សហជីពគ្រូបង្រៀនតែងឈរនៅមុខគេក្នុងកិច្ចខិតខំប្រឹងប្រែងតស៊ូមតិ ដើម្បីគាំទ្រដល់ការអប់រំសាធារណៈ។ សហជីពបានខិតខំបង្ហាញឱ្យគេឃើញពីកិច្ចខិតខំប្រឹងប្រែងធ្វើឱ្យអន្តរាយដល់ការអប់រំសាធារណៈតាមរយៈពាណិជ្ជភាវូបនីយកម្ម ដែលពុំមានការធានាត្រឹមត្រូវ និងការជួលឱ្យស្ថាប័នឯកជនផ្តល់សេវាសាធារណៈ។ អង្គការ Education International ដែលជាសហព័ន្ធសហជីពគ្រូបង្រៀនបានសាកសួរថាតើការប្រើប្រាស់ភាពជាដៃគូរវាងរដ្ឋ និងឯកជនយ៉ាងទូលំទូលាយនៅក្នុងអាមេរិកឡាទីន ឧទាហរណ៍នៅកូស្តារីកា និងសាធារណៈរដ្ឋដូមីនីកជាដើម នាំឱ្យអន្តរាយដល់គ្រឹះស្ថានសាធារណៈដែលផ្តល់សេវាដូចគ្នានេះដែរឬទេ។ ប៉ុន្តែនៅក្នុង

ឱកាសមួយចំនួន តាក់ទិចដែលសហជីពប្រើប្រាស់បានទទួលការរិះគន់ថា ធ្វើអន្តរាយដល់កិច្ចខិតខំប្រឹងប្រែងពង្រឹងការអប់រំសាធារណៈទៅវិញ។

ធុរកិច្ចនានា ប្រើប្រាស់ទម្លាប់ការណ៍មូលធនមនុស្សក្នុងការតស៊ូមតិដើម្បីឱ្យមានការកែទម្រង់វិស័យអប់រំ។ សហព័ន្ធធុរកិច្ចដ៏ប៉ុនដូចគ្នានឹងស្ថាប័នបញ្ចុះបញ្ចូល ដើម្បីគោលបំណងសេដ្ឋកិច្ចដ៏មានឥទ្ធិពលផ្សេងទៀតនៅជុំវិញពិភពលោក បានចេញអនុសាសន៍គោលនយោបាយអប់រំដែលអំពាវនាវឱ្យមានការធ្វើទំនើបកម្ម និងការបណ្តុះបណ្តាលជំនាញសតវត្សរ៍ទី ២១។ ក្រុមមួយចំនួនបានរិះគន់អនុសាសន៍នេះ ថាផ្ទុយគ្នាទៅនឹងរបៀបជួល និងបណ្តុះបណ្តាលបុគ្គលិករបស់និយោជក។ សម្ព័ន្ធធុរកិច្ចសកលសម្រាប់ការអប់រំបានអំពាវនាវឱ្យមានការប្រើប្រាស់ជំនាញឯកទេស ភាពជាអ្នកដឹកនាំ និងធនធាននៃសមាជិករបស់ខ្លួន ដើម្បីឱ្យបញ្ហាអប់រំក្លាយជាបញ្ហាដែលលេចធ្លោក្នុងរបៀបវារៈនយោបាយ។ អ្នករិះគន់តបវិញថា ការគាំទ្រដែលល្អបំផុតសម្រាប់ការអប់រំសាធារណៈគឺត្រូវចូលរួមពិតប្រាកដក្នុងយុទ្ធនាការប្រឆាំងនឹងការចៀសវាង និងគេចវេះពីការបង់ពន្ធ។ កន្លងមកមានការលើកឡើងពីក្តីបារម្ភជុំវិញវិធីសាស្ត្រដែលក្រុមហ៊ុនបច្ចេកវិទ្យាអប់រំ ដែលប្រើប្រាស់បច្ចេកទេសម៉ាយក្រូធីង ដើម្បីលើកផលិតផលឱ្យរដ្ឋាភិបាលតាមបែបដែលមិនស្របតាមបុព្វហេតុសាធារណៈ បានពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងអំឡុងពេលនៃវិបត្តិកូវីដ ១៩ និងងាកទៅប្រើប្រាស់ការរៀនសូត្រពីចម្ងាយ។

ការគាំពារ និងអប់រំកុមារតូច

តួអង្គមិនមែនរដ្ឋ អ្នកដឹកនាំការផ្តល់សេវា គាំពារ និងអប់រំកុមារអាយុក្រោម ៣ ឆ្នាំ។ នៅក្នុងប្រទេសដែលមានចំណូលខ្ពស់ចំនួន ៣៣ ការចុះឈ្មោះចូលរៀននៅតាមគ្រឹះស្ថានឯកជនស្មើនឹង ៥៧%នៃការចុះឈ្មោះចូលរៀនសរុបក្នុងឆ្នាំ ២០១៨។ នៅក្នុងប្រទេសអូស្ត្រាលី អៀឡង់ ហូឡង់ ញូសេលែន និងចក្រភពអង់គ្លេស វិស័យឯកជនដែលរកប្រាក់ចំណេញជាអ្នកទទួលខុសត្រូវចម្បងលើការផ្តល់សេវាអប់រំនៅកម្រិតនេះ។ ក្នុងប្រទេសអាឡឺម៉ង់ កាលពីឆ្នាំ ២០១៧ ការចុះឈ្មោះចូលរៀននៅតាមគ្រឹះស្ថានឯកជនស្មើនឹង ៧៣% ប៉ុន្តែមានអ្នកផ្តល់សេវាតែ ៣% ប៉ុណ្ណោះដែលរកប្រាក់ចំណេញ។ ក្នុងប្រទេសចំណូលមធ្យមចំនួន ៣៣ ការចុះឈ្មោះចូលរៀនកុមារក្រោម ៣ ឆ្នាំនៅតាមគ្រឹះស្ថានរបស់តួអង្គមិនមែនរដ្ឋមាន ៤៦% ពោលគឺចាប់ពីស្ទើរតែជិតសូន្យក្នុងសហព័ន្ធរុស្ស៊ី ដល់ ១០០% ក្នុងប្រទេសតួកគី។ មានតែប្រទេសមួយចំនួនតូចតែប៉ុណ្ណោះនៅក្នុងនោះរាប់បញ្ចូលទាំងប្រទេសអេសវ៉ាឌ័រផង បានងាកទៅពង្រីកការផ្តល់សេវាដោយរដ្ឋ។ បណ្តាប្រទេសនៅអាមេរិកឡាទីន ដូចជាកូឡុំបៀ កូតេម៉ាឡា ប៉េរូជាដើមបានអនុវត្តកម្មវិធីគាំពារកុមារជាទ្រង់ទ្រាយតូចតាមសហគមន៍។ ការផ្តល់សេវាពីនិយោជក ដែលមានជាទូទៅនៅតាមប្រទេសដែលមានជីវភាពធូធារ គឺទើបតែលេចចេញជាបណ្តើរៗប៉ុណ្ណោះនៅតាមប្រទេសក្រីក្រ។ បញ្ហាប្រឈមដ៏សំខាន់មួយ គឺការងារក្នុងវិស័យក្នុងប្រព័ន្ធស្មើត្រឹមតែ ៣០% នៃចំនួនការងារក្នុងប្រទេសដែលមានចំណូលទាប និងប្រទេសដែលមានចំណូលមធ្យមប៉ុណ្ណោះ។

តួអង្គមិនមែនរដ្ឋមានភាពលេចធ្លោជាងក្នុងការផ្តល់សេវាអប់រំនៅកម្រិតមត្តេយ្យសិក្សា បើធៀបនឹងការអប់រំកម្រិតមូលដ្ឋាន។ ចន្លោះពីឆ្នាំ ២០០០ ដល់ឆ្នាំ ២០១៩ ភាគរយនៃគ្រឹះស្ថានអប់រំនៃការចុះឈ្មោះចូលរៀនសរុប នៅកម្រិតអប់រំមត្តេយ្យសិក្សាកើនឡើងពី ២៨,៥% ដល់ ៣៧%, ឡើងដល់រហូត ៥៥% នៅអាស៊ីភាគខាងកើត និងអាស៊ីអាគ្នេយ៍។ នៅប្រទេសចិនក្រោមគោលនយោបាយ "ដើរលើជើងពីរ" គ្រឹះស្ថានឯកជនកើនឡើងពី ៣១% ដល់ ៥៧%។ ក្នុងប្រទេសវៀតណាមភាគរយនៃការចុះឈ្មោះចូលរៀននៅតាមគ្រឹះស្ថានឯកជនថយចុះពី ៦០% ក្នុងឆ្នាំ ២០០៣ មក ១២% ក្នុងឆ្នាំ ២០១៤។ ភាគរយមានចាប់ពីក្រោម ១% ក្នុងប្រទេសនៅអឺរ៉ុបភាគខាងកើតដូចជាប្រទេសអ៊ុយក្រែជាដើមរហូតដល់ជាង ៩៥% ក្នុងតំបន់ការីបៀន (ឧទាហរណ៍ អាទីគ័រ និងបាបូដា) និងតំបន់ប៉ាស៊ីហ្វិកដែលការប្រើសេវាអប់រំច្រើនតែធ្វើនៅតាមសហគមន៍ (ឧទាហរណ៍ នៅវ៉ានូទូ) ឬមានទំនាក់ទំនងជាមួយនឹងបេសកកម្មសាសនា (ឧទាហរណ៍ ហ្វាម៉ាវ)។ អាហ្វ្រិកភាគខាងជើង និងអាស៊ីភាគខាងលិច នាំមុខដោយប្រទេសអាល់ហ្សេរី និងអេហ្ស៊ីប គឺជាតំបន់ដែលមានការថយចុះភាគរយនៃការចុះឈ្មោះចូលរៀននៅតាមគ្រឹះស្ថានឯកជននៅកម្រិតមត្តេយ្យសិក្សាធំជាងគេ ពី ៥៣% ក្នុងឆ្នាំ ២០០០ មក ៣៦% ក្នុងឆ្នាំ ២០១៩។ ផ្ទុយទៅវិញចន្លោះពីឆ្នាំ ២០០០ ដល់ឆ្នាំ ២០១៨ ភាគរយនៃគ្រឹះស្ថានឯកជនមានការកើនឡើងនៅក្នុងប្រទេសអ៊ីស្រាអែលពី ៥% ដល់ ៣៦% និងពី ២៦% ដល់ ៤៥% នៅក្នុងប្រទេសគុយវ៉ែត។

ការចំណាយលើការផ្តល់សេវាអប់រំនៅកម្រិតមត្តេយ្យសិក្សា ដោយអ្នកផ្តល់សេវាមិនមែនរដ្ឋអាចខ្ពស់ពេកសម្រាប់គ្រួសារដែលក្រីក្របំផុត។ ការអង្កេតតាមខ្នងផ្ទះបង្ហាញថាទិន្នន័យរដ្ឋបាលបង្ហាញមិនដល់កម្រិតជាក់ស្តែងពីភាគរយនៃការចុះឈ្មោះចូលរៀននៅតាមគ្រឹះស្ថានមិនមែនរដ្ឋក្នុងប្រទេស ៦ លើ ៧ នៅអាហ្វ្រិកសាប់សាហារ៉ា ពោលគឺគិតជាមធ្យមតិចជាងតួលេខជាក់ស្តែងប្រមាណ ២០ ភាគរយចំណុច។ ការផ្តល់សេវាដោយតួអង្គមិនមែនរដ្ឋបានឆ្លើយតបចំពោះតម្រូវការនៅតំបន់ប្រជុំជនដែលសេវាបែបនេះច្រើនតែអាចរកបានជាទូទៅ និងជាសេវាដែលប្រើប្រាស់ដោយគ្រួសារដែលមានជីវភាពធូធារដែលមានលទ្ធភាពបង់ថ្លៃសេវា។ គិតជាភាគរយនៃការប្រើប្រាស់ប្រចាំឆ្នាំរបស់គ្រួសារ ការអប់រំកម្រិតមត្តេយ្យសិក្សានៅតាមគ្រឹះស្ថានឯកជន ស្មើនឹង ៦% សម្រាប់គ្រួសារដែលមានជីវភាពធូធារជាងគេ និង ១៧% សម្រាប់គ្រួសារដែលមានជីវភាពក្រីក្រជាងគេនៅហ្គាណា ដោយឡែកតួលេខនៅក្នុងប្រទេសអេត្យូពីវិញ គឺ ៤% សម្រាប់គ្រួសារដែលមានជីវភាពធូធារជាងគេ និង ២១% សម្រាប់គ្រួសារដែលមានជីវភាពក្រីក្រជាងគេ។

ការផ្តល់សេវាដោយតួអង្គមិនមែនរដ្ឋ បង្កការលំបាកដល់អភិបាលកិច្ច និងនិយ័តកម្ម។ ភាពចម្រុះនៃតួអង្គមិនមែនរដ្ឋធ្វើឱ្យការគ្រប់គ្រងមានភាពស្មុគស្មាញ។ ប្រទេសកម្ពុជាមានលិខិតបទដ្ឋានគតិយុត្ត ដាច់ដោយឡែកសម្រាប់សាលាមត្តេយ្យសិក្សាសហគមន៍។ នៅក្នុងប្រទេសស្រីលង្កាការពុំមានក្របខ័ណ្ឌគតិយុត្ត ដែលមានលក្ខណៈពហុវិស័យ មានន័យថាវិសាលភាពការងាររបស់ក្រសួងជាច្រើន (អប់រំ សុខាភិបាល កិច្ចការនារី និងកិច្ចការកុមារ) និងក្រុមប្រឹក្សាខេត្តមានភាពត្រួតគ្នា។ នៅរដ្ឋឡាហ្គោសប្រទេសនីហ្សេរីយ៉ា លទ្ធភាពដែលក្រសួងអប់រំរដ្ឋចុះធ្វើអធិការកិច្ចសាលាឯកជនមានកម្រិតខ្ពស់ជាងប្រសិនបើសាលារៀនទាំងនោះគិតថ្លៃសេវាខ្ពស់ (៦៨%) បើធៀបនឹងករណីដែលសាលារៀនទាំងនោះគិតថ្លៃសេវាទាប (៤៨%)។ នៅទីក្រុងណៃរ៉ូប៊ី ប្រទេសកេនយ៉ា សាលាសហគមន៍ត្រូវបានធ្វើអធិការកិច្ចញឹកញាប់ជាងសាលាសាសនា សាលានៃមូលនិធិសប្បុរសធម៌ ឬសាលារៀនដែលមិនរកប្រាក់ចំណេញ។

គុណភាពរបស់អ្នកផ្តល់សេវាអប់រំមិនមែនរដ្ឋ មានការប្រែប្រួលខុសៗគ្នាខ្លាំង។ នៅតាមប្រទេសដែលមានចំណូលទាប និងចំណូលមធ្យមជាច្រើន អ្នកផ្តល់សេវាអប់រំឯកជន មិនសូវជាបានត្រៀមរៀបចំខ្លួន និងមានឱកាសអភិវឌ្ឍន៍វិជ្ជាជីវៈតិចជាងអ្នកអប់រំនៅក្នុងវិស័យសាធារណៈ។ មានគ្រូបង្រៀនសាលាមត្តេយ្យឯកជនត្រឹមតែ ៨% ប៉ុន្តែគ្រូបង្រៀនសាលាមត្តេយ្យរដ្ឋដល់ទៅ ៧៥% ដែលបានចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលដែលផ្តល់ដោយសេវាអប់រំហ្គាណា ព្រោះថាពុំមានការកំណត់លក្ខខណ្ឌអប្បរមាសម្រាប់គ្រូបង្រៀនឯកជននោះឡើយ។ ការប្រើប្រាស់ភាសាអង់គ្លេសជាភាសាបង្រៀននៅតាមសាលាមត្តេយ្យមិនមែនរដ្ឋ ដូចជានៅក្នុងប្រទេសប្រេស៊ីលជាដើម គឺជាឧទាហរណ៍ដែលបង្ហាញពីភាពតានតឹងរវាងកម្មវិធីសិក្សាសមស្របទៅតាមកម្រិតនៃការអភិវឌ្ឍ និងការយល់ឃើញរបស់ប្រជាជនទូទៅអំពីគុណភាព។

ប្រទេសដែលមានចំណូលទាប និងចំណូលមធ្យមមួយចំនួនតូចមាននីតិវិធីធានាគុណភាពផ្សេងក្រៅតែពីលក្ខខណ្ឌផ្នែករដ្ឋបាល។ នៅក្នុងប្រទេសចាម៉ៃកាដែលការផ្តល់សេវាអប់រំធ្វើឡើងភាគច្រើនដោយតួអង្គមិនមែនរដ្ឋ ក្រសួងអប់រំតម្រូវឱ្យអធិការ ឬបុគ្គលិកដែលមានសមត្ថភាពផ្សេងទៀតចុះតាមដានដល់ទីតាំងផ្ទាល់ជារៀងរាល់ខែ ដោយប្រើប្រាស់ស្តង់ដារជាតិចំនួន ១២ ដោយមានការបញ្ចូលការពិនិត្យលើអន្តរកម្ម និងទំនាក់ទំនងរវាងកុមារ គ្រូ មាតាបិតា អ្នកផ្តល់ការថែទាំ និងសមាជិកសហគមន៍។ ប្រទេសហ្វីលីពីនពិនិត្យតាមដានស្តង់ដារជាតិ និងសមត្ថភាពតាមរយៈបញ្ជីត្រួតពិនិត្យអភិវឌ្ឍន៍កុមារតូចរបស់ហ្វីលីពីនដែលមានការបញ្ចាក់ផ្ទៀងផ្ទាត់ពីរដ្ឋាភិបាល។

តួអង្គមិនមែនរដ្ឋមានគំនិតនវានុវត្តន៍ និងស្វែងរកការគាំទ្រសម្រាប់សេវាគាំពារ និងអប់រំកុមារតូច។ កន្លងមក សកម្មជនអប់រំ ដែលមានការប្តេជ្ញាចិត្ត ហើយដែលធ្វើការនៅខាងក្រៅ ឬនៅកៀកនឹងប្រព័ន្ធអប់រំក្នុងប្រព័ន្ធរបស់រដ្ឋ ដើម្បីសម្រេចបក្ខវិស័យរបស់ពួកគេនោះគឺជំរុញឱ្យមានការសិក្សាបែបកុមារមជ្ឈមណ្ឌល។ អ្នកសិក្សាស្រាវជ្រាវពីស្ថាប័នសិក្សាស្រាវជ្រាវបានទាញចំណាប់អារម្មណ៍ចំពោះប្រសិទ្ធភាពរយៈពេលវែងនៃកម្មវិធីអប់រំកុមារតូច ដោយលើកទឹកចិត្តឱ្យសាធារណៈជនទូទៅធ្វើការពង្រីកវិសាលភាពកម្មវិធីទាំងនេះ។ តួអង្គមិនមែនរដ្ឋតស៊ូមតិ ដើម្បីបុព្វហេតុកុមារដែលត្រូវបានគេផ្តាត់ចេញ ដោយបានធ្វើការងារជាមួយនឹងម្តាយ ដែលកំពុងជាប់ពន្ធនាគារនៅក្នុងប្រទេសឈីលីឪពុកម្តាយដែលមានជីវភាពក្រីក្រនិងកំពុងធ្វើការនៅក្នុងប្រទេសហ្វីលីពីន និងកុមារដែលស្ថិតនៅតាមមណ្ឌលថែទាំកុមារនៅក្នុងប្រទេសរ៉ូមីនៀ។ អង្គការនានា ដូចជាមូលនិធិ Bernard van Leer Foundation មូលនិធិ Aga Khan Foundation និងមូលនិធិ Open Society Foundations បានកៀរគរការគាំទ្រ និងធ្វើការតស៊ូមតិដើម្បីបុព្វហេតុនៃការគាំពារ និងអប់រំកុមារតូច។

ការអប់រំនៅកម្រិតឧត្តមសិក្សា

ប្រទេសស្ទើរតែទាំងអស់ខិតខំធានាឱ្យមានការផ្តល់សេវាអប់រំនៅកម្រិតឧត្តមសិក្សាតាមរយៈការផ្តួបកម្លាំងគ្នារវាងតួអង្គរដ្ឋ និងតួអង្គមិនមែនរដ្ឋ។ និស្សិតឧត្តមសិក្សាប្រមាណ ៣៣% ចុះឈ្មោះចូលរៀននៅតាមគ្រឹះស្ថានឯកជន នៅក្នុងសកលលោក ដោយភាគរយខ្ពស់ជាងគេ គឺនៅអាស៊ីកណ្តាល និងអាស៊ីខាងត្បូង អាមេរិកឡាទីន និងហ្គារីបៀន។ ការកើនឡើងនៃការផ្តល់សេវាដោយតួអង្គមិនមែនរដ្ឋ បានឆ្លើយតបទៅនឹងតម្រូវការផ្សេងៗគ្នា។ គ្រឹះស្ថានដែលធ្វើការងារផ្តោតលើសាសនា ឬវប្បធម៌មានទំនាក់ទំនងជាមួយនឹងប្រវត្តិសាស្ត្រ និងប្រពៃណី និងជួយបំពេញតម្រូវការអប់រំ 'បែបផ្សេង'។ គ្រឹះស្ថាន Elite ត្រូវបានបង្កើតឡើង ដើម្បីឆ្លើយតបចំពោះតម្រូវការចង់បានការអប់រំ 'ដែលកាន់តែប្រសើរ' ដែលជារឿយៗជាតម្រូវការរបស់គ្រួសារដែលមានជីវភាពធូរធារ។ ចុងក្រោយគ្រឹះស្ថានតូចៗ ដែលមិនសូវលេចធ្លោកាលពីពេលថ្មីៗនេះ ចាប់ផ្តើមមានវត្តមានជាការឆ្លើយតបទៅនឹងតម្រូវការអប់រំឧត្តមសិក្សា 'កាន់តែច្រើនជាងមុន' ជាពិសេសនៅក្នុងបរិបទដែលរដ្ឋមានថវិកាតិចតួច។

គ្រឹះស្ថានមិនមែនរដ្ឋមានភាពពាក់ព័ន្ធ និងគុណភាពរបស់ប្រព័ន្ធ។ គ្រឹះស្ថានតូចៗដែលគិតថ្លៃសេវា ច្រើនតែផ្តល់ការសិក្សាមុខជំនាញតិចតួច ប៉ុណ្ណោះ ភាគច្រើនផ្តោតលើការបណ្តុះបណ្តាលវិជ្ជាជីវៈ។ នៅក្នុងប្រទេសឥណ្ឌាមហាវិទ្យាល័យឯកជនប្រមាណ ៤0% ផ្តល់សេវាអប់រំតែមួយជំនាញប៉ុណ្ណោះ ជាទូទៅគឺជំនាញខាងអប់រំ។ បុគ្គលិកផ្នែកសិក្សាធិការនៃគ្រឹះស្ថានមិនមែនរដ្ឋមិនសូវមានពេញម៉ោងឡើយ – ដូចជានៅក្នុងប្រទេសហ្សែណេកាល់ជាដើមមានត្រឹមតែតិចជាង ២0% – ហើយពួកគេច្រើនតែជាសាស្ត្រាចារដែលឆ្លៀតពេលទំនេរពីគ្រឹះស្ថានសាធារណៈមកបង្រៀនតាមមហាវិទ្យាល័យឯកជន។ នៅក្នុងប្រទេសម៉ាឡេស៊ីសាស្ត្រាចារ្យដែលដើរបង្រៀនតាមសាលាឯកជនបែបនេះអាចមានរហូតដល់ ៨0% នៃបុគ្គលិកនៅតាមគ្រឹះស្ថានមិនមែនរដ្ឋតូចៗដែលទើបបង្កើតថ្មីៗ។ ការផ្តោតលើការកេប្រាក់ចំណេញបង្កបញ្ហាប្រឈមបន្ថែមមួយទៀតខាងផ្នែកគុណភាព ដោយសារតែការប្រមូលផ្តុំក្នុងទីផ្សារណាមួយ និងការផ្តល់អាទិភាពលើប្រាក់ចំណេញជាងការខិតខំលើកកម្ពស់គុណភាពនៃការសិក្សា។

ការផ្តល់សេវាដោយតួអង្គមិនមែនរដ្ឋនាំឱ្យមានការបារម្ភរឿងសមធម៌។ ក្នុងប្រទេសចំណូលមធ្យមកម្រិតខ្ពស់ ភាគរយកាន់តែខ្ពស់របស់តួអង្គមិនមែនរដ្ឋក្នុងភាគរយនៃការចុះឈ្មោះចូលរៀនសរុប មានទំនាក់ទំនងជាមួយនឹងការកើនឡើងនូវវិសមភាពនៃការចូលរៀន។ នៅក្នុងប្រទេសអ៊ុយរូហ្គាយសិស្សជាង ៧៥% នៅគ្រឹះស្ថានមិនមែនរដ្ឋមកពីបញ្ចាភាគដែលមានជីវភាពធូរធារជាងគេបើធៀបនឹងតិចជាង ៤0% នៅគ្រឹះស្ថានសាធារណៈ។ ទោះជាយ៉ាងនេះក្តី គ្រឹះស្ថានមិនមែនរដ្ឋអាចជួយឱ្យក្រុមដែលប្រឈមនឹងការផ្តាត់ចេញអាចទទួលបានការអប់រំ។ នៅក្នុងប្រទេសអារ៉ាប៊ីសាអូឌីត គ្រឹះស្ថានមិនមែនរដ្ឋបានពង្រីកការទទួលបានសេវាអប់រំសម្រាប់ស្ត្រីតាមរយៈការផ្តល់នូវគ្រប់ណ្តុះបណ្តាលតែសម្រាប់និស្សិតស្រី ខណៈពេលដែលនៅក្នុងប្រទេសម៉ាឡេស៊ី គ្រឹះស្ថានទាំងនេះបានផ្តល់លទ្ធភាពសិក្សាដល់និស្សិតជនជាតិចិន និងជនជាតិភាគតិចដែលត្រូវបានហាមប្រាមមិនឱ្យរៀននៅតាមគ្រឹះស្ថានសាធារណៈ ព្រោះតែមានការកំណត់កូតាជនជាតិភាគតិច។ ទោះជាយ៉ាងនេះក្តី ការផ្តល់សេវាអប់រំដែលមានការបែងចែកបែបនេះ អាចនាំឱ្យមានហានិភ័យលើភាពចុះសម្រុងគ្នាក្នុងសង្គម។

ក្របខ័ណ្ឌគតិយុត្តច្រើនតែឆ្លុះបញ្ចាំងពីទស្សនៈយល់ឃើញរបស់រដ្ឋាភិបាលលើតួអង្គមិនមែនរដ្ឋ។ លិខិតបទដ្ឋានគតិយុត្តដែលមានលក្ខណៈតឹងរ៉ឹងមានទំនាក់ទំនងជាមួយនឹងការមិនជឿទុកចិត្ត ខណៈពេលដែលការយល់ឃើញដែលមានលក្ខណៈអំណោយផលចំពោះតួអង្គមិនមែនរដ្ឋអាចជួយសម្រួលដល់ការផ្តល់ការបញ្ជាក់ទទួលស្គាល់គុណភាព ការពិនិត្យតាមដាន និងសូម្បីតែការផ្តល់ថវិកាសាធារណៈ។ នៅតាមប្រទេសមួយ

ចំនួនគ្រឹះស្ថានរកប្រាក់ចំណេញត្រូវដាក់ឱ្យស្ថិតនៅក្រោមគោលការណ៍ណែនាំដែលកាន់តែមានលក្ខណៈតឹងរ៉ឹង–ពួកគេអាចត្រូវបានគេផាត់ចេញនៅខាងក្រៅច្បាប់តែម្តង ដូចជានៅក្នុងប្រទេសអាហ្សង់ទីន និងឈីលី ឬប្រឈមនឹងការរឹតត្បិតខាងផ្នែកការវិភាជន៍ថវិកា ដូចជាមានការកំណត់ផលដែលបានពីការវិនិយោគត្រឹមតែ១០%ប៉ុណ្ណោះក្នុងប្រទេសហ្វីលីពីន។ជារួម យន្តការធានាគុណភាពបានជួយប្រទេសនានា ក្នុងការបិទគ្រឹះស្ថានទាំងឡាយដែលប្រព្រឹត្តិអំពើបោកបន្លំនៅក្នុងការប្រកបអាជីវកម្មរបស់ខ្លួន ឬផ្តល់សេវាដែលមានគុណភាពទាបជាដើម។ នៅក្នុងឆ្នាំ ២០១៧ គណៈកម្មការឧត្តមសិក្សារបស់ប្រទេសប៉ាគីស្ថានបានរកឃើញគ្រឹះស្ថានខុសច្បាប់ចំនួន ១៥៣ ដំណើរការនៅក្នុងប្រទេសនេះ។ ប៉ុន្តែធនធានសម្រាប់ផ្តល់ការបញ្ជាក់គុណភាព និងតាមដានគ្រឹះស្ថានមិនមែនរដ្ឋ ជារឿយៗនៅមានភាពខ្វះខាតនៅឡើយ។

លិខិតបទដ្ឋានគតិយុត្តដែលលើកកម្ពស់សមធម៌ មិនមានច្រើនដូចវិធានរដ្ឋបាលនោះឡើយ។ កូតា ឬលក្ខណៈវិនិច្ឆ័យសម្រាប់ទទួលនិស្សិតចុះឈ្មោះនិស្សិតពិសេស ដែលត្រូវរៀបចំឡើង ដើម្បីបង្កើនការទទួលបានការអប់រំកែទម្រិតឧត្តមសិក្សាសម្រាប់ក្រុមដែលជួបការលំបាក ជានិច្ចកាលពុំមានវិសាលភាពគ្របដណ្តប់លើអ្នកផ្តល់សេវាមិនមែនរដ្ឋនោះឡើយ។ នៅពេលដែលអ្នកផ្តល់សេវាទាំងនេះអនុវត្តគោលការណ៍ទាំងនេះ ដូចជានៅក្នុងប្រទេសឥណ្ឌាជាដើម ជាទូទៅគឺវាអនុវត្តសម្រាប់តែគ្រឹះស្ថានដែលទទួលបានថវិកាគាំទ្រពីរដ្ឋតែប៉ុណ្ណោះ។ ប៉ុន្តែរដ្ឋាភិបាលក៏ជួយផ្តល់ហិរញ្ញប្បទានដល់គ្រឹះស្ថានមិនមែនរដ្ឋនៅតាមប្រទេសភាគច្រើនផងដែរ បុគ្គលិកសិក្សាធិការមួយចំនួនទទួលបានប្រាក់ឧត្តម្ភធនក្នុងនាមជាមន្ត្រីរដ្ឋាភិបាលនៅក្នុងប្រទេសឥណ្ឌូនេស៊ី នៅក្នុងប្រទេសថៃវិញមានការផ្តល់មូលនិធិពិសេសដល់គ្រឹះស្ថានមិនមែនរដ្ឋ។ការទទួលបានមូលនិធិសាធារណៈអាចជួយឱ្យការផ្តល់សេវាពីស្ថាប័នមិនមែនរដ្ឋកាន់តែមានភាពល្អប្រសើរតាមរយៈការលើកទឹកចិត្តឱ្យមានគំនិតផ្តួចផ្តើមធ្វើការស្រាវជ្រាវ ឬប្រសិនបើមានការកំណត់លក្ខខណ្ឌការផ្តល់ថវិកាបែបនេះ ជួយឱ្យគ្រឹះស្ថាននានាសម្រេចតាមស្តង់ដារគុណភាព ឬសមធម៌។

គ្រួសារជាអ្នកវ៉ាប់រងចំណាយលើមូលនិធិអប់រំកែទម្រិតឧត្តមសិក្សាក្នុងភាគរយមួយកាន់តែច្រើន ដែលជាការបង្ហាញថា គេត្រូវការការគាំទ្រពីរដ្ឋ និងពីស្ថាប័នមិនមែនរដ្ឋកាន់តែច្រើនជាងមុន។ រដ្ឋាភិបាលអាចផ្តល់ប្រាក់ឧបត្ថម្ភធន ថ្លៃសេវាសម្រាប់និស្សិតមួយចំនួនដល់គ្រឹះស្ថានមិនមែនរដ្ឋ ដូចជានៅក្នុងប្រទេសប្រេស៊ីល និងឈីលីជាដើម ឬផ្តល់ឧបត្ថម្ភធនសម្រាប់កម្មវិធីផ្តល់កម្ចីដល់និស្សិត ដែលអាចរកបានៅក្នុងប្រទេសជាង ៧០ សម្រាប់និស្សិតទាំងអស់ដែលរៀននៅថ្នាក់ឧត្តមសិក្សា។ តួអង្គមិនមែនរដ្ឋជួយគ្រួសារនានាក្នុងការវ៉ាប់រងចំណាយតាមរយៈប្រាក់អាហារូបត្ថម្ភដែលបង់ដោយក្រុមហ៊ុន មូលនិធិ អង្គការក្រៅរដ្ឋាភិបាល និងសម្បុរសជន ព្រមទាំងតាមរយៈការផ្តល់ជាកម្ចីដល់និស្សិត ឬចុះកិច្ចព្រមព្រៀងបែងចែកចំណូលជាដើម។

តួអង្គមិនមែនរដ្ឋជួយផ្តល់ហិរញ្ញប្បទានដល់គ្រឹះស្ថាននានា ក្រៅតែពីជួយវ៉ាប់រងថ្លៃសេវា។ យន្តការដែលអនុវត្តញឹកញាប់រួមមាន ការចូលរួមក្នុងសកម្មភាពលើទីផ្សារ ដូចជាការផ្តល់ដីសម្រាប់ជួល ការលក់ផលិតផលនិងសេវាកម្មនានា និងការរាយអង្គាសមូលធនតាមរយៈកម្ចី និងការលក់បំណុលបំណុលជាដើម។ គិតត្រឹមពាក់កណ្តាលឆ្នាំ ២០២០ ការចេញបំណុលបំណុលដោយសាកលវិទ្យាល័យនៅទូទាំងសកលលោកកើនឡើងដល់ ១១,៤ ពាន់លានដុល្លារ ពោលគឺជាងពីរដងនៃចំនួនកាលពីឆ្នាំ ២០១៩។ អ្នកផ្តល់ជំនួយ និងសម្បុរសជនក៏ជាប្រភពចំណូលដ៏សំខាន់ក្រៅតែពីថ្លៃសេវាសម្រាប់គ្រឹះស្ថាននានាផងដែរ ដែលស្មើនឹងជាងពាក់កណ្តាលនៃចំណូលសរុបដែលរកបានដោយគ្រឹះស្ថានឧត្តមសិក្សានៅសហរដ្ឋអាមេរិក ក្នុងឆ្នាំ ២០២០។

តួអង្គមិនមែនរដ្ឋមានឥទ្ធិពលលើការអប់រំកែទម្រិតឧត្តមសិក្សាតាមច្រកនានា។ យន្តការមួយចំនួនដូចជាភាពជាដៃគូសម្រាប់ការស្រាវជ្រាវ ការបញ្ចុះបញ្ចូល ការកែទម្រង់អភិបាលកិច្ច ឱ្យដូចធុរកិច្ច និងការតស៊ូមតិជាដើម អាចជួយបង្កើនតម្លាភាព និងពង្រឹងវិស័យនេះបន្ថែមទៀត។ ជំនួយផ្សេងទៀត ដូចជាការផ្តល់ជំនួយក្នុងចំនួនមួយច្រើនពីគ្រឹះស្ថានរកប្រាក់ចំណេញដល់អ្នកនយោបាយជាដើម (ដូចជានៅប្រទេសប្រេស៊ីល និងសហរដ្ឋអាមេរិក) អាចនាំឱ្យមានការជះឥទ្ធិពលមិនត្រឹមត្រូវលើការធ្វើគោលនយោបាយ និងធ្វើឱ្យប៉ះពាល់ដល់ស្វ័យភាពស្ថាប័នជាដើម។

ការអប់រំបច្ចេកទេសវិជ្ជាជីវៈ និងការអប់រំមនុស្សពេញវ័យ

តួអង្គមិនមែនរដ្ឋបានជួយពង្រីកការផ្តល់សេវាអប់រំបែបច្នៃទេស និងវិជ្ជាជីវៈ។ នៅទូទាំងសកលលោកទាំងមូលនិស្សិត ៣៨.៥% ដែលរៀននៅកម្រិតអប់រំក្រោមមធ្យមសិក្សា តែមិនមែនជាការអប់រំថ្នាក់ឧត្តមសិក្សាជ្រើសរើសគ្រឹះស្ថានឯកជនក្នុងឆ្នាំ២០១៩។ក្នុងប្រទេសដែលជាសមាជិករបស់អង្គការOECDនិស្សិត ៤៤%ដែលកំពុងរៀនក្នុងកម្មវិធីវិជ្ជាជីវៈកម្រិតឧត្តមសិក្សារយៈពេលខ្លីចុះឈ្មោះចូលរៀននៅតាមគ្រឹះស្ថានឯកជន។ កិច្ចសហប្រតិបត្តិការជាមួយតួអង្គមិនមែនរដ្ឋមានគោលបំណងធ្វើយ៉ាងណាឱ្យប្រព័ន្ធអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ (TVET) កាន់តែឆ្លើយតបចំពោះតម្រូវការទីផ្សារការងារ ក៏ដូចជាបង្កើនសមត្ថភាព និងធនធានរបស់ពួកគេ សូម្បីតែនៅក្នុងប្រទេសដែលមានប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរដ្ឋដែលរឹងមាំក៏ដោយ។ ក្នុងបរិបទផ្សេងទៀត តួអង្គមិនមែនរដ្ឋបានបំពេញបន្ថែមក្នុងការផ្តល់សេវាអប់រំវិជ្ជាជីវៈតាមរយៈកិច្ចសន្យាបែបប្រពៃណី គំនិតផ្តួចផ្តើមបណ្តុះបណ្តាលបែបស្វយ័ត និងភាពជាដៃគូរដ្ឋ និងឯកជនដែលភាគច្រើនមានការសម្របសម្រួលពីរដ្ឋ។ ក្នុងប្រទេសដែលក្រីក្រ តួអង្គមិនមែនរដ្ឋជួយឱ្យក្រុមជួបការលំបាកអាចទទួលបានសេវាអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈកាន់តែមានសមធម៌។

និយោជកចូលរួមក្នុងកម្មវិធីហ្វឹកហាត់កូនជាងជាលក្ខណៈផ្លូវការ និងក្រៅផ្លូវការ។ ការអង្កេតលើអន្តរកាលពីសាលារៀនទៅកន្លែងធ្វើការដែលធ្វើឡើងដោយអង្គការអន្តរជាតិខាងការងារបានរកឃើញថា ក្នុងចំណោមអ្នកចូលរួមអាយុពី ១៥ ដល់ ៣៥ ឆ្នាំ ៥ នាក់ក្នុងប្រទេសចំនួន ៣៣ មិនដល់ម្នាក់ឡើយដែលបានបញ្ចប់យ៉ាងហោចណាស់កម្មវិធីហ្វឹកហាត់កូនជាងជាផ្នែកមួយនៃការអប់រំរបស់ពួកគេ។ ការចូលរួមតិចតួចនៅក្នុងប្រទេសដែលមានចំណូលទាបអាចមានទំនាក់ទំនងជាមួយនឹងលក្ខណៈក្រៅប្រព័ន្ធនៃទីផ្សារការងារ និងប្រព័ន្ធបណ្តុះបណ្តាល។ ប្រសិនបើពុំមាននិយ័តកម្ម និងការទទួលស្គាល់ឱ្យបានគ្រប់គ្រាន់នោះទេ ការលើកទឹកចិត្តដែលផ្សារភ្ជាប់ជាមួយនឹងកម្មវិធីហ្វឹកហាត់កូនជាងអាច

សាបរលាបជាមិនខាន។ ស្ថាប័នអន្តរការីអាចសម្របសម្រួលកិច្ចពិគ្រោះយោបល់ជាមួយនឹងនិយោជក ដួយឱ្យការសិក្សារៀនសូត្រកាន់តែមានភាពប្រសើរ និងជានាឱ្យមានការផ្តួរផ្តង់ឱ្យបានត្រឹមត្រូវជាពិសេសនៅតាមប្រទេសនានា ដែលពុំមានប្រពៃណីផ្តល់ការហ្វឹកហាត់ដល់កូនជាងឱ្យបានរឹងមាំ។

និយោជកឯកជន គឺជាអ្នកដែលផ្តល់សេវាបន្តអភិវឌ្ឍន៍ជំនាញភាគច្រើន។ ខណៈពេលដែលកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈផ្លូវការ ផ្តោតជាពិសេសលើមុខរបរដែលងាយនឹងត្រូវបានបំប្លែងជាការធ្វើដោយស្វ័យប្រវត្តិ ការបណ្តុះបណ្តាលជំនាញឡើងវិញ និងការបង្កើនជំនាញ កើតមាននៅខាងក្រៅការអប់រំបែបប្រពៃណី។ ការបណ្តុះបណ្តាលក្រៅប្រព័ន្ធ និងការបណ្តុះបណ្តាលដែលបានទទួលការគាំទ្រពីនិយោជកកើតមានជាទូទៅ។ អ្វីដែលគេផ្តល់ឱ្យ គឺមានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងទំហំរបស់ក្រុមហ៊ុន។ លទ្ធផលដែលទទួលបានពីកម្មវិធីវាស់វែងជំនាញ STEP របស់ធនាគារពិភពលោកបង្ហាញថានិយោជកចង់ឱ្យកម្មវិធីបណ្តុះបណ្តាលផ្ទាល់នៅនឹងកន្លែងធ្វើការ ក្លាយជាកម្មវិធីដែលផ្តល់ដោយអ្នកផ្តល់ដោយអ្នកផ្តល់សេវារដ្ឋ ឬឯកជនផ្លូវការពីខាងក្រៅវិញ។

អភិបាលកិច្ចតាមបែបចូលរួមក្នុងប្រព័ន្ធអភិវឌ្ឍន៍ជំនាញមានការលំបាក។ ប្រព័ន្ធ TVET នៅមានលក្ខណៈប្រមូលផ្តុំភាគច្រើន។ ក្របខ័ណ្ឌគុណវុឌ្ឍិជាតិនៅក្នុងប្រទេសជាង ១៥០ មានគោលបំណងធ្វើយ៉ាងណាឱ្យអភិបាលកិច្ចនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈកាន់តែមានភាពចូលរួម និងសមស្របទៅតាមគោលបំណង បើទោះជាការបង្កើនតម្លាភាព និងភាពឆ្លើយតបនៃជំនាញនៅតែជាអាទិភាពសម្រាប់អាជ្ញាធរសាធារណៈក៏ដោយ។ប្រសិទ្ធភាពនៃប្រព័ន្ធTVETទទួលរងការបន្ទុចបង្អាក់ដោយសារយន្តការធានាគុណភាពដែលអនុវត្តបានតែផ្នែកខ្លះ។ អន្តរកម្មរវាងវិស័យឯកជន និងវិស័យអប់រំច្រើនតែផ្តោតលើការកំណត់ពីជំនាញចៀសជាងផ្តោតលើការអភិវឌ្ឍកម្មវិធីសិក្សា។ប្រព័ន្ធជំនាញដែលឆ្លើយតបបានយ៉ាងល្អចំពោះបម្រែបម្រួលនៃសេដ្ឋកិច្ច គឺជាប្រព័ន្ធទាំងឡាយណាដែលពឹងអាស្រ័យលើការប្រើប្រាស់អភិក្រមត្រីភាគី ដែលមានការចូលរួមពីតួអង្គសង្គម និងសេដ្ឋកិច្ចនានា។ ភាពជាដៃគូរដ្ឋ និងឯកជនផ្តោតលើចំណេះដឹងតាមរយៈក្រុមប្រឹក្សាជំនាញតាមវិស័យត្រូវបានបង្កើតឡើងដើម្បីបង្កើនការយល់ដឹងពីតម្រូវការទីផ្សារការងារ។


ប្រព័ន្ធអភិវឌ្ឍន៍ជំនាញពឹងអាស្រ័យលើថវិកាគាំទ្រពីរដ្ឋ និងពីតួអង្គមិនមែនរដ្ឋ។ បន្ថែមលើការវិភាជន៍ថវិកាផ្ទាល់ពីរដ្ឋាភិបាល ប្រព័ន្ធ TVET ខិតខំរិះរកថវិកាគាំទ្រពីប្រភពផ្សេងៗតាមរយៈការកំណត់ថវិកាសម្រាប់កម្រិតបណ្តុះបណ្តាលជាក់លាក់ស្វែងរកថវិកាគាំទ្រពីក្រុមហ៊ុននានា។ តួអង្គមិនមែនរដ្ឋកន្លងមកក៏បានចូលរួមផ្ទាល់ផងដែរតាមរយៈកិច្ចលទ្ធកម្មដែលមានការប្រកួតប្រជែង ក៏ប៉ុន្តែទទួលបានលទ្ធផលចម្រុះ។ និយោជកត្រូវបានលើកទឹកចិត្តឱ្យផ្តល់ការបណ្តុះបណ្តាលតាមរយៈកម្មវិធីបង់ពន្ធ ឬផ្តល់ថវិកាជាអំណោយ។ ទោះជាយ៉ាងនេះក្តី ការវិនិយោគរបស់ក្រុមហ៊ុនលើការបណ្តុះបណ្តាលនៅតែមិនទាន់មានគ្រប់គ្រាន់ព្រោះថាការលើកទឹកចិត្តសម្រាប់ការវិនិយោគបែបនេះនៅមានកម្រិតទាបជាងការលើកទឹកចិត្តការទាញយកជំនាញដែលខ្លួនត្រូវការដោយផ្ទាល់ពីទីផ្សារការងារ។ រដ្ឋាភិបាលផ្តល់ការលើកទឹកចិត្តដល់បុគ្គលម្នាក់ៗតាមរយៈការ៉ាប់រងចំណាយបណ្តុះបណ្តាលផ្ទាល់ ឬប្រយោល ទៅក្នុងគណនីសម្រាប់សិក្សារៀនសូត្ររបស់បុគ្គលម្នាក់ៗ ឬផ្តល់ក្នុងទម្រង់ជាប្រយោជន៍ផ្សេងៗ។

កម្មវិធីសម្រាប់មនុស្សពេញវ័យភាគច្រើនអនុវត្តដោយអង្គការក្រៅរដ្ឋាភិបាល និងអង្គការសហគមន៍។ តាមរយៈមជ្ឈមណ្ឌលសិក្សាសហគមន៍ កម្មវិធីអក្ខរកម្ម និងកម្មវិធីស្រដៀងគ្នានេះ អង្គការក្រៅរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល បានផ្តល់សេវាអប់រំដល់ក្រុមមនុស្សពេញវ័យដែលងាយរងគ្រោះហើយដែលកន្លងមកត្រូវបានដាត់ចេញពីការអប់រំក្នុងប្រព័ន្ធ។ក្នុងករណីមួយចំនួន រដ្ឋាភិបាលពឹងផ្អែកលើសេវារបស់ខ្លួនក្នុងការអនុវត្តកម្មវិធីអក្ខរកម្មសម្រាប់មនុស្សពេញវ័យ និងកម្មវិធីផ្តល់ឱកាសទី ២។ នៅក្នុងបរិបទផ្សេងទៀតក្រុមទាំងនេះបានជំទាស់ទៅនឹងការផ្តល់សេវាអប់រំមនុស្សពេញវ័យរបស់រដ្ឋទៅវិញ ជាពិសេសនៅអាមេរិកឡាទីន ដោយពួកគេខិតខំជំរុញឱ្យមានការប្រើប្រាស់ភាសាដែលមិនមែនជាភាសានិយាយទូទៅ សម្រាប់កម្មវិធីអក្ខរកម្មមនុស្សពេញវ័យ។ ទោះជាយ៉ាងនេះក្តី ក្នុងបរិបទផ្សេងទៀត អង្គការទាំងនេះទទួលរងឥទ្ធិពលដោយសារអាទិភាពរបស់អ្នកផ្តល់ជំនួយ។ ការចូលរួមរបស់អង្គការទាំងនេះក្នុងការរៀបចំគោលនយោបាយរបស់រដ្ឋាភិបាលនៅមានកម្រិតនៅឡើយ បើទោះជានៅអាហ្វ្រិកភាគខាងលិច និងអាហ្វ្រិកភាគកណ្តាល យុទ្ធសាស្ត្រវិមជ្ឈការ (faire-faire decentralization) និងយុទ្ធសាស្ត្រជួលឱ្យអ្នកខាងក្រៅផ្តល់សេវាជំនួស នាំឱ្យមានការសម្រេចបានលទ្ធផលជាវិជ្ជមាន ដោយរដ្ឋជាអ្នកគ្រប់គ្រង និងបែងចែកធនធាន ខណៈពេលដែលតួអង្គមិនមែនរដ្ឋទទួលខុសត្រូវលើការផ្តល់សេវា។

វិស័យឯកជនបានពង្រីកតួនាទីរបស់ខ្លួនការអប់រំមនុស្សពេញវ័យជាពិសេសពាក់ព័ន្ធនឹងការរៀនភាសា។ ក្រុមហ៊ុនឯកជនអាចចូលរួមក្នុងការអប់រំមនុស្សពេញវ័យតាមរយៈការអភិវឌ្ឍសហគមន៍ ជារឿយៗជាផ្នែកមួយគំនិតផ្តួចផ្តើមទំនួលខុសត្រូវក្នុងសង្គមរបស់សាជីវកម្ម ឬចូលរួមក្នុងការផ្តល់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍។

ភាពកាន់តែពាក់ព័ន្ធនៃការរៀនភាសា និងរង្វាយតម្លៃបានទាក់ទាញក្រុមហ៊ុនរកប្រាក់ចំណេញ។ អ្នករៀនភាសាអង់គ្លេសប្រមាណ ៤០% នៅប្រទេសអាហ្សង់ទីន និងប៉េរូសិក្សាជាមួយនឹងគ្រឹះស្ថានបង្រៀនភាសាឯកជន។ ការរៀនភាសាដោយប្រើឧបករណ៍ចល័តជាជំនួយក៏កំពុងរីកសាយភាយផងដែរ ប៉ុន្តែប្រសិទ្ធភាពនៃការរៀនសូត្របែបនេះកំពុងត្រូវបានលើកមកជជែកវែកញែកនៅឡើយ។

អនុសាសន៍



ក្រៅតែពីការបែងចែកសាលារៀនជាសាលារៀនសាធារណៈ និងសាលារៀនឯកជន មានប្រភេទសាលារៀនមិនមែនរដ្ឋជាច្រើន។ លើសពីនេះ តួនាទីរបស់តួអង្គមិនមែនរដ្ឋ គឺមានលើសពីត្រឹមការផ្តល់សេវាអប់រំទៅទៀត ពោលគឺមានអន្តរាគមន៍ជាច្រើនផ្សេងទៀតនៅកម្រិតអប់រំផ្សេងៗគ្នា និងប្រើប្រាស់ច្រកជាច្រើន ដើម្បីដៈឥទ្ធិពលរបស់ខ្លួន។ សំណួរសម្រាប់អ្នកធ្វើគោលនយោបាយ គឺមិនមែនត្រឹមតែ ថាតើការចូលរួមរបស់តួអង្គមិនមែនរដ្ឋនៅក្នុងការអប់រំ បានបំពេញទៅតាមស្តង់ដារគុណភាពដែលបានឯកភាពគ្នាដែរឬទេប៉ុណ្ណោះទេ ថែមទាំងថាតើតួអង្គមិនមែនរដ្ឋបានជួយ ឬបន្ថយបង្អាក់បែបណាខ្លះដល់កិច្ចខិតខំប្រឹងប្រែងជានាសមធម៌ និងបរិយាបន្នក្នុងការអប់រំ។

មានទិសដៅជាយុទ្ធសាស្ត្រចំនួន ២ ដែលពាក់ព័ន្ធនឹងការផ្តល់ថវិកាគាំទ្រ និងការផ្តល់សេវា ដែលលេចធ្លោជាងគេក្នុងកិច្ចការរបស់រដ្ឋាភិបាលក្នុងការផ្តល់ការការពារ និងបំពេញសិទ្ធិទទួលបានការអប់រំ។ ទី ១ កាលពីឆ្នាំ ២០១៥ រដ្ឋាភិបាលសន្យាថា កុមារ និងមនុស្សវ័យក្មេងគ្រប់រូបនឹងទទួលបានការអប់រំដោយមិនគិតថ្លៃក្រោមការឧបត្ថម្ភថវិកាពីរដ្ឋាភិបាលសម្រាប់ការអប់រំកម្រិតមត្តេយ្យសិក្សារយៈ ១ ឆ្នាំ និងការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សារយៈពេល ១២ ឆ្នាំ។ ទោះជាយ៉ាងនេះក្តី ដោយសារតែក្នុងចំណោមប្រទេសចំនួន ៣ មានប្រទេសមួយដែលចំណាយធនធានតិចជាង ៤% នៃ ផ.ស.ស. និង ១៥% នៃចំណាយសាធារណៈសរុបសម្រាប់ការអប់រំ ប្រទេសជាច្រើននៅពុំទាន់បានបំពេញតាមការប្តេជ្ញាចិត្តក្នុងការផ្តល់ថវិកាគាំទ្រដែលចាំបាច់នោះឡើយ។ ទី ២ រដ្ឋាភិបាលចាំបាច់ត្រូវសម្រេចចិត្តថាតើខ្លួនត្រូវបំពេញតួនាទីកម្រិតណាក្នុងការផ្តល់សេវាអប់រំ និងគ្រប់គ្រងសេវាអប់រំ។ ការយល់ឃើញរបស់រដ្ឋាភិបាលអំពីជម្រើសសាលារៀន និងតួអង្គមិនមែនរដ្ឋក៏ខុសៗគ្នាផងដែរ។

តួអង្គមិនមែនរដ្ឋជាច្រើនកាន់តែបង្ហាញវត្តមានរបស់ខ្លួនពាក់ព័ន្ធនឹងទិដ្ឋភាពជាច្រើននៃការអប់រំ។ អ្នកដែលប្រកបធុរកិច្ចធ្វើការសម្រេចចិត្តថាតើការអប់រំ គឺជាប្រភេទអាជីវកម្មដែលផ្តល់នៅប្រាក់ចំណេញច្រើនដែរឬទេ និងអំពីរបៀបផ្សព្វផ្សាយពីទំនិញ និងសេវាកម្មរបស់ខ្លួន ហើយពួកគេក៏សម្រេចចិត្តផងដែរថាតើពួកគេត្រូវទទួលខុសត្រូវចំពោះនរណាៈ តែចំពោះម្ចាស់ភាគហ៊ុនឬចំពោះអ្នកដទៃទៀតផងដែរ? អង្គការក្រៅរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ជាអ្នកជ្រើសរើសអត្ថភាព និងសម្រេចចិត្តពីរបៀបឆ្លើយតបចំពោះអាទិភាពទាំងនោះៈ តើពួកគេគួរបំពេញចំណុចខ្វះខាត ឬជំរុញឱ្យរដ្ឋាភិបាលបំពេញចំណុចខ្វះខាតទាំងនេះ? មូលនិធិនានាក៏បានកំណត់អាទិភាព និងសម្រេចចិត្តពីរបៀបមានឥទ្ធិពលលើសង្គម និងរបៀបធ្វើការងារឱ្យបានជិតស្និទ្ធជាមួយប្រព័ន្ធអប់រំផងដែរ។ គ្រូបង្រៀន និងអង្គការវិជ្ជាជីវៈរបស់ពួកគេធ្វើការសម្រេចចិត្តដែលអាចជួយពង្រឹងបន្ថែម ឬធ្វើឱ្យសាបរលាបនូវទំនុកចិត្តចំពោះប្រព័ន្ធអប់រំសាធារណៈ។

ការអំពាវនាវនៃរបាយការណ៍ដែលមានចំណងជើងថា – នរណាជាអ្នកជ្រើសរើស? នរណាជាអ្នកខាតបង់? – គឺជាការអញ្ជើញឱ្យអ្នកធ្វើគោលនយោបាយចោទសួរទំនាក់ទំនងជាមួយតួអង្គមិនមែនរដ្ឋ ពាក់ព័ន្ធនឹងជម្រើសជាមូលដ្ឋានមួយចំនួនដូចជាៈ ជម្រើសរវាងសេរីភាព និងការជ្រើសរើស និងសមធម៌, រវាងគំនិតផ្តួចផ្តើមដែលផ្តល់ការលើកទឹកចិត្ត (ឧទាហរណ៍ ការបង្កើនគុណភាពនៅគ្រប់ទិសទីក្នុងប្រព័ន្ធ) និងការបង្កើតជាស្តង់ដារ (ឧទាហរណ៍ ការបង្កើនគុណភាពសម្រាប់អ្នកសិក្សាគ្រប់រូប), រវាងក្រុមប្រជាជនដែលមានមធ្យោបាយ និងតម្រូវការផ្សេងៗគ្នា, រវាងការប្តេជ្ញាចិត្តចំពោះមុខរបស់ពួកគេ (ឧទាហរណ៍ ការប្តេជ្ញាចិត្តផ្តល់ការអប់រំដោយមិនគិតថ្លៃរយៈពេល ១២ ឆ្នាំ ក្រោមក្របខ័ណ្ឌនៃគោលដៅអភិវឌ្ឍន៍ដោយចីរភាពទី ៤) និងការប្តេជ្ញាចិត្តដែលនឹងត្រូវសម្រេចជាបន្តបន្ទាប់ (ឧទាហរណ៍ ការអប់រំក្រោយមធ្យមសិក្សា), និងរវាងវិស័យអប់រំ និងវិស័យសង្គមដទៃទៀត។

ដោយចងចាំពីគំនិតទាំងនេះ អនុសាសន៍ខាងក្រោមត្រូវបានរៀបចំឡើង ដើម្បីដល់យុទ្ធនាការ #RighttheRules ដើម្បីជានាយ៉ាងនាឱ្យមានការការពារសមធម៌នៅក្នុងការអប់រំ ជុំវិញទិដ្ឋភាពហិរញ្ញប្បទាន គុណភាពអភិបាលកិច្ច នវានុវត្តន៍ និងការធ្វើគោលនយោបាយ។ គោលបំណង គឺដើម្បីកៀរគរពីការរួមចំណែកពីតួអង្គមិនមែនរដ្ឋ ដើម្បីផ្តល់សេវាអប់រំប្រកបដោយគុណភាពដោយមិនធ្វើឱ្យប៉ៈពាល់ដល់សមភាព។ ការកៀរគរសក្តានុពលបែបនេះ ក៏អាចជំរុញឱ្យរដ្ឋាភិបាលដាក់ចេញនូវគោលដៅឆ្លើយតបចំពោះបញ្ហាគុណភាពទាប និងវិសមភាពក្នុងការផ្តល់សេវាសាធារណៈផងដែរ។ អនុសាសន៍ទាំងនេះមានគោលបំណងផ្តោតជាសំខាន់លើរដ្ឋាភិបាលដែលចាំបាច់ត្រូវផ្តល់ចម្លើយឱ្យបានច្បាស់លាស់ ចំពោះសំណួរសួរចំនួន ៥ ចេញពីជ្រុងសមធម៌ និងបរិយាបន្ន។ ទោះជាយ៉ាងនេះក្តី តួអង្គពាក់ព័ន្ធក្នុងវិស័យអប់រំទាំងអស់ ក៏អាចយកអនុសាសន៍ទាំងនេះ ទៅប្រើប្រាស់ជាឧបករណ៍តស៊ូមតិ ដើម្បីគាំទ្រដល់វឌ្ឍនភាព ឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ដោយចីរភាពទី ៤។ ដូច្នេះអនុសាសន៍ទាំងនេអំពាវនាវឱ្យតួអង្គទាំងអស់ ទាំងរដ្ឋ ទាំងមិនមែនរដ្ឋ បំពេញតួនាទីឱ្យបានត្រឹមត្រូវទៅតាមក្បួនច្បាប់ដែលត្រូវបានកំណត់ (យុទ្ធនាការ #RightbytheRules)។

១. តើការផ្តល់ហិរញ្ញប្បទានដល់ការអប់រំលម្អៀងទៅរកអ្នកសិក្សាមួយចំនួន ហើយបែរជាដាក់ចេញអ្នកសិក្សាផ្សេងទៀតដែរឬទេ?

បំពេញតាមការប្តេជ្ញាចិត្ត ដើម្បីធ្វើយ៉ាងណាឱ្យការអប់រំកម្រិតមត្តេយ្យសិក្សារយៈពេល ១ ឆ្នាំ និងការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សារយៈពេល ១២ ឆ្នាំ ផ្តល់ដោយមិនគិតថ្លៃ – ប៉ុន្តែការផ្តល់ហិរញ្ញប្បទានពីប្រភពសាធារណៈមិនមែនមានន័យថាសេវាត្រូវតែផ្តល់ដោយស្ថាប័នសាធារណៈនោះឡើយ ប្រសិនបើគេអាចជានាបាននូវសមធម៌ដែរនោះ



រដ្ឋាភិបាលគួរធ្វើយ៉ាងណាឱ្យការអប់រំដែលមានគុណភាពខ្ពស់មានដោយមិនគិតថ្លៃនៅកន្លែងផ្តល់សេវា។ រដ្ឋាភិបាលចាំបាច់ត្រូវជានាថាប្រជាពលរដ្ឋមិនមែនជាអ្នកវាប់រងចំណាយលើទំនិញ និងលើសេវាកម្មអប់រំ ដែលប្រទេសរបស់ពួកគេបានប្តេជ្ញាថានឹងផ្តល់ដោយមិនគិតថ្លៃនោះឡើយ។

រដ្ឋាភិបាលចាំបាច់ត្រូវតាមដានការចំណាយលើការអប់រំពីហោប៉ៅផ្ទាល់ខ្លួន ដោយប្រើប្រាស់ការអង្កេតលើចំណូល និងចំណាយរបស់គ្រួសារ។ ជារឿយៗ រដ្ឋាភិបាលពុំបានយកចិត្តទុកដាក់ពីចំណាយដែលមិនមានការឯកសារបញ្ជាក់ច្បាស់ លាស់ឡើយ ដែលនេះជាកត្តាដែលអាចនាំឱ្យមានការកើនឡើងនូវវិសមភាព។

រាល់អ្នកផ្តល់សេវាទាំងអស់ ទាំងរដ្ឋ ទាំងមិនមែនរដ្ឋត្រូវផ្តល់លក្ខខណ្ឌដូចៗគ្នាដល់សិស្ស។ ការប្តេជ្ញាចិត្តក្នុងការផ្តល់នូវថវិកាពីប្រភពសាធារណៈសម្រាប់ការងារអប់រំ មិនមែនមានន័យថា សេវាអប់រំទាំងអស់ត្រូវតែផ្តល់ជាសាធារណៈនោះឡើយ។ ប៉ុន្តែគេគួរចាត់ទុកគ្រឹះស្ថានអប់រំទាំងអស់ថាជាផ្នែកនៃប្រព័ន្ធតែមួយ ដែលស្ថិតនៅក្រោមវិធាន ទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុ និងយន្តការត្រួតពិនិត្យតែមួយ។

ការប៉ុនប៉ងធ្វើពិពិធកម្មសេវាអប់រំគួររៀបចំឡើងតាមបែបផែនដែលធានាបាននូវសមធម៌។ ការជួលឱ្យអ្នកផ្តល់សេវាពីខាងក្រៅមកគ្រប់គ្រងសាលាសាធារណៈការផ្តល់ឧបត្ថម្ភធនសម្រាប់ប៉ាប់រងចំណាយប្រតិបត្តិការរបស់សាលាឯកជន ឬការផ្តល់មូលនិធិគាំទ្រដល់គ្រួសារ ដើម្បីបំពេញតាមជម្រើសសាលារៀនរបស់ពួកគេអាចងាយនឹងផ្តល់ជាប្រយោជន៍ដល់អ្នកសិក្សារៀនសូត្រ ដែលមានជីវភាពធូធារទៅវិញ។


សាលារៀនមិនគួរមានសិទ្ធិជ្រើសរើសសិស្សនោះឡើយ។ ប្រទេសនានាសុទ្ធតែមានការប្តេជ្ញាចិត្តមិនឱ្យមានការរើសអើងក្នុងសេវាអប់រំ ជាគោលការណ៍ដែលត្រូវឆ្លុះបញ្ចាំងក្នុងគោលនយោបាយទទួលយកសិស្សឱ្យចូលរៀន។ លើសពីនេះ សិទ្ធិរបស់គ្រួសារ និងសិស្សក្នុងការជ្រើសរើសសាលារៀនមិនគួរធ្វើឱ្យវិសមភាពមានការកើនឡើងនោះឡើយ។

អ្នកផ្តល់សេវាមិនមែនរដ្ឋដែលទទួលបានដែលទទួលបានថវិកាគាំទ្រពីរដ្ឋមិនគួរគិតថ្លៃសេវានានានោះឡើយ។ ខណៈពេលដែលគ្រប់ប្រទេសទាំងអស់គួរខិតខំធានាថា ការអប់រំកម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា ត្រូវផ្តល់ឱ្យដោយមិនគិតថ្លៃ ប្រទេសជាច្រើននៅឆ្ងាយពីស្ថានភាពល្អបំផុតដែលពួកគេចង់បានបែបនេះ។ សូម្បីតែគ្រឹះស្ថានឯកជនដែលពឹងផ្អែកលើការគាំទ្រពីរដ្ឋាភិបាលក៏គិតថ្លៃសេវាផងដែរ។

ការរកប្រាក់ចំណេញ គឺមិនស្របតាមការប្តេជ្ញាចិត្ត ដើម្បីធានាឱ្យមានការផ្តល់ការអប់រំកម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាដោយមិនគិតថ្លៃនោះឡើយ។ គេអាចប្រើប្រាស់វិធានការធ្វើនិយ័តកម្ម ឬការហាមប្រាម ដើម្បីឆ្លើយតបចំពោះគោលនយោបាយស្តីពីជម្រើសសាលារៀន ដែលនាំឱ្យវិសមភាពមានការកើនឡើង។

២. តើអ្នកសិក្សាទាំងអស់សុទ្ធតែបានទទួលការអប់រំប្រកបដោយគុណភាព ដែលពួកគេមានសិទ្ធិទទួលបាន ឬអ្នកសិក្សាមួយចំនួនទទួលបានការអប់រំដែលមានគុណភាពមិនគ្រប់គ្រាន់?

កំណត់ស្តង់ដារគុណភាពដែលត្រូវអនុវត្តចំពោះគ្រឹះស្ថានអប់រំទាំងរដ្ឋ ទាំងមិនមែនរដ្ឋទាំងអស់



រដ្ឋាភិបាលចាំបាច់ត្រូវកំណត់នូវស្តង់ដារគុណភាព ដែលត្រូវអនុវត្តចំពោះគ្រឹះស្ថានអប់រំទាំងអស់។ ស្តង់ដារគុណភាពដែលមិនត្រឹមតែគ្របដណ្តប់លើធាតុចូលប៉ុណ្ណោះទេ ថែមទាំងលើលទ្ធផលផងដែរ ផ្តល់ការការពារដល់អ្នកដែលត្រូវទទួលរងការខាតបង់ច្រើនជាងគេ។ ស្តង់ដារទាំងនេះ គួរគ្របដណ្តប់លើបញ្ហាសុវត្ថិភាព និងបរិយាបន្ន។ ស្តង់ដារទាំងនេះ គួរពាក់ព័ន្ធជាមួយនឹងទីតាំងដែលសាលារៀនស្ថិតនៅ និងជួយឱ្យសាលារៀនទាំងនោះកាន់តែមានភាពល្អប្រសើរ។ គេគួរធ្វើការវាយតម្លៃលើការសម្រេចតាមស្តង់ដារទាំងនេះនៅតាមសាលារៀននីមួយៗទាំងសាលារៀនរដ្ឋ ទាំងសាលារៀនមិនមែនរដ្ឋ និងត្រូវមានការរាយការណ៍ជាសាធារណៈ។

គួរមានការផ្តល់តម្លៃដល់គ្រូបង្រៀនក្នុងនាមពួកគេជាអ្នកជំនាញវិជ្ជាជីវៈនៅគ្រប់សាលារៀនទាំងអស់។ គុណវុឌ្ឍិគ្រូបង្រៀន និងឱកាសអភិវឌ្ឍន៍វិជ្ជាជីវៈ មិនគួរមានការប្រែប្រួលខុសៗគ្នាទៅតាមអ្នកផ្តល់សេវានោះឡើយ។ ទីផ្សារការងារសម្រាប់គ្រូបង្រៀន ដែលមានការបែងចែកគ្រូបង្រៀនជាក្រុម និងបញ្ហាវិសមភាពនៃបៀវត្ស និងលក្ខខណ្ឌរបស់គ្រូគឺជាសញ្ញាដ៏ច្បាស់មួយដែលបង្ហាញពីប្រព័ន្ធអប់រំដែលមិនបានបំពេញមុខងារឱ្យបានល្អ។ រដ្ឋាភិបាលចាំបាច់ត្រូវឆ្លើយតបជាបណ្តើរៗចំពោះបញ្ហាគ្រប់បែបយ៉ាងដែលជាឫសគល់នាំឱ្យមានអតុល្យភាពបែបនេះ។

ចាំបាច់ត្រូវមានការដាក់ឱ្យអនុវត្តនូវយន្តការធានាគុណភាព ដើម្បីតាមដាន និងពង្រឹងការអនុវត្តស្តង់ដារនានា។ ការត្រួតពិនិត្យរបស់រដ្ឋាភិបាលតាមរយៈការធ្វើអធិការកិច្ចតាមសាលារៀន ការវាយតម្លៃ និងការវាយតម្លៃលើការសិក្សារបស់សិស្ស គួរធ្វើឡើងឱ្យបានដូចៗគ្នា ដោយមិនប្រកាន់ពីប្រភេទអ្នកផ្តល់សេវានោះឡើយ។ យន្តការទាំងនេះ គួរពិចារណាសមត្ថភាពអនុវត្តរបស់រដ្ឋ។


ប្រទេសទាំងឡាយត្រូវការធានាគុណភាពដែលកាន់តែរឹងមាំសម្រាប់ការអប់រំបច្ចេកទេស វិជ្ជាជីវៈ និងឧត្តមសិក្សា។ ខណៈពេលដែលរដ្ឋាភិបាលផ្តល់ឧបត្ថម្ភធនដល់បុគ្គល ឬជួលក្រុមហ៊ុនឱ្យផ្តល់ជាវគ្គ

បណ្តុះបណ្តាល រដ្ឋាភិបាលចាំបាច់ត្រូវការ/ពារក្រុមដែលជួបការលំបាកជាងគេ ដែលងាយរងគ្រោះដោយសារការកេងបន្លំ។ សាកលវិទ្យាល័យដែលបើកដំណើរការ ដើម្បីរកប្រាក់ចំណេញតែងត្រូវបានគេត្រួតពិនិត្យនៅពេលដែលសាកលវិទ្យាល័យទាំងនោះផ្តល់ការអប់រំក្នុងកម្រិតគុណភាពទាបបំផុត និងពាក់ព័ន្ធជាមួយនឹងការអនុវត្តដែលមិនល្អ។

រដ្ឋាភិបាលចាំបាច់ត្រូវហាមប្រាមមិនឱ្យមានការបង្រៀនបន្ថែមជាលក្ខណៈឯកជន ដើម្បីបង្ការផលប៉ះពាល់អវិជ្ជមានមកលើគុណភាព និងសមធម៌របស់ប្រព័ន្ធអប់រំ។ ការឆ្លើយតបកម្រិតគោលនយោបាយមានការប្រែប្រួលខុសៗគ្នា ចាប់ពីការកំណត់លក្ខខណ្ឌឱ្យគ្រូបង្រៀនឯកជនត្រូវមានលិខិតអនុញ្ញាតរហូតដល់ការចុះបញ្ជីតាមប្រព័ន្ធអនឡាញ ដើម្បីកាន់តែងាយស្រួលគ្រប់គ្រង។ ការហាមប្រាមបែបនេះ ក៏អាចជាជម្រើសមួយដែរ ប៉ុន្តែអាចនាំឱ្យមានការបង្កើតទីផ្សារក្រៅប្រព័ន្ធ។ អត្ថិភាពចម្បងគួរផ្តោតលើការឆ្លើយតបចំពោះឫសគល់នៃបញ្ហា ដូចជាការផ្តល់បៀវត្សទាបដល់គ្រូបង្រៀន និងការប្រឡងចុងក្រោយ ដែលមានសារៈសំខាន់ខ្លាំងជាដើម។

៣. តើលិខិតបទដ្ឋានគតិយុត្តមានប្រសិទ្ធភាព និងអាចអនុវត្តទៅបានដែរឬទេ ឬថាតើលិខិតបទដ្ឋានទាំងនោះបង្កជលិបាកដែលគេមិនចង់បាន ដែលបង្កគ្រោះថ្នាក់ដល់អ្នកសិក្សាដែលជួបការលំបាក?

បង្កើតនូវដំណើរការតាមដានរួម និងដំណើរការផ្តល់ការគាំទ្រដែលត្រូវអនុវត្តចំពោះគ្រប់គ្រឹះស្ថានអប់រំរដ្ឋ និងមិនមែនរដ្ឋ



រដ្ឋាភិបាលចាំបាច់ត្រូវមានចក្ខុវិស័យឱ្យបានច្បាស់លាស់ និងដាក់ចេញនូវក្របខ័ណ្ឌដែលបង្ហាញពីរបៀបដែលរដ្ឋាភិបាលចង់ជំរុញការចូលរួមសហការពីសំណាក់តួអង្គមិនមែនរដ្ឋ និងត្រូវផ្សព្វផ្សាយពីចក្ខុវិស័យនេះតាមរយៈលិខិតបទដ្ឋានគតិយុត្តនានា។ លិខិតបទដ្ឋានគតិយុត្តនានា គួរផ្តោតការយកចិត្តទុកដាក់មិនមែនលើកិច្ចការរដ្ឋបាលលម្អិត និងស្តង់ដារជាតុចូលដែលពុំមានលក្ខណៈប្រាកដនិយមនោះឡើយ ប៉ុន្តែលើដំណើរការ និងលទ្ធផលនៃការអប់រំ និងត្រូវមានការពិនិត្យ និងកែសម្រួលជាទៀងទាត់ប្រកបដោយតម្លាភាព និងមានការចូលរួម ជាមួយនឹងការផ្តល់ធាតុចូលពីសាលារៀនរដ្ឋ និងសាលារៀនមិនមែនរដ្ឋ។


អ្នកផ្តល់សេវាអប់រំ ជានិច្চកាល គួរត្រូវបានធ្វើនិយ័តកម្មពីសំណាក់អាជ្ញាធរអប់រំ ដោយចាត់ទុកថាជាគ្រឹះស្ថានអប់រំ មិនមែនជាគ្រឹះស្ថានពាណិជ្ជកម្ម ដែលត្រូវធ្វើនិយ័តកម្ម ដោយនិយ័តករទីផ្សារនោះឡើយ។ អ្នកផ្តល់សេវាមួយចំនួនត្រូវបានគេចាត់ទុកថាជាធុរកិច្ចដែលផ្តល់សេវាគាំពារ និងអប់រំកុមារតូចផ្តល់សេវាអប់រំបន្ថែមជាលក្ខណៈឯកជន និងការបណ្តុះបណ្តាលវិជ្ជាជីវៈជាដើម។ ស្រដៀងគ្នានេះដែរ អ្នកផ្តល់សេវាដទៃទៀតត្រូវបានត្រួតពិនិត្យដោយក្រសួងគាំពារសង្គម ឬដោយអាជ្ញាធរសាសនាជាដើម។

លិខិតបទដ្ឋានគតិយុត្តនានាចាំបាច់ត្រូវតែសាមញ្ញ មានតម្លាភាព និងមានប្រសិទ្ធភាព។ ប៉ុន្តែអ្វីៗគឺផ្ទុយទៅវិញ ពោលគឺសមត្ថភាពនិយ័តកម្មមានកម្រិតទាបបំផុត នៅកន្លែងដែលគេត្រូវការវាបំផុត និងកន្លែងដែលអាចមានអំពើពុករលួយកើតមានឡើងខ្ពស់បំផុត។ ក្នុងករណីដែលនៅមានការខ្វះខាតសមត្ថភាពពិនិត្យតាមដាន និងពង្រឹងការអនុវត្តលិខិតបទដ្ឋានគតិយុត្តនានា និងពុំមានភាពពាក់ព័ន្ធ និងអាចនាំមកនៅផលវិបាកទៅវិញ។

រដ្ឋាភិបាលត្រូវចាំបាច់មានភាពស្មោះត្រង់ជុំវិញហេតុផលដែលនាំឱ្យពួកគេមានបំណងចង់ធ្វើនិយ័តកម្ម។ ដំណើរការពិនិត្យតាមដាន និងផ្តល់ការគាំទ្រ គួរតែមានដូចៗគ្នា ដែលបង្ហាញថារដ្ឋាភិបាលពិតជាយកចិត្តទុកដាក់ចំពោះការអប់រំរបស់កុមារគ្រប់រូប ដោយមិនប្រកាន់ពីប្រភេទសាលារៀនដែលពួកគេរៀននោះឡើយ។ រដ្ឋាភិបាលក៏ចាំបាច់ត្រូវកសាងទំនាក់ទំនងប្រកបដោយការជឿទុកចិត្ត ជាមួយអ្នកផ្តល់សេវាមិនមែនរដ្ឋ ដោយត្រូវផ្តល់នូវការលើកទឹកចិត្តឱ្យបានសមស្រប ដើម្បីឱ្យពួកគេអាចដំណើរការសាលារៀនរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

៤. តើគំនិតល្អៗសម្រាប់ការអប់រំត្រូវបានគេខិតខំបណ្តុះឱ្យមាន ឬត្រូវបានរាំងខ្ទប់មិនឱ្យមាន?

បង្កភាពងាយស្រួលដល់ការសាយភាយគំនិតនវានុវត្តន៍តាមរយៈប្រព័ន្ធអប់រំ ដើម្បីបុព្វហេតុរួម



អ្នកធ្វើគោលនយោបាយ គួរអោចកំណត់ពីនវានុវត្តន៍ និងត្រូវផ្តល់ពេលវេលា និងឱកាសឱ្យមានការអភិវឌ្ឍជាគំនិតល្អៗ។ ពុំមាននរណាម្នាក់មានសិទ្ធិផ្តាច់មុខលើគំនិតល្អៗនោះឡើយ។ ការអប់រំ គឺជាកិច្ចខិតខំប្រឹងប្រែង នៅក្នុងសង្គម និងជាប្រព័ន្ធដែលមានលក្ខណៈស្មុគស្មាញ។ បញ្ហាប្រឈមសម្រាប់អ្នកធ្វើគោលនយោបាយ គឺត្រូវលើកទឹកចិត្តឱ្យមាននវានុវត្តន៍ ជាពិសេសនៅពេលដែលសាធារណៈជនទូទៅផ្តល់អាទិភាពដល់ភាពអនុលោម ចៀសជាងលើការពិសោធន៍។

រដ្ឋាភិបាលគួរធ្វើការងារក្នុងភាពជាដៃគូជាមួយគ្រប់តួអង្គទាំងអស់ ដើម្បីកសាងប្រព័ន្ធអប់រំមួយ ដែលមានប្រសិទ្ធភាពសម្រាប់ទាំងអស់គ្នា ដោយផ្តល់អាទិភាពលើអតិក្រម ដែលមានការពិគ្រោះយោបល់ជាមួយគ្នា។ ចាំបាច់ត្រូវមានការកសាងវប្បធម៌ជឿទុកចិត្តគ្នា ដើម្បីជំរុញលើកកម្ពស់នវានុវត្តន៍។ ការកសាងនូវលក្ខណៈ និងការបង្កើតជាវេទិកា ដើម្បីឱ្យតួអង្គពាក់ព័ន្ធចម្រុះធ្វើអន្តរកម្ម និងសហការគ្នាអាចជួយឱ្យប្រព័ន្ធអប់រំសាធារណៈទទួលបានប្រយោជន៍ពីគំនិតទស្សនៈយល់ឃើញផ្សេងៗគ្នា និងដើម្បីឱ្យប្រកពជំនាញឯកទេសនៅតែមានភាពពាក់ព័ន្ធ។

ជាការចាប់ផ្តើម រដ្ឋាភិបាលចាំបាច់ត្រូវបណ្តុះគំនិតនវានុវត្តន៍ ក្នុងប្រព័ន្ធអប់រំសាធារណៈ។ រដ្ឋាភិបាលចាំបាច់ត្រូវផ្សព្វផ្សាយសារ ដែលបង្ហាញថារដ្ឋាភិបាលពិតជាប្តេជ្ញាចិត្តចង់បានឧត្តមភាពប្រាកដមែន។ រដ្ឋាភិបាលគួរពិនិត្យតាមដានការសិក្សារៀនសូត្រ កត្តាដែលកំណត់ពីការសិក្សារៀនសូត្រ ធ្វើការវាយតម្លៃពីការអនុវត្តល្អ ផ្តល់ធនធាន ដើម្បីផ្តល់លទ្ធភាពឱ្យអ្នកអនុវត្តការងារធ្វើការចែករំលែកបទពិសោធន៍ជាមួយគ្នាទៅវិញទៅមក សាកល្បងគំនិតល្អៗ និងពង្រីកវិសាលភាពគំនិតល្អៗទាំងនេះ។

រដ្ឋាភិបាល ក៏គួរស្វែងរកមេរៀនពីតួអង្គមិនមែនរដ្ឋផងដែរ។ គោលវិធីរៀន និងបង្រៀនដែលមានលក្ខណៈស្វយ័ត សមស្របតាមបរិបទ និងមានភាពទន់ភ្លន់ ជាពិសេសដែលមានការយកចិត្តទុកដាក់ចំពោះអ្នកសិក្សា ដែលមានឱកាសតិចតួចអាចផ្តល់នូវគំនិតថ្មីៗ ដែលរដ្ឋាភិបាលគួរទាញប្រយោជន៍ពីគំនិតទាំងនោះ ហើយក្នុងពេលជាមួយគ្នាត្រូវទទួលស្គាល់ថាការមានសមត្ថភាពទាប ជាកត្តាដែលរារាំងមិនឱ្យរដ្ឋាភិបាលអាចតាមដាន និងវាយតម្លៃសាលារដ្ឋឱ្យបានត្រឹមត្រូវ ចុះទម្រាំសាលារៀនមិនមែនរដ្ឋទៅទៀត។

តួនាទីរបស់រដ្ឋាភិបាល គឺត្រូវបង្កើតបរិយាកាសឱ្យបានសមស្របដើម្បីនាំមកនូវនវានុវត្តន៍។ គេមិនគួរចាត់ទុកការអប់រំថាជាទីផ្សារដែល 'អ្នកផលិត' សេវាអប់រំប្រកួតប្រជែងជាមួយនឹងអ្នកផ្តល់សេវាដទៃទៀតនោះឡើយ។ ផ្ទុយទៅវិញគេចាំបាច់ត្រូវចែករំលែកធ្វើតេស្តសាកល្បងគំនិតថ្មីៗនានា ហើយប្រសិនបើមានការរកឃើញថាគំនិតទាំងនោះពិតជាល្អមែន ត្រូវយកគំនិតទាំងនេះទៅអនុវត្តដោយរដ្ឋាភិបាលជាអ្នកជួយឱ្យគំនិតទាំងនេះសាយភាយជ្រួតជ្រាបក្នុងប្រព័ន្ធអប់រំទាំងមូល ហើយតួអង្គមិនមែនរដ្ឋស្មគ្រគិតយកគំនិតទាំងនេះទៅអនុវត្ត ដើម្បីបុព្វហេតុរួមចៀសជាង ដើម្បីផលប្រយោជន៍សេដ្ឋកិច្ច។

៥. តើរាល់សំឡេងទាំងអស់ សុទ្ធតែបានទទួលឱកាសស្មើគ្នា ដើម្បីសម្រួចការជជែកពិភាក្សាជាសាធារណៈអំពីបញ្ហាអប់រំដែរឬទេ?

រក្សាតម្លាភាព និងសុចរិតភាពនៃដំណើរការគោលនយោបាយអប់រំសាធារណៈ ដើម្បីរាំងខ្ទប់ផលប្រយោជន៍សួនតួ



អ្នកធ្វើគោលនយោបាយចាំបាច់ត្រូវពិចារណាលើគំនិត និងការយល់ឃើញពីគ្រប់តួអង្គពាក់ព័ន្ធទាំងអស់។ ប៉ុន្តែ ដូចគ្នានឹងការណ៍ដែលអ្នកធ្វើគោលនយោបាយគួរបើកចំហទទួលយកសំឡេងពីអ្នកពាក់ព័ន្ធចម្រុះ អ្វីដែលសំខាន់ និងចាំបាច់ផងដែរនោះ គឺការប្រាស្រ័យទាក់ទងជាមួយនឹងមន្ត្រីសាធារណៈ អំពីច្បាប់គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តស្តីពីការអប់រំ ដើម្បីឱ្យឯកសារទាំងនេះមានតម្លាភាព។ តួអង្គមួយចំនួនប្រហែលជាកំពុងខិតខំបង្កើនចំណែកទីផ្សារ ឬអំណាចនយោបាយរបស់ខ្លួនចៀសជាងខិតខំ ដើម្បីបុព្វហេតុសាធារណៈ។

រដ្ឋាភិបាលចាំបាច់ត្រូវពិនិត្យតាមដាន និងការសុវត្ថិភាពទប់ទល់នឹងការបញ្ចុះបញ្ចូល ដើម្បីប្រយោជន៍សួនតួ ដើម្បីកុំឱ្យការបញ្ចុះបញ្ចូលបែបនេះមានឥទ្ធិពលមិនត្រឹមត្រូវលើគោលនយោបាយសាធារណៈ។ ដើម្បីបន្តរក្សាជាជឿទុកចិត្តលើដំណើរការគោលនយោបាយសាធារណៈ គេអាចអនុវត្តវិធានការជាច្រើន ដើម្បីលើកកម្ពស់តម្លាភាព ដោយវាអាស្រ័យទៅតាមសមត្ថភាព ដូចជា ច្បាប់ស្តីពីសេរីភាពព័ត៌មានដែលជំរុញឱ្យមានការបង្ហាញពីការផ្តល់ជាអំណោយដល់គណៈបក្សនយោបាយ និងការជួបប្រជុំជាមួយមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ និងវិធានប្រឆាំងទៅនឹងមន្ត្រីរដ្ឋាភិបាលដែលចាកចេញពីមុខដំណែង ហើយដែលនៅតែបន្តអាចទទួលបានផលប្រយោជន៍ឯកជន និងប្រឆាំងនឹងអ្នកបញ្ចុះបញ្ចូល និងអ្នកឧបត្ថម្ភដល់អ្នកបញ្ចុះបញ្ចូលទាំងនេះមិនឱ្យកាន់មុនដំណែងសាធារណៈ។ អនុសាសន៍ទាំងនេះ ក៏ត្រូវអនុវត្តចំពោះអង្គការអន្តរជាតិផងដែរ ដែលអង្គការទាំងនេះចាំបាច់ត្រូវតែមានគោលនយោបាយឱ្យបានច្បាស់លាស់ ដើម្បីចូលរួមជាមួយនឹងតួអង្គមិនមែនរដ្ឋ ដែលផ្តល់អាទិភាពដល់សមធម៌ និងបរិយាបន្ន។

ការតាមដានការអប់រំក្នុងបរិបទនៃគោលដៅអភិវឌ្ឍន៍ដោយចីរភាព

ដោយសារតែយើងខិតជិតដល់ពាក់កណ្តាលនៃរយៈពេល ដើម្បីសម្រេចរបៀបវារៈអភិវឌ្ឍន៍ដោយចីរភាពឆ្នាំ ២០៣០ កន្លងមក មានការសម្រេចបាននូវភាពជឿនលឿនសំខាន់ៗក្នុងការរៀបចំក្របខ័ណ្ឌពិនិត្យតាមដាន និងចំណុចដៅដែលប្រទេសនានាបានដាក់ចេញ។ ទោះជាយ៉ាងណាក៏ដោយ ការរាតត្បាតជាសកលនៃជំងឺកូវីដ ១៩ នាំមកនូវឧបសគ្គធំៗជាច្រើនក្នុងកិច្ចការទាំងពីរខាងលើនេះ។ មិនត្រឹមតែឧបករណ៍ស្តង់ដារដែលត្រូវបានប្រើប្រាស់សម្រាប់តាមដានវឌ្ឍនភាពក្នុងការអប់រំប៉ុណ្ណោះទេដែលរងផលប៉ះពាល់ សូម្បីតែចំណុចដៅខ្លួនឯងក៏ទាមទារឱ្យមានការពិចារណាឡើងវិញផងដែរ។

ប្រទេសនានាបានផ្ញើព័ត៌មានចំណុចដៅ (BENCHMARKS) ថ្នាក់ជាតិ សម្រាប់គោលដៅអភិវឌ្ឍន៍ដោយចីរភាពទី ៤


ក្របខ័ណ្ឌសកម្មភាពអប់រំឆ្នាំ ២០៣០ អំពាវនាវឱ្យបណ្តាប្រទេសនានាដាក់ចេញនូវចំណុចដៅរយៈពេលមធ្យមឱ្យបានសមស្រប (ឧទាហរណ៍ សម្រាប់ឆ្នាំ ២០២០ និង ២០២៥) សម្រាប់សូចនាករ SDG ទី ៤ ដើម្បីប្រមូលព័ត៌មានពីការរួមចំណែកដល់ប្រទេសនីមួយៗត្រូវត្រៀមរៀបចំដើម្បីចូលរួមសម្រេចរបៀបវារៈសកលនេះទៅតាមស្ថានភាពដើមគ្រារៀងៗខ្លួន។ វិទ្យាស្ថានស្ថិតិរបស់យូណេស្កូ (UIS) និងក្រុមរៀបចំរបាយការណ៍ GEM បានខិតខំកៀរគរកម្លាំងសហគមន៍អន្តរជាតិ ដើម្បីសម្រេចទិសដៅនេះ។ បន្ទាប់ពីមានការជ្រើសរើសយកសូចនាករ SDG ទី ៤ ចំនួន ៧ ធ្វើជាចំណុចដៅកាលពីឆ្នាំ ២០១៩ និងអនុសាសន៍នៃសេចក្តីប្រកាសដែលត្រូវបានដាក់ចេញក្នុងកិច្ចប្រជុំសកលស្តីពីការអប់រំកាលពីខែតុលា ឆ្នាំ ២០២០ ដើម្បីពន្លឿនវឌ្ឍនភាព និងលើកស្ទួយនូវចំណុចដៅពាក់ព័ន្ធដែលមានលក្ខណៈប្រាកដនិយមសម្រាប់សូចនាករសំខាន់ៗនៃគោលដៅ SDG ទី៤ ប្រទេសនានាត្រូវបានស្នើឱ្យផ្ញើតម្លៃនៃចំណុចដៅថ្នាក់ជាតិរបស់ខ្លួនឱ្យបានមុនខែតុលា ឆ្នាំ ២០២១ សម្រាប់ចំណុចដៅឆ្នាំ ២០២៥ និង ២០៣០។ ក្នុងចំណោមប្រទេសទាំងនេះមានប្រទេសចំនួន ៣៩% បានផ្ញើព័ត៌មានអំពីតម្លៃនៃចំណុចដៅទាំងនេះ។ ប្រទេស ១០% ទៀតសន្យាថានឹងផ្ញើផ្ញើព័ត៌មានមកឱ្យ ខណៈពេលដែលប្រទេស ១៤% បន្ថែមទៀត គឺជាសមាជិកនៃសហគមន៍អឺរ៉ុប និងសហគមន៍ការីបៀន ដែលបានបង្កើតជាចំណុចដៅថ្នាក់តំបន់រួចទៅហើយ (រូបភាពទី ៣)។

ព័ត៌មានអំពីតម្លៃដើមគ្រា និងតម្លៃចំណុចដៅថ្នាក់ជាតិ ដែលត្រូវបានដាក់សម្រាប់ឆ្នាំ ២០២៥ និង ២០៣០ ឥឡូវនេះមាននៅក្នុងមណ្ឌលព័ត៌មានអប់រំសកល (Global Education Observatory) ជាច្រកទ្វារថ្មីសម្រាប់ទិន្នន័យពាក់ព័ន្ធនឹងការអប់រំ។ នៅដើមឆ្នាំ ២០២២ វិទ្យាស្ថានស្ថិតិយូណេស្កូ (UIS) និងរបាយការណ៍ពិនិត្យតាមដានការអប់រំសកលនឹងចេញផ្សាយរបាយការណ៍ដើមគ្រាមួយ ដែលធ្វើការវិភាគលើលទ្ធផលនៃដំណើរការនេះ។ របាយការណ៍នេះនឹងបង្ហាញថាតើប្រទេស តំបន់ និងពិភពលោកទាំងមូលបំណងចង់ដើរដល់កម្រិតណា។ នឹងមានការរៀបរាប់ដោយសង្ខេបពីដំណើរការ ដើម្បីជួយឱ្យប្រទេសនានា កំណត់ចំណុចដៅអប់រំក្នុងករណីដែលចំណុចដៅទាំងនេះ នៅមានការខ្វះចន្លោះ ហើយក្នុងករណីដែលពាក់ព័ន្ធក៏នឹងមានការឆ្លុះបញ្ចាំងពីផលប៉ះពាល់ដែលអាចកើតមានដោយសារជំងឺកូវីដ ១៩ មកលើការសម្រេចតាមចំណុចដៅរបស់ជាតិផងដែរនៅពេលដែលមានទិន្នន័យថ្មីៗបន្ថែមទៀត។

រូបភាពទី ៣៖

ក្នុងចំណោមប្រទេសចំនួន ៣ មាន ២ ប្រទេសដែលបានចូលរួមក្នុងដំណើរការកំណត់ចំណុចដៅសម្រាប់គោលដៅអភិវឌ្ឍន៍ដោយចីរភាពទី ៤

ភាគរយនៃប្រទេសបែងចែកតាមស្ថានភាពនៃការផ្ញើរបាយការណ៍ស្តីពីចំណុចដៅថ្នាក់ជាតិ សម្រាប់ SDG ទី ៤ ត្រឹមខែតុលា ឆ្នាំ ២០២១



ប្រភព៖ ក្រុមរៀបចំរបាយការណ៍របស់ UIS និង GEM

EU = សហភាពអឺរ៉ុប, CARICOM = សហគមន៍ការីបៀន

ជំងឺកូវីដ ១៩

ជំងឺកូវីដ ១៩ បានបង្កផលប៉ះពាល់ដល់លទ្ធភាពសម្រេចគោលដៅទី ៤ និងមធ្យោបាយសម្រាប់ពិនិត្យតាមដានវឌ្ឍនភាព

ជំងឺកូវីដ ១៩ គឺជាវិបត្តិដ៏ធ្ងន់ធ្ងរបំផុតមិនធ្លាប់មានមកលើប្រព័ន្ធអប់រំក្នុងសកលលោក។ ចន្លោះពីខែមីនា ឆ្នាំ ២០២០ ដល់ខែតុលា ឆ្នាំ ២០២១ រយៈពេលដែលសាលារៀនត្រូវបានបិទទ្វារទាំងស្រុង គឺស្មើនឹង ២៨% នៃចំនួនថ្ងៃសិក្សាសរុប និងបិទទ្វារចោះៗស្មើនឹង ២៦% នៃចំនួនថ្ងៃសិក្សាសរុប។ បញ្ហាកើតឡើងខ្ពស់បំផុតនៅក្នុងខែមេសា ឆ្នាំ ២០២០ (៩៥%)។ ចន្លោះពីខែកញ្ញា ឆ្នាំ ២០២០ ដល់ខែសីហា ឆ្នាំ ២០២១ សាលារៀនត្រូវបានបិទទ្វារដោយអន្លើ ក្នុងរយៈពេលស្មើនឹងពាក់កណ្តាលនៃចំនួនថ្ងៃសិក្សា (**រូបភាពទី ៤**)។ ប្រទេសជាច្រើនដាក់ចំណាត់ថ្នាក់ថាសាលារៀនរបស់ខ្លួនបើកដំណើរការដោយអន្លើ សូម្បីតែសាលារៀនភាគច្រើនត្រូវបានបិទទ្វារក៏ដោយ។

ស្ថិតិ SDG ទី ៤ ផ្លូវការភាគច្រើន គឺជាស្ថិតិសម្រាប់ឆ្នាំ ២០១៩ និងឆ្លុះបញ្ចាំងពីស្ថានភាពមុនពេលដែលមានការរាតត្បាតជាសកលកើតមានឡើង។ ការវាយតម្លៃដែលធ្វើឡើងដោយ UIS លើអង្គភាពផែនការរបស់ក្រសួងអប់រំចំនួន ១២៩ ចន្លោះពីខែមិថុនាដល់ខែកញ្ញាឆ្នាំ ២០២០ បានរកឃើញថា អង្គភាព ២ ភាគ ៣ ត្រូវពន្យាពេលប្រមូលទិន្នន័យ ឬផ្អាកហូតដល់ឆ្នាំសិក្សាគិតបន្ទាប់ ខណៈពេលដែលពួកគេទទួលរងផលប៉ះពាល់ក្នុងកម្រិតមធ្យម ឬធ្ងន់ធ្ងរដោយមិនអាចបំពេញតាមលក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងការរាយការណ៍បាន។ ការធ្វើការអង្កេតក៏រងផលប៉ះពាល់ធ្ងន់ធ្ងរផងដែរក្នុងអំឡុងពេលនៃការរាតត្បាតជាសកលនេះ។

កម្មវិធីអង្កេតតាមខ្នងផ្ទះជាទ្រង់ទ្រាយធំមួយចំនួនត្រូវបានប្តូរទៅធ្វើតាមទូរស័ព្ទវិញ។ ប៉ុន្តែការអង្កេតជាង ២៥ លើកដែលគ្រោងធ្វើ ឬកំពុងធ្វើរួចទៅហើយក្នុងឆ្នាំ ២០២០ ត្រូវជួបប្រទះនឹងមានភាពយឺតយ៉ាវដុំវិញការចុះប្រមូលទិន្នន័យ។ លទ្ធផលនៃការអង្កេតនេះ ក៏ត្រូវធ្វើការពិចារណាពីពេលដែលការចុះប្រមូលទិន្នន័យដាក់ស្តែងត្រូវបានធ្វើឡើង និងថាតើសាលារៀនដែលនៅក្បែរខាងបើកដំណើរការដែរឬទេកាលពីពេលនោះ។ លើសពីនេះទៀងតម្លៃលើលទ្ធផលសិក្សារបស់សិស្សក៏រងផលប៉ះពាល់ផងដែរ។ ឧទាហរណ៍ កម្មវិធីវាយតម្លៃសិស្សអន្តរជាតិ (PISA) ជុំឆ្នាំ ២០២១ ត្រូវពន្យារពេល ១ ឆ្នាំ។

ភាពចម្រុះនៃប្រភពព័ត៌មានគួបផ្សំនឹងការប្រើប្រាស់វិធីសាស្ត្រសំណាកពេលវេលានៃការអង្កេត និងបរិបទនៃការអង្កេតខុសៗគ្នា មានន័យថាកិច្ចការប្រមូលទិន្នន័យពិពណ៌នាដុំវិញផលប៉ះពាល់នៃជំងឺកូវីដ ១៩ នៅតែជាការលំបាក។ នៅក្នុងករណីដែលពុំមានទិន្នន័យរដ្ឋបាល ការអង្កេតក្នុងប្រទេសអេត្យូពី ហ្គាណា និងសេណេហ្គាល់ ផ្តល់នូវព័ត៌មានបឋម ដែលបង្ហាញថាកុមារបានវិលត្រឡប់ទៅកាន់សាលារៀនវិញបន្ទាប់ពីសាលារៀនបើកដំណើរការជាថ្មី បើទោះជាការកើនឡើងនៃអត្រាត្រួតថ្នាក់ អាចមាននយ័ថាគេមានតែពន្យាពេលបោះបង់ចោលការសិក្សា។

ក្តីបារម្ភធំៗចំនួន ២ រួមមានផលប៉ះពាល់នៃការអាក់ខានវិបត្តិនេះមកលើការរៀនសូត្រ និងការបែងចែកមិនស្មើគ្នានៃផលប៉ះពាល់អវិជ្ជមានមកលើការសិក្សារៀនសូត្រ និងផលប៉ះពាល់ផ្សេងទៀតមកលើអ្នកសិក្សាដែលកាន់តែជួបការលំបាក។

នៅក្នុងសកលលោកទាំងមូល ក្នុងចំណោមសិស្ស ៣ នាក់មានតែម្នាក់ប៉ុណ្ណោះ ដែលមានអ៊ីនធឺណិតប្រើប្រាស់ ហើយក្នុងចំណោមកុមារដែលមានជីវភាពក្រីក្របំផុត ៦ នាក់ មានតែម្នាក់ប៉ុណ្ណោះដែលមានអ៊ីនធឺណិតប្រើប្រាស់។ ដូច្នេះ គំរូសិក្សាពីចម្ងាយដែលមានប្រសិទ្ធភាពបំផុត បានផាត់ចេញអ្នកសិក្សាភាគច្រើនលើសលុប ហើយកិច្ចខិតខំប្រឹងប្រែងពង្រីកទម្រង់នៃការសិក្សាបែបនេះអាចប៉ះពាល់ដល់សមធម៌ក្នុងរយៈពេលពីខ្លីទៅមធ្យម។ ការប្រើប្រាស់កម្មវិធីសិក្សាតាមឧបករណ៍ចល័ត ដែលកន្លងមកបានទទួលការចាប់អារម្មណ៍យ៉ាងច្រើនពីប្រព័ន្ធផ្សព្វផ្សាយ គឺជាគោលវិធីរៀនពីចម្ងាយដែលគេប្រើប្រាស់តិចតួចជាងគេ នេះបើតាមការអង្កេតលើប្រទេសអាហ្វ្រិកសាប់សាហារ៉ាចំនួន ៦ ពោលគឺគោលវិធីសិក្សាបែបនេះត្រូវបានប្រើប្រាស់ដោយកុមារមិនលើសពី ១៧% ឡើយនៅក្នុងប្រទេសនីហ្សេរីយ៉ា និង ១២% នៅក្នុងប្រទេសអេត្យូពី និងស្ទើតែគ្មានកុមារណាប្រើប្រាស់ឡើយក្នុងប្រទេសប៊ូគីណាហ្វាសូ ម៉ាឡាវី ម៉ាលី និងអ៊ូហ្គង់ដា។

ផលប៉ះពាល់មកលើការសិក្សា គឺអាស្រ័យលើរយៈពេលនៃការបិទទ្វារសាលារៀន ទម្រង់ដែលប្រើប្រាស់សម្រាប់ការរៀនសូត្រពីចម្ងាយ និងកម្រិតនៃការផ្តល់ការគាំទ្រដល់សិស្ស ដែលទាំងអស់នេះមានការប្រែប្រួលខុសៗគ្នា រវាងប្រទេសមួយ និងប្រទេសមួយ និងរវាងតំបន់មួយៗ និងតំបន់មួយនៅក្នុងប្រទេសតែមួយ។ ការសិក្សាភាគច្រើនត្រូវបានធ្វើឡើងក្នុងប្រទេសចំណូលខ្ពស់។ បើគិតជាមធ្យមក្នុងប្រទេសចំនួន ៧ ការបាត់បង់ការរៀនសូត្រស្មើនឹងសមមូល ៣០% នៃ មួយឆ្នាំសិក្សាសម្រាប់មុខវិជ្ជាគណិតវិទ្យា និង ៣៥% សម្រាប់មុខវិជ្ជាអំណាន គិតជាមធ្យម ប្រសិនបើសាលារៀនបិទទ្វារយៈពេល ៨ សប្តាហ៍។ ប៉ុន្តែនៅក្នុងប្រទេសបារាំងលទ្ធផលផ្នែកអំណាន និងគណិតវិទ្យាមានភាពល្អប្រសើរទៅវិញសម្រាប់សិស្សថ្នាក់ទី ៦។

កស្តុតាងបង្ហាញយ៉ាងច្បាស់ថាផលប៉ះពាល់មានការប្រែប្រួលខុសៗគ្នាទៅតាមស្ថានភាពសង្គមសេដ្ឋកិច្ច។ នៅសហរដ្ឋអាមេរិក ការវិភាគលើអត្រាប្រឡងជាប់របស់សិស្សថ្នាក់ទី ៣ ដល់ទី ៨ ក្នុងរដ្ឋចំនួន ១២ បានបង្ហាញថាការប្តូរពីរបៀបប្រឡងដែលត្រូវអង្គុយនៅទីតាំងផ្ទាល់ ទៅជាប្រើប្រាស់ទម្រង់ហាយប្រីដ (hybrid) ទាំងស្រុង ឬការប្រឡងតាមប្រព័ន្ធអនឡាញ ធ្វើឱ្យផលប៉ះពាល់អវិជ្ជមានកាន់តែមានការកើនឡើងគិតជាមធ្យម គឺ ១០ ភាគរយចំណុចសម្រាប់មុខវិជ្ជាគណិតវិទ្យា និង ៤ ភាគរយចំណុចសម្រាប់មុខវិជ្ជាអង់គ្លេស។ ការប្តូរទៅប្រើប្រាស់ទម្រង់បែបហាយប្រីដ ឬទម្រង់តាមប្រព័ន្ធអនឡាញធ្វើឱ្យអត្រាប្រឡងជាប់ថយចុះ ៤ ភាគរយចំណុចសម្រាប់ស្រុកដែលពុំមានសិស្សស្បែងខ្មៅ ឬសិស្សហ៊ីស្ពែនិក ប៉ុន្តែមានហូតដល់ ៩ ភាគរយចំណុចសម្រាប់សិស្សស្បែកខ្មៅ និងសិស្សហ៊ីស្ពែនិក មានហូតដល់ ៥០% នៃចំនួនសិស្សសរុប។

លើសពីនេះ ក៏មិនសូវមានការរង្វាយតម្លៃលើលទ្ធផលនៃការសិក្សាដោយផ្ទាល់ក្នុងប្រទេសចំណូលទាប និងចំណូលមធ្យមផងដែរនៅទីក្រុងសៅប៉ូឡូ ប្រទេសប្រេស៊ីល សិស្សមធ្យមសិក្សារៀនបានត្រឹមតែ ២៧,៥% នៃអ្វីដែលពួកគេត្រូវរៀនក្នុងសាលា ប្រសិនបើពុំមានការរាតត្បាតជាសកលតែប៉ុណ្ណោះ។ សិស្សដែលសាលារៀនរបស់ខ្លួនបានបើកដំណើរការដោយថ្មីបាត់បង់ការរៀនសូត្រក្នុងកម្រិតតិចជាង។ នៅក្នុងប្រទេសកូឡុំប៊ៀ សិស្សទទួលបានពិន្ទុតិចជាងឆ្នាំមុន ៥ ពិន្ទុ ដែលស្មើនឹង ១ ភាគ ៤ នៃឆ្នាំសិក្សា។ នៅអាហ្វ្រិកខាងត្បូងសិស្សថ្នាក់ទី ២ និងថ្នាក់ទី ៤ បាត់បង់ការសិក្សាចន្លោះពី ៥៧% និង ៨១% នៃបំណិនអំណានរយៈពេល ១ ឆ្នាំក្នុងឆ្នាំ ២០២០ បើធៀបនឹងលទ្ធផលមុនពេលមានការរាតត្បាតជាសកល។

របាយការណ៍ស្តីពីស្ថានភាពប្រចាំឆ្នាំនៃការអប់រំ ដែលជាការវាយតម្លៃមួយដឹកនាំធ្វើដោយប្រជាពលរដ្ឋនៅអាស៊ីខាងត្បូងបង្ហាញថាកម្រិតនៃការសិក្សាមានការថយចុះនៅដំបូងៗ។ នៅរដ្ឋហ្គាណាតាកា ដែលជារដ្ឋជនបទមួយរបស់ប្រទេសឥណ្ឌា ភាគរយអ្នកដែលចេះអានអំណានសម្រាប់សិស្សថ្នាក់ទី ២ មានការថយចុះក្នុងចំណោមសិស្សនៅគ្រប់កម្រិតថ្នាក់ ប៉ុន្តែការថយចុះនេះកើតឡើងធ្ងន់ធ្ងរបំផុតក្នុងចំណោមសិស្សរៀនថ្នាក់ទី ៤ (ពី ៣៣% មក ១៨%) ចន្លោះពីឆ្នាំ ២០១៨ និងឆ្នាំ ២០២០។ នៅប្រទេសប៉ាគីស្ថានការអង្កេតលើស្រុកចំនួន ១៦ បានរកឃើញពីការបាត់បង់ការសិក្សា ស្រដៀងគ្នានេះដែរសម្រាប់ជំនាញជាមូលដ្ឋានថ្នាក់ទី ១ និងថ្នាក់ទី ៣ ប៉ុន្តែពុំមានការបាត់បង់បែបនេះសម្រាប់ថ្នាក់ទី ៥ ឡើយ។

កស្តុតាងផ្សេងៗគ្នាទាំងនេះ នៅពេលយកមកផ្គុំបគ្នា បញ្ជាក់ថាការបិទសាលារៀនបង្កផលប៉ះពាល់អវិជ្ជមានមកលើការរៀនសូត្ររបស់សិស្ស។ ប្រសិនបើគេឱ្យនិយមន័យការខាតបង់បែបនេះគិតជាកម្រិតស្តង់ដ៏នាញអប្បរមា ដូចដែលបានកំណត់នៅក្នុងគោលដៅ SDG ទី ៤ ផលប៉ះពាល់នៅក្នុងប្រទេសចំណូលមធ្យមអាចមានច្រើនជាងនៅក្នុងប្រទេសដែលមានចំណូលទាប ដែលកម្រិតដំបូងមានកម្រិតទាបរួមទៅហើយ ឬក្នុងប្រទេសចំណូលខ្ពស់ដែលសាលារៀនបន្តបិទទ្វារតែក្នុងរយៈពេលខ្លី ហើយសិស្សមានឱកាសច្រើនក្នុងការរៀនតាមអនឡាញ។ ទោះជាយ៉ាងណាក៏ដោយ មានចំណុចជាច្រើនដែលគេនៅមិនទាន់ដឹងរហូតដល់ពេលនេះ ដូចជាថាតើកម្រិតនៃការសិក្សានឹងត្រឡប់មកវិញ ឬថាតើជំងឺកូវីដ ១៩ នឹងបង្កផលប៉ះពាល់រយៈពេលវែងលើការរៀនសូត្រដែរឬទេ។

ដើម្បីបន្ធូរបន្ថយផលវិបាកទាំងនេះ សាលារៀនបានបន្ថែម ឬកែសម្រួលឆ្នាំសិក្សា និងបានផ្តល់អាទិភាពដល់ផ្នែកខ្លះនៃកម្មវិធីសិក្សា ឬដល់ជំនាញមួយចំនួន។ ប្រទេស ២ ភាគ ៣ បានរាយការណ៍ថាបានអនុវត្តវិធានការផ្តល់ការបង្រៀនបំប៉នបន្ថែមសម្រាប់សិស្សបឋមសិក្សា និងមធ្យមសិក្សា។ នៅក្នុងប្រទេសហ្វីលីពីន ក្រសួងអប់រំបានចេញគោលការណ៍ណែនាំឱ្យរៀបចំថ្នាក់បំប៉នរយៈពេល ៦ សប្តាហ៍សម្រាប់សិស្សដែលទទួលបានពិន្ទុទាបជាង ៧៥% នៃការធ្វើតេស្តចុងឆ្នាំ។ កម្មវិធីបំប៉នបន្ថែមថ្នាក់ជាតិនៅក្នុងប្រទេសអង់គ្លេស (ចក្រភពអង់គ្លេស) ផ្តល់ការបង្រៀនបំប៉នបន្ថែមរយៈ ១៥ ម៉ោង ដល់សិស្សជួបការលំបាករហូតដល់ ៦ លាននាក់។


ការរាតត្បាតជាសកលក៏បង្កផលប៉ះពាល់ដែលធ្លាប់កើតមានឡើងដល់**គ្រូបង្រៀន**ផងដែរ។ នៅពេលដែលបិទទ្វារសាលារៀន គេដឹងថាគ្រូជាច្រើននាក់ពុំបានត្រៀមខ្លួនប្តូរទៅបង្រៀនពីចម្ងាយឡើយ ពួកគេក៏ពុំប្រាកដប្រជាជាមួយនឹងតួនាទីរបស់ពួកគេ ហើយក៏មិនចេះប្រើបច្ចេកវិទ្យាទៅទៀត។ នៅក្នុងការអង្កេតមួយជាមួយនឹងគ្រូបង្រៀនជាង ២០.០០០ នាក់ក្នុងប្រទេសចំនួន ១៦៥ អ្នកឆ្លើយតប ៣៩% បានឡើងឡើងថាសុខមាលភាពផ្លូវកាយ ផ្លូវចិត្ត និងផ្លូវអារម្មណ៍ របស់ពួកគេទទួលរងផលប៉ះពាល់ក្នុងអំឡុងពេលនៃការរាតត្បាតជាសកលនេះ។ ម្យ៉ាងវិញទៀតអ្នកឆ្លើយតប ៥០% បានលើកឡើងថា ពួកគេនៅតែមានទឹកចិត្តចង់បំពេញវិជ្ជាជីវៈរបស់ពួកគេ។ បែតិ្តនេះនាំឱ្យមានការលេចចេញនូវសំណួរអំពីការផ្លាស់ប្តូរដែលចាំបាច់ពាក់ព័ន្ធនឹងការអប់រំគ្រូ។ ក្រៅតែពីចំណេះដឹងផ្នែកបច្ចេកវិទ្យា គ្រូចាំបាច់ត្រូវឆ្លើយតបចំពោះតម្រូវការចិត្តសង្គម និងតម្រូវការនៃការសិក្សារៀនសូត្ររបស់សិស្សផងដែរ។

ការអប់រំសម្រាប់**ការអភិវឌ្ឍដោយចីរភាព** និង**ភាពជាពលរដ្ឋសកល** គឺជាការឆ្លើយតបចំពោះបញ្ហាប្រឈមរបស់ផែនដី ដែលកាន់តែមានភាពប្រទាក់ក្រឡាគ្នា ប៉ុន្តែអនាគតរបស់ផែនដីក៏ប្រឈមនឹងហានិភ័យខ្លាំងផងដែរ។ ទោះជាយ៉ាងណាក៏ដោយជំងឺកូវីដ ១៩ ទំលាយឱ្យឃើញពីការខកខានៃប្រព័ន្ធអប់រំ ក្នុងការសម្រេចនូវសាមគ្គីភាព និងភាពហុនិយម និងបង្ហាញឱ្យឃើញពីការកើនឡើងនូវវិសមភាពក្នុងប្រទេសនីមួយៗ និងរវាងប្រទេសមួយ និងប្រទេសមួយទៀត ដែលនាំឱ្យមានក្តីកង្វល់ផ្នែកសីលធម៌។ នៅក្នុងពិភពលោកមានការឆ្លើយតបជាច្រើនក្នុងទិសដៅផ្ទុយគ្នា ចាប់ពីរ៉ាក់សាំងជាតិនិយម រហូតដល់គោលនយោបាយស្តប់ជនបរទេស និងការសោយកាយជំនឿដែលពោពេញដោយការរើសអើង។ បែតិ្តកូវីដ ១៩ ក៏នាំឱ្យមានការយកចិត្តទុកដាក់ចំពោះចំណេះដឹងអំពីសុខភាពផងដែរ។

រូបភាពទី ៤:

នៅរយៈពេល ២០ ខែ សាលារៀនបានបិទទ្វារដោយអន្លើក្នុងរយៈពេលយ៉ាងហោចណាស់ស្មើនឹង ៥៥% នៃថ្ងៃសិក្សា

ភាគរយនៃចំនួនថ្ងៃទៅតាមស្ថានភាពនៃការបើកសាលារៀនបែងចែកតាមខែ ពីខែកុម្ភៈ ឆ្នាំ ២០២០ ដល់ខែតុលាឆ្នាំ ២០២១



ប្រភព៖ UIS (2021c).

ផលប៉ះពាល់គិតប្រាកដនៃការបិទទ្វារសាលារៀន និងការបើកដំណើរការសាលារៀនឡើងវិញមកលើស្ថានភាពនៃការឆ្លងជំងឺនៅក្នុងសហគមន៍នៅតែជាអ្វីដែលគេមិនអាចសន្និដ្ឋានបាន។ ប៉ុន្តែការកាត់បន្ថយហានិភ័យនៃការឆ្លងជំងឺឱ្យនៅតិចបំផុតក្នុង**មជ្ឈដ្ឋានសិក្សារៀនសូត្រ** ជាអ្វីដែលគេអាចធ្វើបានតាមរយៈវិធានការនានា ចាប់ពីការពាក់ម៉ាស់ ការរក្សាគម្លាត និងការលាងសម្អាតដៃ រហូតដល់ការមិនលើកទឹកចិត្តឱ្យប្រើវត្ថុរួមគ្នា និងការសម្លាប់មេរោគលើផ្ទៃដែលគេតែងប៉ះពាល់ឱ្យបានញឹកញាប់។ ជំណោះស្រាយដែលប្រើប្រាស់បច្ចេកវិទ្យាកម្រិតទាប ដើម្បីឱ្យមានខ្យល់អាកាសចេញចូលកាន់តែប្រសើរ រួមមានការប្រើប្រាស់បរិវេណនៅខាងក្រៅអាគារ និងបើកចំហបង្អួចទៅតាមដូវ។ ប្រទេសចំណូលទាបតិចជាង ១0% បានរាយការណ៍ថា បានដាក់ឱ្យអនុវត្តនូវវិធានការជាមូលដ្ឋានគ្រប់គ្រាន់ ដូចជា ដាក់សាប៊ូលាងដៃ ទឹកស្អាត ម៉ាស់ បរិក្ខាសម្រាប់ធ្វើអនាម័យបរិស្ថាន និងអនាម័យផ្ទាល់ខ្លួនឱ្យបានគ្រប់គ្រាន់ ដើម្បីធានាសុវត្ថិភាពសម្រាប់អ្នករៀនសូត្រ និងបុគ្គលិកគ្រប់រូប។ ភាគរយសម្រាប់ប្រទេសដែលមានចំណូលខ្ពស់វិញ គឺមានរហូតដល់ ៩៦% ឯណោះ។

មានកស្តុតាងថ្មីៗមួយចំនួនដែលបង្ហាញថាការរាតត្បាតជាសកលនិងផលប៉ះពាល់របស់វា ធ្វើឱ្យធនធាន**ហិរញ្ញប្បទាន**សម្រាប់ការអប់រំត្រូវរួមតូច ដោយសារតែចំណូលរបស់រដ្ឋាភិបាលមានការថយចុះផង និងដោយសារតែតម្រូវការពីវិស័យផ្សេងទៀតមានការកើនឡើងផង។ ទិន្នន័យដែល UIS ប្រមូលសម្រាប់ប្រទេសចំនួន ៧១ បង្ហាញថាភាគរយនៃចំណាយលើការអប់រំធៀបនឹងចំណាយសរុបថយចុះពី ១៤,១% ក្នុងឆ្នាំ ២០១៩ មក ១៣,៥% ក្នុងឆ្នាំ ២០២១។

សម្រាប់**ការអប់រំកុមារតូច** សូម្បីតែក្នុងករណីដែលមានការរៀនសូត្រពីចម្ងាយក៏ដោយ បញ្ហាប្រឈម រួមមាន ការខ្វះការបណ្តុះបណ្តាលគ្រូ ការកែសម្រួលការរៀនសូត្រពីចម្ងាយឱ្យស្របតាមស្ថានភាពរបស់កុមារតូចៗ ការតាមដាន និងវាយតម្លៃការអភិវឌ្ឍរបស់កុមារ និងការឆ្លើយតបចំពោះបរិស្ថាននៅតាមគ្រួសារដែលជួបការលំបាក ដែលមានទទួលបានការគាំទ្រមិនគ្រប់គ្រាន់។ ការបិទកន្លែងផ្តល់សេវាអប់រំកុមារតូច និងការមានអន្តរកម្មតិចតួចធ្វើឱ្យកុមារពុំ ទទួលបានការភ្ញោចទំនាក់ទំនងក្នុងសង្គម និងភ្ញោចផ្នែកបញ្ញានៅខាងក្រៅផ្ទះរបស់ពួកគេ។

ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈត្រូវរងផលប៉ះពាល់ដោយសារតែកម្មវិធីរហូតដល់ ៨0% ផ្អែកលើជំនាញអនុវត្ត និងជំនាញទន់ដែលអ្នកសិក្សាគួរមករៀនដោយផ្ទាល់។ ការត្រៀមរៀបចំគ្រូ គឺជាបញ្ហាដ៏ធំមួយព្រោះថាគ្រូខ្វះសមត្ថភាពផ្តល់ការរៀនសូត្រពីចម្ងាយ ក្នុងពេលកម្មវិធីអប់រំស្តង់ដារបស់ពួកគេត្រូវទទួលរងការរំខាន។ ជាការសំខាន់ណាស់ដែលគេត្រូវប្រើប្រាស់គោលវិធីច្រើនចម្រុះ និងមិនពឹងអាស្រ័យទៅលើជំណោះស្រាយដែលទាមទារឱ្យមានការប្រើប្រាស់បច្ចេកវិទ្យាកម្រិតខ្ពស់ ដើម្បីផ្តល់ការរៀនសូត្រពីចម្ងាយ។ ក្នុងពេលជាមួយគ្នាមានឧទាហរណ៍ដែលបង្ហាញពីភាពធន់ផងដែរ ពេលគឺបង្ហាញឱ្យឃើញថាការបណ្តុះបណ្តាលនៅតែបន្តផ្តល់ការគាំទ្រដល់វិស័យដែលរងផលប៉ះពាល់ខ្លាំង។

ការអប់រំនៅកម្រិតឧត្តមសិក្សាមានបទពិសោធន៍ជាមួយនឹងការរៀនសូត្រពីចម្ងាយច្រើនជាងកម្រិតអប់រំផ្សេងទៀត។ ក្នុងការអង្កេតមួយដែលធ្វើឡើងជាមួយនឹងប្រទេសចំនួន ៥៣ ប្រទេសចំនួន ៣ បានរាយការណ៍ថាបានប្តូរទៅជាអប់រំឧត្តមសិក្សាតាមប្រព័ន្ធអនឡាញទាំងស្រុង ១៩% ពឹងផ្អែកជាចម្បងលើទម្រង់នៃការអប់រំតាមអនឡាញ និង ២៨% ប្រើប្រាស់គោលវិធីបែបហាយប្រឹដ (hybrid) ពេលគឺរៀនពីចម្ងាយផង និងរៀនដោយមានការចូលរួមផ្ទាល់នៅក្នុងថ្នាក់ផង។ ប្រទេស

ដែលមានចំណូលមធ្យមចាប់ពីប្រទេសកូឡុំបៀ រហូតដល់ប្រទេសអេហ្ស៊ីប និងចាប់ពីប្រទេសចិន រហូតដល់សហព័ន្ធរុស្ស៊ី បានរៀបចំថ្នាលអនឡាញសម្រាប់គោលបំណងនេះ។ ប៉ុន្តែនៅក្នុងការអង្កេតជាមួយនឹងនិស្សិតនៅអាហ្វ្រិកសាប់សាហារ៉ាវិញ មាននិស្សិតត្រឹមតែ ៣៩% ប៉ុណ្ណោះដែលបានចុះឈ្មោះចូលរៀននៅតាមគ្រឹះស្ថានដែលផ្តល់ជម្រើសសិក្សាពីចម្ងាយ។ ក្នុងប្រទេសនៅសហភាពអឺរ៉ុបនិស្សិត ៤១% ដែលធ្វើការក្នុងអំឡុងពេលនៃការសិក្សាបានបាត់បង់ការងាររបស់ខ្លួន ដោយ ២៩% បាត់បង់បណ្តោះអាសន្ន និង ១២% បាត់បង់ជាអចិន្ត្រៃយ៍។

ទិសដៅពេញនិយមសម្រាប់និស្សិតអន្តរជាតិដែលនិយាយភាសាអង់គ្លេស ដូចជាអូស្ត្រាលី ញូសេឡែន ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក មានការថយចុះចំនួន**សិស្សដែលផ្លាស់ទី**ចូលមកក្នុងប្រទេសទាំងនេះ។ មាននិស្សិតរហូតដល់ ១ ភាគ ៣ នៅក្នុងប្រទេសអូស្ត្រាលីគឺជានិស្សិតអន្តរជាតិ នេះធ្វើឱ្យគ្រឹះស្ថានអប់រំឧត្តមសិក្សាត្រូវជួបនឹងការលំបាកធ្ងន់ធ្ងរផ្នែកហិរញ្ញវត្ថុ។ និងស្ថិត និងនិស្សិតដែលបញ្ចប់ការសិក្សាត្រូវជាប់គាំងនៅក្នុងប្រទេសដែលពួកគេទៅរៀននៅពេលដែលពួកគេត្រូវវិលត្រឡប់ទៅកាន់ប្រទេសកំណើតរបស់ពួកគេវិញ។

ជំនាញអក្ខរកម្ម និងជំនាញលេខនព្វន្តនពន្ធរបស់មនុស្សពេញវ័យមានសារៈសំខាន់ និងចាំបាច់សម្រាប់យុទ្ធនាការអប់រំអំពីចំណេះដឹងសុខភាព និងយុទ្ធនាការចាក់វ៉ាក់សាំង និងត្រូវតែជាផ្នែកមួយដ៏សំខាន់នៃការឆ្លើយតបចំពោះស្ថានភាពអាសន្នជាសាធារណៈ និងផែនការស្តារឡើងវិញ។ នៅក្នុងប្រទេសឥណ្ឌាស្ត្រីដែលចូលរួមនៅក្នុងកម្មវិធីអក្ខរកម្មមនុស្សពេញវ័យមានចំណេះដឹងអំពីជំងឺកូវីដ ១៩ ខ្ពស់ជាងស្ត្រីដែលមិនចេះអក្សរ។ លេខនពន្ធគឺជាកត្តាដែលមានសង្គតិភាពបំផុត ដែលអាចឱ្យគេទាយដឹងពីការថយចុះនៃភាពងាយរងគ្រោះដោយសារការផ្សព្វផ្សាយព័ត៌មានមិនពិតអំពីជំងឺកូវីដ ១៩។ ទោះជាយ៉ាងណាក៏ដោយ សូម្បីតែមុនពេលមានការរាតត្បាតជាសកល ការអប់រំពីចម្ងាយ គឺជាមធ្យោបាយផ្តល់កម្មវិធីអក្ខរកម្មបឋមដោយមិនមានភាពពេញនិយមនោះឡើយ។ ក្នុងប្រទេសប្រេស៊ីល លិខិតបទដ្ឋានគតិយុត្តមួយបានតម្រូវឱ្យកម្មវិធីសិក្សាកម្រិតបឋមសិក្សាត្រូវតែបង្រៀនក្នុងថ្នាក់ដោយផ្ទាល់។

ចំណុចដៅ ៤.១. ការអប់រំបឋមសិក្សា និងមធ្យមសិក្សា

មុនពេលដែលមានការរាតត្បាតជាសកលកុមារ ក្មេងជំទង់ និងយុវជនដែលដល់វ័យចូលរៀននៅសាលាបឋមសិក្សា និងមធ្យមសិក្សាចំនួន ២៦០ លាននាក់ស្ថិតនៅក្រៅសាលា។ តួលេខនេះមិនបានប្រែប្រួលឡើយក្នុងរយៈពេលមួយទសវត្សរ៍នេះ។ គម្រោងសហការរវាងរបាយការណ៍ GEM និង UIS កំពុងត្រូវបានអនុវត្ត ដើម្បីធ្វើសមាហរណកម្ម និងផ្ទៀងផ្ទាត់ទិន្នន័យដែលបានពីប្រភពរដ្ឋបាល និងពីការអង្កេតខ្នងផ្ទះ បំពេញចំណុចខ្វះខាតនៃទិន្នន័យរដ្ឋបាល និងចងក្រងចេញជាស៊េរីទិន្នន័យតាមពេលវេលាដែលមានភាពប្រទាក់ក្រឡាគ្នា។ គម្រោងនេះមានមូលដ្ឋានលើការងាររបស់ក្រុមរៀបចំរបាយការណ៍ GEM ដែលបានប្រមូលផ្តុំទិន្នន័យពីប្រភពចម្រុះ ដើម្បីធ្វើការប៉ាន់ប្រមាណពីអត្រាបញ្ចប់ការសិក្សា។គេហទំព័រថ្មីមួយ(www.education-estimates.org)ជួយឱ្យអតិក្រមនេះកាន់តែងាយស្រួលយកទៅប្រើប្រាស់សម្រាប់បណ្តាប្រទេសនានា។ អត្រាបញ្ចប់ការសិក្សានៅកម្រិតបឋមសិក្សាមានជិត ឬលើសពី ៩០% ក្នុងគ្រប់តំបន់ទាំងអស់ លើកលែងតែអាហ្វ្រិកសាប់សាហារ៉ា ដែលក្នុងចំណោមកុមារ ៣ នាក់មានតែ ២ នាក់ប៉ុណ្ណោះដែលបានរៀនចប់កម្រិតបឋមសិក្សា បើទោះជាអត្រានេះកើនឡើងពី ៦៥% ដល់ ៧៦% ប្រសិនបើគេបញ្ចូលសិស្សដែលរៀនដល់ថ្នាក់ចុងក្រោយយឺតជាងគេផងនោះ (**រូបភាពទី ៥**)។ នៅអាហ្វ្រិកសាប់សាហារ៉ា កុមាររៀននៅសាលាបឋមសិក្សា ២៣% និងក្មេងជំទង់ដែលរៀននៅសាលាមធ្យមសិក្សាបឋមភូមិ ៣១% ជាសិស្សលើសអាយុក្នុងកម្រិតមួយគួរឱ្យកត់សម្គាល់ ដែលពន្យល់ពីមូលហេតុដែលតំបន់នេះមានគម្លាតធំជាងគេ រវាងអត្រាបញ្ចប់ការសិក្សាសមស្របតាមអាយុ និងអត្រាបញ្ចប់ការសិក្សាសម្រាប់សិស្សដែលលើសអាយុ។

នៅក្នុងសំណុំទិន្នន័យសកលនៃបណ្តាប្រទេសដែលត្រូវបានគ្របដណ្តប់ដោយនិន្នាការនៃការសិក្សាមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រជាអន្តរជាតិ (TIMSS) កំណើនប្រចាំឆ្នាំគិតជាមធ្យមចន្លោះពីឆ្នាំ ២០១៥ ដល់ ២០១៩ នៃភាគរយសិស្សដែលសម្រេចកម្រិតស្ទាត់ជំនាញអប្បរមាគឺ ០,៣ ភាគរយចំណុចសម្រាប់ថ្នាក់ទី ៤ និង ០,៥ ភាគរយចំណុចសម្រាប់សម្រាប់ថ្នាក់ទី ៨។ ប្រទេសដែលសម្រេចបានលើសពីមធ្យមភាគទាំងនេះ រួមមានឈីលី ដែលភាគរយនេះកើនឡើងពី ៤១% ក្នុងឆ្នាំ ២០០៣ ដល់ ៥៧% ក្នុងឆ្នាំ ២០១១ និង ៧០% ក្នុងឆ្នាំ ២០១៩ ដែលអត្រាកំណើននេះ គឺលឿនជាងអត្រាគិតជាមធ្យមយ៉ាងហោចណាស់ ៣ ដង។ នៅតាមប្រទេសដទៃទៀត ដូចជានៅចូដង់ និងរ៉ូម៉ានៀជាដើម មានកំណើនតិចតួច ឬគ្មានកំណើនសោះតែម្តង។ ការផ្តល់សេវាដល់អ្នកដែលនៅចុងក្រោយគេ ១០% គឺជាការលំបាក សូម្បីតែក្នុងបរិបទដែលមានធនធានច្រើនក៏ដោយ។ នៅសហរដ្ឋអាមេរិក កាលពីឆ្នាំ ១៩៩៥ មានសិស្សត្រឹមតែ ៨៦% ប៉ុណ្ណោះ ដែលសម្រេចតាមចំណុចដៅអន្តរជាតិកម្រិតទាបនៃ TIMSS ហើយភាគរយនេះមាន ៨៧% ក្នុងឆ្នាំ ២០១៩។ នៅប្រទេសញូហ្សេលែន ភាគរយនេះមានការថយចុះជាបន្តបន្ទាប់ពី ៨៩% ក្នុងឆ្នាំ ១៩៩៥ មកនៅ ៨២% ក្នុងឆ្នាំ ២០១៩។


ចំណុចដៅ ៤.២. ការអប់រំកុមារតូច

ទិន្នន័យនៃសន្ទុះអភិវឌ្ឍន៍កុមារតូចសម្រាប់កុមារអាយុពី ៣៦ ដល់ ៥៩ ខែបង្ហាញថាគម្លាតទ្រព្យធនភាគច្រើននៅទ្រឹង ឬមានការកើនឡើង។ វិធីសាស្ត្រដែលប្រើប្រាស់សម្រាប់សូចនាករនេះ ដែលប្រមូលទិន្នន័យអំពីភាគរយរបស់កុមារតូចដែលមានការអភិវឌ្ឍស្របតាមអាយុរបស់ពួកគេ ដូចជាការអភិវឌ្ឍន៍ផ្នែកសុខភាព ការរៀនសូត្រ និងសុខមាលភាពចិត្តសង្គម ត្រូវបានគេធ្វើបច្ចុប្បន្នភាពយ៉ាងម៉ត់ចត់។ ការរៀនសូត្រចាប់ផ្តើមពីក្នុងផ្ទះ។ ក្នុងឆ្នាំ ២០១២ ដល់ឆ្នាំ ២០១៩ កុមារ ៦២% ចូលរួមក្នុងសកម្មភាពចាប់ពី ៤ ឡើងទៅ ដែលរៀបចំដោយមនុស្សពេញវ័យនៅក្នុងផ្ទះ នៅក្នុងប្រទេសដែលមានចំណូលទាប និងមធ្យម។ ភាគរយគឺទាបជាង ២០% នៅក្នុងប្រទេស ហ្គាំប៊ៀ សេរ៉ាឡេអូន និងតូហ្គោ។ ឧបសគ្គដ៏សំខាន់មួយដែលធ្វើឱ្យគេមិនអាចជួយភ្ជាប់កុមារ ដូចជាការអានរួមគ្នាជាមួយនឹងកុមារ ជាដើម គឺភាពអាចរកបាននៃសៀវភៅ។ គិតជាមធ្យមកុមារអាយុក្រោម ៥ ឆ្នាំ ក្រោម ១ ភាគ ៤ មានសៀវភៅយ៉ាងហោចណាស់ ៣ ក្បាលនៅផ្ទះ។ ក្នុងប្រទេសចំនួន៣ក់កណ្តាលក្នុងចំណោមកុមារ ១០ នាក់មានកុមារក្រោមម្នាក់ដែលមានសៀវភៅ ៣ ក្បាលនៅផ្ទះ ដោយឡែក

រូបភាពទី ៥៖

សូចនាករដែលបង្ហាញពីការបញ្ចប់ការសិក្សាសមស្របតាមអាយុ ធ្វើការប៉ាន់ប្រមាណមិនដល់កម្រិតជាក់ស្តែងនៃចំនួនកុមារដែលចុងក្រោយពិតជាបានបញ្ចប់ការសិក្សាឡើយ ជាពិសេសនៅអាហ្វ្រិកសាប់សាហារ៉ា

អត្រាបញ្ចប់ការសិក្សា និងការបញ្ចប់ការសិក្សាពិតប្រាកដ បែងចែកតាមតំបន់ ២០០០–២០



ប្រភព៖ ការវិភាគដែលធ្វើឡើងដោយក្រុមរៀបចំរបាយការណ៍ GEM ដោយប្រើប្រាស់ទិន្នន័យអង្កេតខ្នងផ្ទះ។

នៅក្នុងប្រទេសចំនួន ៨ នៅអាហ្វ្រិកសាប់សាហារ៉ា មានកុមារមិនដល់ ១% ប៉ុណ្ណោះដែលមានសៀវភៅយ៉ាងហោចណាស់ ៣ ក្បាលនៅផ្ទះ។

សិទ្ធិទទួលបានការអប់រំ ចាប់ផ្តើមពីកំណើត។ រហូតដល់ពេលដែលកុមារអាយុបាន ៣ ឆ្នាំ ខួរក្បាលរហូតដល់ ៩០% បានអភិវឌ្ឍន៍។ ការចូលរួមរបស់កុមារអាយុក្រោម ៣ ឆ្នាំក្នុងកម្មវិធីគាំពារ និងអប់រំកុមារតូចច្រើនតែនៅមានកម្រិត បើទោះជានៅតាមប្រទេសចំណូលមធ្យម និងចំណូលខ្ពស់ជាច្រើន កម្មវិធីនេះបានគ្របដណ្តប់ដល់កុមារអាយុពី ០ ដល់ ១ ឆ្នាំបាន ២០% និងកុមារអាយុ ២ ឆ្នាំបាន ៦០% ក៏ដោយ។ សូម្បីតែនៅក្នុងប្រទេសដែលមានចំណូលខ្ពស់ ការទទួលបានសេវាគាំពារ និងអប់រំកុមារតូចនៅអាស្រ័យតាមស្ថានភាពសង្គមសេដ្ឋកិច្ចរបស់កុមារក្នុងកម្រិតខ្ពស់នៅឡើយ។ នៅក្នុងប្រទេសបារាំង និងអៀឡង់ ភាពខុសគ្នានៃការចូលរួមរវាងកុមារអាយុពី ០ ដល់ ២ ឆ្នាំដែលមកពីគ្រួសារក្រីក្រ និងគ្រួសារដែលមានជីវភាពធូរធារ គឺមានលើសពី ៥០ ភាគរយចំណុច។ នៅក្នុងសកលលោកទាំងមូល កុមារ ៧៥% ចុះឈ្មោះចូលរៀននៅកម្រិតមត្តេយ្យសិក្សាមួយឆ្នាំមុនអាយុចូលរៀនជាផ្លូវការនៅកម្រិតបឋមសិក្សាសម្រាប់ឆ្នាំសិក្សាដែលបញ្ចប់នៅក្នុងឆ្នាំ ២០២០។ អត្រាពិតនៃការចូលរៀនដែលត្រូវបានកែសម្រួលនៅប្រទេសដែលមានចំណូលទាប (៤៥%) ស្មើត្រឹមតែពាក់កណ្តាលនៃអត្រាក្នុងប្រទេសដែលមានចំណូលខ្ពស់ (៩១%) ប៉ុណ្ណោះ។

ចំណុចដៅ ៤.៣. ការអប់រំបច្ចេកទេស វិជ្ជាជីវៈ ឧត្តមសិក្សា និងការអប់រំមនុស្សពេញវ័យ


ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) នៅតែពុំបានទទួលថវិកាគាំទ្រឱ្យបានគ្រប់គ្រាន់ ហើយជារឿយៗពុំបានទទួលការយកចិត្តទុកដាក់ឡើយ នៅក្នុងប្រទេសជាច្រើន បើទោះជាប្រទេសខ្លះដូចជាអាមេនី ប្រេស៊ីល ប៊ូរុនឌី កូស្តារីកា ឥណ្ឌូនេស៊ី និងអ៊ុយរូហ្គាយ បានបង្កើនអត្រានៃការចូលរួមក្នុងការបណ្តុះបណ្តាលប្រភេទនេះបានយ៉ាងច្រើនក្នុងរយៈពេល ១៥ ឆ្នាំចុងក្រោយនេះក៏ដោយ។ ការរៀននៅសាលាមធ្យមសិក្សាវិជ្ជាជីវៈ ហាក់បីដូចជាមិនមែនជាជម្រើសទាក់ទាញឡើយ ប្រសិនបើសញ្ញាបត្រវិជ្ជាជីវៈពុំបានផ្តល់ជាជម្រើសឱ្យគេអាចបន្តទៅរៀនដោយផ្ទាល់នៅកម្រិតឧត្តមសិក្សា ខុសពីសញ្ញាបត្រមធ្យមសិក្សាចំណេះទូទៅ ដែលនេះ គឺជាអ្វីដែលកើតមានឡើងនៅក្នុងប្រទេសចំនួន ១ ភាគ ៤។ ផ្ទុយទៅវិញនៅក្នុងប្រទេស ៣០% សិស្សដែលបានបញ្ចប់ការសិក្សាពីសាលាមធ្យមសិក្សាវិជ្ជាជីវៈទាំងអស់ សុទ្ធតែអាចចូលរៀនដោយផ្ទាល់នៅកម្រិតអប់រំឧត្តមសិក្សា។

អត្រារួមនៃការចូលរៀនក្នុងកម្រិតឧត្តមសិក្សាក្នុងសកលលោកមាន ៣៩% និងបន្តមានការកើនឡើងក្នុងកម្រិតថេរជាមធ្យមប្រមាណ ១ ភាគរយចំណុចក្នុងមួយឆ្នាំចាប់តាំងពីឆ្នាំ ២០០០ មក។ ទិន្នន័យរដ្ឋបាលទាំងនេះមិនមែនសុទ្ធតែដូចគ្នានឹងទិន្នន័យអង្កេតលើការចូលរៀននោះឡើយ (**រូបភាពទី ៦**)។ ការចុះឈ្មោះសិក្សាអាចប៉ាន់ប្រមាណមិនដល់

រូបភាពទី ៦៖

ទិន្នន័យនៃការចូលរៀននៅកម្រិតឧត្តមសិក្សាអាចប៉ាន់ប្រមាណលើស ឬប៉ាន់ប្រមាណខ្វះពីអត្រាចូលរៀនជាក់ស្តែង

អត្រារួមនៃការចូលរៀន និងសិក្សានៅកម្រិតឧត្តមសិក្សា ២០១៥-១៩



ប្រភព៖ មូលដ្ឋានទិន្នន័យ UIS

កម្រិតជាក់ស្តែងនៃការចូលរៀនរបស់សិស្ស ប្រសិនបើមានសិស្សជាច្រើនរៀននៅគ្រឹះស្ថានដែលពុំត្រូវបានរាប់ បញ្ចូលក្នុងស្ថិតិផ្លូវការ ដោយសារតែគ្រឹះស្ថានទាំងនេះខ្វះការទទួលស្គាល់ ឬការធានាគុណភាព។ ផ្ទុយទៅវិញ អត្រានៃការសិក្សាអាចប៉ាន់ប្រមាណលើសពីអត្រាចូលរៀន ប្រសិនបើសិស្សជាច្រើនបានត្រឹមតែមកចុះឈ្មោះចូលរៀន ជាពិសេសនៅក្នុងករណីដែលការបង្រៀនផ្តល់ដោយមិនគិតថ្លៃ ហើយសិស្សអាចទទួលបានឧបត្ថម្ភធនទៅតាមស្ថានភាពរបស់ពួកគេ។ លើសពីនេះ ទិន្នន័យរដ្ឋបាលមានទំនាក់ទំនងជាមួយនឹងកម្រិតអាយុណូមីណាល់ (nominal age) ៥ ឆ្នាំក្រោយអាយុបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាទុតិយភូមិ ប៉ុន្តែការសិក្សាកម្រិតឧត្តមសិក្សានៅអាយុកាន់តែច្រើនក៏ជាអ្វីដែលតែងតែកើតមានផងដែរ ជាពិសេសនៅអាហ្វ្រិកសាប់សាហារ៉ា។

បើគិតចេញពីជ្រុងរយៈពេលពេញមួយជីវិត ភាពសមស្របនៃតម្លៃសេវាអប់រំកម្រិតឧត្តមសិក្សា មិនធ្វើឱ្យសេវាអប់រំជាសេវាដែលមានតម្លៃសមស្របសម្រាប់ការបង់មុននោះឡើយ។ មានមូលហេតុសេដ្ឋកិច្ច ដើម្បីឱ្យមានការចែករំលែកចំណាយសម្រាប់ការអប់រំកម្រិតឧត្តមសិក្សា ដែលពឹងអាស្រ័យជាសំខាន់លើបេក្ខជនដែលជាក់ពាក្យចូលរៀនមិនជួបប្រទះនឹងឧបសគ្គក្នុងការទទួលបានឥណទាន។ នៅក្នុងប្រទេសជាង ៧០ មានប្រភេទកម្ចីជាច្រើនប្រភេទសម្រាប់សិស្ស ហើយទីផ្សារនេះមានការកើនឡើងរហូតដល់តម្លៃ ១ ទ្រីលានដុល្លារ។ ក្នុងប្រទេសជាច្រើន ភាគរយនៃចំណូលរបស់អ្នកខ្ចីឥណទានទាំងនេះដែលត្រូវប្រើប្រាស់សម្រាប់សងកម្ចីសម្រាប់និស្សិត មានកម្រិតច្រើនលើសលុប ជាពិសេសសម្រាប់និស្សិតបញ្ចប់ការសិក្សាដែលមានជីវភាពធូរធារតិចតួចជាងគេបំផុត។ ការកែទម្រង់គោលនយោបាយដែលល្អត្រូវតែមានងាកចេញពីការផ្តល់កម្ចីដែលមានកំណត់រយៈពេលទូទាត់ ដែលជាប្រភេទកម្ចីដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ ទៅជាកម្ចីដែលត្រូវសងទៅតាមកម្រិតនៃប្រាក់ចំណូល។

ក្នុងប្រទេសដែលមានចំណូលខ្ពស់ភាគច្រើននិយោជកគឺជាអ្នកផ្តល់សេវាធំជាងគេតែមួយគត់សម្រាប់សេវាអប់រំ និងបណ្តុះបណ្តាលមនុស្សពេញវ័យ ដែលរំលេចឱ្យឃើញពីភាពចាំបាច់ ដែលត្រូវមានគោលនយោបាយផ្តោតការយកចិត្តទុកដាក់លើបុគ្គលដែលស្ថិតនៅខាងក្រៅទីផ្សារការងារ។ សូម្បីតែសម្រាប់អ្នកដែលមានការងារធ្វើក៏ដោយ ពេលវេលាដែលត្រូវចំណាយសម្រាប់ទទួលបានការបណ្តុះបណ្តាលអាចមានសារៈសំខាន់ដូចគ្នានឹងការឧបត្ថម្ភសម្រាប់ការបណ្តុះបណ្តាលនេះផងដែរ ដែលនេះបង្ហាញពីភាពចាំបាច់ត្រូវមានអន្តរាគមន៍ជាសាធារណៈក្នុងទម្រង់ជាកម្មវិធីសម្រាប់អ្នកដែលបានចាកចេញពីការអប់រំ។ ទិន្នន័យផ្អែកតាមពេលវេលាដែលបានពីប្រទេសចំណូលខ្ពស់ចំនួន ៦ បង្ហាញថាការអប់រំមនុស្សពេញវ័យគឺជាការ

ខិតខំដែលត្រូវធ្វើជាទៀងទាត់របស់មនុស្សមួយភាគតូច ជាពិសេសក្នុងចំណោមអ្នកដែលមានការអប់រំកាន់តែខ្ពស់។

ចំណុចដៅ ៤.៤. ជំនាញសម្រាប់ការងារ

ក្នុងចំណោមប្រទេស ៩១ ដែលមានទិន្នន័យមានតែប្រទេសតែ ១០ ប៉ុណ្ណោះ ដែលរបាយការណ៍ភាគច្រើនរបស់មនុស្សពេញវ័យ បានបញ្ចូលជំនាញបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT) យ៉ាងហោចណាស់ ៥ លើ ៩ សម្រាប់តាមដាន ដើម្បីយកមកធ្វើការប្រៀបធៀបជាលក្ខណៈសកល។ ក្នុងប្រទេសប្រមាណពាក់កណ្តាលមនុស្សពេញវ័យភាគច្រើនពុំមានជំនាញឡើយ។ ក្នុងប្រទេសចំណូលទាប និងចំណូលមធ្យមភាគច្រើន មនុស្សវ័យក្មេងមួយចំនួនតូចដែលមិនបានបញ្ចប់ យ៉ាងហោចណាស់ការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិមានជំនាញ ICT អ្វីមួយ។ នៅក្នុងប្រទេសអ៊ីរ៉ាក់ ឡាវ និងសេរ៉ាឡេអូន សូម្បីតែអ្នកដែលមានការអប់រំខ្ពស់បំផុតគិតជាមធ្យមមានជំនាញតិចជាង ២ ប៉ុណ្ណោះក្នុងចំណោមជំនាញទាំង ៩។ ការមានឧបករណ៍ និងអ៊ីនធឺណិតប្រើប្រាស់ ក៏ជាឧបសគ្គមួយទៀតផងដែរ៖ សូម្បីតែក្នុងចំណោមមនុស្សអាយុពី ២០ ដល់ ២៤ ឆ្នាំមានស្ត្រី ៩៨% និងបុរស ៩០% នៅក្នុងប្រទេសឆាត ដែលរាយការណ៍ថាមិនដែលបានប្រើប្រាស់អ៊ីនធឺណិតឡើយ។ ភាគរយនេះមាន ៦១% សម្រាប់ស្ត្រី និង ៦៣% សម្រាប់បុរសនៅក្នុងប្រទេសឡាវ និង ៣៦% សម្រាប់ស្ត្រី និង ៣១% សម្រាប់បុរសនៅក្នុងប្រទេសទុយនេស៊ី។

ការគិតបែបគណនា (Computational thinking) បច្ចុប្បន្នកំពុងត្រូវបានបញ្ចូលទៅក្នុងកម្មវិធីសិក្សាជាតិ។ ប្រទេសហ្វាំងឡង់ បានតម្រូវឱ្យមានការបញ្ចូលការគិតបែបអាល់ហ្គោរីធឹម (algorithmic thinking) និងការសរសេរកម្មវិធី (programming) ទៅក្នុងកម្មវិធីសិក្សាចាប់ពីថ្នាក់ទី ១ ទៅក្នុងទម្រង់ជាសកម្មភាពអន្តរមុខវិជ្ជានៅក្នុងកម្មវិធីសិក្សា។ ក្នុងការពិនិត្យលើប្រទេសដែលមានចំណូលខ្ពស់ចំនួន ៨ កាលពីឆ្នាំ ២០១៨ សិស្សដែលប្រើបច្ចេកវិទ្យា ICT កាន់តែញឹកញាប់នៅក្នុងសាលារៀន សម្រាប់កិច្ចការដែលពាក់ព័ន្ធនឹងសាលារៀន មិនមែនសុទ្ធតែទទួលបានពិន្ទុខ្ពស់ជាងអ្នកដែលពុំបានប្រើប្រាស់បច្ចេកវិទ្យា ICT នោះឡើយ ហើយសិស្សដែលមានបទពិសោធន៍ជាមួយនឹងការសរសេរកម្មវិធីក៏មិនមែនសុទ្ធតែអាចយកជំនាញនេះមកប្រើប្រាស់ក្នុងបរិបទដែលមិនពាក់ព័ន្ធនឹងការសរសេរកម្មវិធីនោះដែរ។

ចំណេះដឹងហិរញ្ញវត្ថុ គឺជាជំនាញដ៏សំខាន់សម្រាប់ការប្រកបមុខរបរ ចិញ្ចឹមជីវិតក្នុងសេដ្ឋកិច្ចសម័យទំនើប និងសម្រាប់ជីវិតមនុស្សពេញវ័យទូទៅ ប៉ុន្តែមិនមែនគ្រប់គ្នាសុទ្ធតែមានឱកាសរៀនចេះពីបញ្ញត្តិហិរញ្ញវត្ថុសំខាន់ៗនៅសាលារៀននោះឡើយ។ កម្មវិធីវាយតម្លៃសិស្សជាអន្តរជាតិឆ្នាំ ២០១៨ មានបញ្ចូលម៉ូឌុលចំណេះដឹងហិរញ្ញវត្ថុ ក្នុងទម្រង់ជាម៉ូឌុលជាជម្រើសដែលត្រូវបានប្រព័ន្ធអប់រំចំនួន ២០ ដែលចូលរួមក្នុងកម្មវិធីនេះយកទៅប្រើប្រាស់។ ក្នុងគ្រប់ប្រទេសដែលចូលរួមក្នុងកម្មវិធីនេះទាំងអស់ក្មេងស្រីមិនសូវជាបានរាយការណ៍ពីសកម្មភាពក្នុងថ្នាក់រៀនពាក់ព័ន្ធហិរញ្ញវត្ថុឡើយ បើទោះជាការអប់រំហិរញ្ញវត្ថុជាធម្មតាត្រូវបានបញ្ចូលក្នុងមុខវិជ្ជាគណិតវិទ្យា ដែលជាទូទៅជាមុខវិជ្ជាដែលត្រូវតែរៀនក៏ដោយ។

ចំណុចដៅ ៤.៥. សមធម៌

វិសមភាពយេនឌ័រនៅតែជាក្តីបារម្ភដ៏សំខាន់មួយ បើទោះជាការយល់ពីបញ្ហាប្រឈមដែលកើតមាននៅកម្រិតផ្សេងៗ និងនៅទីកន្លែងផ្សេងៗគ្នាទាមទារឱ្យមានការដឹងពីភាពខុសប្លែកគ្នានៃកម្រិត និងទីកន្លែងទាំងនេះក៏ដោយ។ ការអប់រំនៅកម្រិតមធ្យមសិក្សាទុតិយភូមិ គឺជាកម្រិតដែលក្មេងស្រីជំទង់ត្រូវទទួលរងការចាញ់ប្រៀបធ្ងន់ធ្ងរ (ដូចជានៅក្នុងប្រទេសបេនីន ឆាត និងនីហ្សេរដើម) ប៉ុន្តែពួកគេក៏ទំនងជាទទួលបានប្រយោជន៍បន្ថែម និងមានការប្រែប្រួលយ៉ាងឆាប់រហ័សនៃស្ថានភាពទូទៅដែលផ្តល់នូវភាពល្អប្រសើរសម្រាប់ពួកគេ។ នេះកើតមានឡើងនៅក្នុងប្រទេសជាច្រើនរួមនឹងប្រទេសដែលនៅឆ្ងាយបំផុតពីការសម្រេចគោលដៅ SDG ទី ៤ បើធៀបនឹងប្រទេសដែលស្ថិតនៅក្នុងស្ថានភាពប្រហាក់ប្រហែលពួកគេនៅក្នុងតំបន់មួយចំនួន ដូចជាកម្ពុជា កុងហ្គោ ហ្គាំបៀ ហ្គាណា ម៉ាឡាវី និងរវ៉ាន់ដាជាដើម។

ទ្រព្យធនដែលគេប្រើនតែវាស់រវែងនៅកម្រិតខ្នងផ្ទះ ជានិច្চកាលមិនអាចឱ្យគេដឹងពីការជួបការខ្វះខាតរបស់កុមារឡើយ។ នៅតាមប្រទេសជាច្រើន ១០% នៃកុមារដែលជួបការខ្វះខាត គឺជាកុមារដែលស្ថិតនៅក្នុងគ្រួសារដែលជីវភាពធូរធារជាងគេ ហើយមានកុមារជាង ៣០% ដែលស្ថិតនៅក្នុងគ្រួសារក្រីក្រជាងគេមិនជួបការខ្វះខាតនៅឡើយ។ កម្រិតនៃការជួបការខ្វះខាតរបស់កុមារអាចជាកត្តាបន្ថែមមួយទៀតដែលអាចឱ្យគេព្យាករណ៍ដឹងពីលទ្ធផលនៃការអប់រំរបស់ពួកគេ។

មានកុមារក្នុងចំនួនដ៏ច្រើនដែលរៀននៅសាលារៀនដែលគ្រប់គ្រងដោយក្រុមប្រជាប់អាវុធមិនមែនរដ្ឋ។ ក្រុមទាំងនេះមានហេតុផលជាច្រើនដែលធ្វើឱ្យពួកគេសម្រេចចិត្តផ្តល់ការអប់រំ មិនថាតាមរយៈអន្តរាគមន៍បែបគ្រប់គ្រងផ្ទាល់មួយចំនួន ដូចជាតាមរយៈការដាក់ចេញជាកម្មវិធីសិក្សា ឬទុកឱ្យអ្នកផ្តល់សេវាដែលមានស្រាប់បន្តដំណើរការសាលារៀន។ ការអប់រំស្ថិតនៅក្នុងចំណោមសេវាដែលមានតម្លៃបំផុត ដែលពលរដ្ឋជាជនស៊ីវិលធ្វើការទាមទារ។ ការខកខានពុំបានផ្តល់សេវាអប់រំអាចនាំឱ្យមានការថ្នាក់ថ្នាំងចិត្ត។

មានបញ្ហាប្រឈមពាក់ព័ន្ធនឹងការប្រើប្រាស់ភាសាចម្រុះក្នុងការអប់រំ។ ដូចជានៅក្នុងប្រទេសអាហ្វ្រិកភាគខាងលិច និងអាហ្វ្រិកខាងកណ្តាល ដូចជា ប្រទេសឆាដ ហ្គាំបៀរ និងតូហ្គោ ដែលក្នុងនោះកុមារអាយុ ៧ ដល់ ១៤ ឆ្នាំ ៥% និយាយភាសាដែលប្រើប្រាស់សម្រាប់ការបង្រៀននៅក្នុងផ្ទះរបស់ពួកគេដែរ។ អភិក្រមដែលបញ្ចូលគោលនយោបាយស្តីពីភាសាប្រើប្រាស់សម្រាប់ការបង្រៀនជាមួយនឹងប្រភពទិន្នន័យភាសាការប៉ាន់ប្រមាណពីចំនួនប្រជាជនដល់វ័យចូលរៀន និងអត្រាចុះឈ្មោះចូលរៀនបង្ហាញថា កុមារ ៣៧% នៅក្នុងប្រទេសដែលមានចំណូលទាប និងចំណូលមធ្យមរៀនភាសាផ្សេងក្រៅតែភាសាដែលប្រើប្រាស់នៅក្នុងផ្ទះរបស់ពួកគេ៖ ២៧% និយាយភាសាសរសេរគោពតិច និង ១០% និយាយភាសាដែលគេមិនសូវនឹងប្រើប្រាស់ទូទៅ ដែលក្នុងនោះភាសានីមួយៗមានចំនួនអ្នកនិយាយតិចតួចប៉ុណ្ណោះ។

ចំណុចដៅ ៤.៦. អក្ខរកម្មមនុស្សពេញវ័យ

នៅក្នុងសកលលោកទាំងមូល ក្នុងចំណោមមនុស្សពេញវ័យដែលមានអាយុចាប់ពី ១៥ ឆ្នាំឡើងទៅ មានស្ត្រី ៨៣% និងបុរស ៩០% ដែលចេះអក្សរ បើគេបែងចែកអក្ខរកម្មជា ២ ប្រភេទ – ពោលគឺខុសគ្នា ៧ ភាគរយចំណុច។ ក្នុងចំណោមស្ត្រីវ័យក្មេង ៤ នាក់មានជាង ១ នាក់ដែលមិនចេះអក្សរនៅអាហ្វ្រិកសាប់សាហារ៉ា ដែលអត្រាអក្ខរកម្មយុវជនជាស្ត្រីកើនឡើងតិចជាង ១ ភាគរយចំណុចក្នុងមួយឆ្នាំ។ ក្នុងសកលលោកទាំងមូល ការថយចុះចំនួនស្ត្រីមិនចេះអក្សរ នៅអាស៊ីបូព៌ា និងអាស៊ីអាគ្នេយ៍ចាប់តាំងពីឆ្នាំ ១៩៩៩ មកត្រូវបានកាត់កងភាគច្រើន ដោយសារការកើនឡើងនូវចំនួនស្ត្រីមិនចេះអក្សរនៅអាហ្វ្រិកសាប់សាហារ៉ា។ លើសពីនេះការសន្មតដែលថា អ្នកដែលចាកចេញពីសាលាមធ្យមសិក្សាទាំងអស់សុទ្ធតែចេះអក្សរ មានន័យថាកម្រិតអក្ខរកម្មពិតប្រាកដកន្លងមកត្រូវបានគេប៉ាន់ប្រមាណលើពីកម្រិតពិតប្រាកដ។ សិស្សដែលបញ្ចប់ការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិជិតពាក់កណ្តាលនៅក្នុងប្រទេសចំនួន ១៨ ដែលមានទិន្នន័យអង្កេតកាលពីពេលថ្មីៗនេះ ពុំមានកម្រិតអក្ខរកម្មដល់កម្រិតមូលដ្ឋាន ទៅតាមនិយមន័យដែលកំណត់ថា ជាអ្នកដែលចេះអានប្រយោគបែបសាមញ្ញនោះឡើយ (**រូបភាពទី ៧**)។


អង្គហេតុផ្សេងពីនេះ ដែលកំណត់ថាការមិនបានទៅរៀនមិនមែនសុទ្ធតែមិនចេះអក្សរ រំលេចឱ្យឃើញពីសារៈសំខាន់នៃការទទួលបានសមត្ថភាពអក្ខរកម្មនៅក្រៅសាលារៀន។ ពាក់ព័ន្ធនឹងចំនួនប្រជាជនមិនចេះអក្សរដែលត្រូវបានប៉ាន់ប្រមាណ ការចុះឈ្មោះចូលរៀនរបស់មនុស្សពេញវ័យក្នុងកម្មវិធីក្រៅប្រព័ន្ធ ISCED 1 មាន ១% ចុះនៅក្នុងប្រទេសបូលីវៀ ហុងឌួរ៉ាស ម៉ូសំប៊ិក កាតា ស៊ូរីណាម, ២% នៅក្នុងប្រទេសបារ៉ែន និង ប៉េរូ, ៣% នៅកូឡុំប៊ៀ និងថៃ, ៤% នៅអារ៉ាប៊ីសាអូឌីត និង ៨% នៅសាធារណៈរដ្ឋដូមីនីក។

ទិន្នន័យនៅមានគិចគួច សូម្បីតែទិន្នន័យអំពីជំនាញលេខនព្វន្តនពន្ធសាមញ្ញៗ។ គេអាចធ្វើការគណនារង្វាស់តំណាងឱ្យសមត្ថភាពចេះលេខនព្វន្តកម្រិតមូលដ្ឋាន ជាភាគរយនៃមនុស្សដែលប្រាប់អាយុរបស់ខ្លួនបានត្រឹមត្រូវដែលនេះឆ្លុះបញ្ចាំងពីសមត្ថភាពប្រើប្រាស់លេខ (lowintegers) ដែលមានលក្ខណៈសាមញ្ញ។ ខណៈពេលដែលមនុស្សភាគច្រើនសូម្បីតែអ្នកមានជីវភាពក្រីក្របំផុតសុទ្ធតែអាចឆ្លងផុតពីកម្រិតកំណត់នេះ រង្វាស់នេះ គឺជារង្វាស់ដែលសមស្របសម្រាប់ពិនិត្យមើលនិន្នាការចំណេះដឹងលេខនព្វន្តកន្លងមក។

រូបភាពទី ៧៖

សូម្បីតែអ្នកដែលបញ្ចប់ការសិក្សាពីសាលាមធ្យមសិក្សា ក៏គេមិនអាចសន្មតថាបានទទួលសមត្ថភាពអក្ខរកម្មនោះដែរ

អត្រាអក្ខរកម្មរបស់ក្រុមអាយុ ២០ ដល់ ២៤ ឆ្នាំ បែងចែកតាមកម្រិតនៃការអប់រំនៅតាមប្រទេសមួយចំនួន ២០១៥-១៩



សម្គាល់៖ ទំហំនៃចំណុចនៅក្នុងក្រាហ្វិច គឺសមមាត្រទៅនឹងទំហំប្រជាជននៅកម្រិតអប់រំនីមួយៗ។

ប្រភព៖ ការវិភាគដែលធ្វើឡើងដោយក្រុមរៀបចំរបាយការណ៍ GEM ដោយប្រើប្រាស់ទិន្នន័យ DHS។

ការវិភាគលើទិន្នន័យដែលបានពីការអង្កេតខ្នងផ្ទះនិងជំរឿនប្រជាជន អនុញ្ញាតឱ្យគេអាចតាមដានដឹងពីសមត្ថភាពលេខនពន្ធរបស់ក្រុមប្រជាជន ដែលកើតកន្លោះទសវត្សរ៍ ១៩៦០ និង ២០១០ នៅក្នុងប្រទេសអាហ្វ្រិក សាប់សាហារ៉ា ចំនួន ៤២។ ភាពល្អប្រសើរនៅក្នុងរយៈពេលនេះមានតិចតួចប៉ុណ្ណោះ ហើយពុំនៅបិនថេរក្នុងចំណោមប្រជាជនដែលមានជីវភាពក្រីក្របំផុតនោះឡើយ។ ការកើនឡើងជារួមនៃសមត្ថភាពលេខនពន្ធនៅអាហ្វ្រិកភាគច្រើន កើតឡើងស្ទើរតែទាំងស្រុងដោយសារការកើនឡើងនូវអត្រាចូលរៀន។

ចំណុចដៅ ៤.៧. ការអភិវឌ្ឍដោយចីរភាព និងភាពជាពលរដ្ឋសកល

ចំណុចដៅ ៤.៧ មានវិសាលភាពទូលំទូលាយជាងចំណុចដៅផ្សេងទៀត ក្នុងរបៀបវារៈ SDG ទី ៤ ដោយបានឆ្លើយតបចំពោះអ្វីដែលអ្នកសិក្សាចាំបាច់ត្រូវរៀន ដើម្បីឈានទៅសម្រេចមហិច្ឆតានៃគោលដៅ SDG ទី ៤ ដែលចង់ឱ្យមានការផ្លាស់ប្រែជាវិជ្ជមាន។ ភាគរយនៃសាលារៀនដែលផ្តល់ការអប់រំអំពីជំងឺអេដស៍ និងផ្លូវភេទ ដោយយកគំរូតាមការអប់រំបំណិនជីវិត មានកម្រិតទាបជាពិសេសនៅកម្រិតបឋមសិក្សា ដូចជាសាលាបឋមសិក្សា ២,៥% នៅប្រទេសបីហ្គីណាហ្វាសូ និង ៦% នៅប្រទេសនីហ្សេជាដើម។ ទោះជាយ៉ាងណាក៏ដោយគោលការណ៍ណែនាំបច្ចេកទេសអន្តរជាតិរបស់អង្គការសហប្រជាជាតិ ស្តីពីការអប់រំផ្លូវភេទ ដែលត្រូវបានកែសម្រួលឡើងវិញ ផ្តល់អនុសាសន៍ឱ្យមានការអប់រំអំពីភាពមានវ័យគ្រប់ការ និងការមករដូវមុនពេលដែលអ្នកសិក្សាឈានដល់វ័យនេះ ដូចជាសម្រាប់សិស្សដែលមានអាយុ ពី ៩ ដល់ ១២ ឆ្នាំជាដើម។ ឧបករណ៍ពិនិត្យ និងវាយតម្លៃលើការអប់រំផ្លូវភេទរបស់យូណេស្កូ គឺជាឧបករណ៍ដែលត្រូវបានប្រើប្រាស់សម្រាប់រៀបចំរបាយការណ៍វឌ្ឍនភាពជាសកលដែលសម្រេចបានកាលពីពេលថ្មីៗ ជុំវិញការអប់រំផ្លូវភេទដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ។ ក្នុងចំណោមប្រទេស ២៤ មានប្រទេសតែ ៣ ប៉ុណ្ណោះដែលត្រូវបានវាយតម្លៃថាមានខ្លឹមសារកម្មវិធីសិក្សា 'កម្រិតខ្ពស់' អំពីសុខភាពផ្លូវភេទ និងបន្តពូជសម្រាប់កុមារអាយុពី ៩ ដល់ ១២ ឆ្នាំ ហើយប្រទេសចំនួន ៥ មានខ្លឹមសារកម្មវិធីសិក្សា 'ល្អប្រសើរ'។

ការសិក្សាអំពីការអប់រំពលរដ្ឋ និងភាពជាប្រជាពលរដ្ឋអន្តរជាតិ ឆ្នាំ ២០១៦ នៅក្នុងប្រទេសចំណូលមធ្យមកម្រិតខ្ពស់ និងប្រទេសចំណូលខ្ពស់ចំនួន ២៣ បានបានរកឃើញថាភាគរយសិស្សដែលមានការយល់ដឹងគ្រប់គ្រាន់អំពីបញ្ហា៣ក់ព័ន្ធនឹងភាពជាពលរដ្ឋសកលមានចាប់ពីប្រមាណ ៤០% នៅសាធារណៈរដ្ឋដូមីនីក ឡាតវី និងហុងឡុង រហូតដល់ជិត ៧0% នៅក្នុងប្រទេសក្រូអាត សាធារណៈរដ្ឋកូរ៉េ និងស៊ុយអែត។ ការអង្កេត TIMSSឆ្នាំ២០១៩បានបង្ហាញថាមានសិស្សប្រហែល៣0%ប៉ុណ្ណោះដែលមានកម្រិតស្ទាត់ជំនាញផ្នែកចំណេះដឹងអំពីវិទ្យាសាស្ត្របរិស្ថាន។ ការអប់រំអំពីការប្រែប្រួលអាកាសធាតុ មានគោលបំណងជួយឱ្យប្រជាជនយល់ឆ្លើយតប កាត់បន្ថយ និងបន្សាំខ្លួនទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ កម្រងព័ត៌មានថ្មីមួយរបស់បណ្តាប្រទេសនានា ស្តីពីការផ្សព្វផ្សាយ និងអប់រំអំពីការប្រែប្រួលអាកាសធាតុ ដែលចងក្រងដោយរបាយការណ៍ GEM និងគម្រោងតាមដាន និងវាយតម្លៃការអប់រំផ្សព្វផ្សាយអំពីបរិស្ថាន អាចឱ្យគេធ្វើការប្រៀបធៀបស្ថានភាពនៅតាមប្រទេសទាំងនេះ។ សំណុំទី ១ នៃកម្រងព័ត៌មានរបស់ប្រទេសចំនួន ២០ គ្របដណ្តប់លើគ្រប់តំបន់ និងក្រុមប្រទេសបែងចែកតាមកម្រិតចំណូលទាំងអស់។ សំណុំទី ២ ដែលមានកម្រងព័ត៌មានរហូតដល់ ៥០ គ្រោងនឹងត្រូវបោះពុម្ពផ្សាយក្នុងឆ្នាំ ២០២២។ ការវិភាគបឋមបង្ហាញថា ការផ្តោតការយកចិត្តទុកដាក់លើការប្រែប្រួលអាកាសធាតុត្រូវបានរកឃើញតែក្នុងច្បាប់ ៤0% នៃច្បាប់អប់រំជាតិទាំងអស់ និងក្នុងផែនការ ឬយុទ្ធសាស្ត្រវិស័យអប់រំតែ ៤៥% ប៉ុណ្ណោះ។

ចំណុចដៅ ៤.ក. សម្ភារៈរូបវន្តដែលបម្រើដល់ការអប់រំ និងបរិយាកាសរៀនសូត្រ

ការសិក្សាដែលមានគុណភាពល្អមិនអាចកើតឡើងបានឡើយ ប្រសិនបើបរិយាកាសពុំមានភាពសមស្រប ហើយគុណភាពរឹតតែធ្លាក់ចុះខ្លាំងទៅទៀត ប្រសិនបើបរិយាកាសរៀនសូត្រគំរាមកំហែងដល់សុខមាលភាពរបស់កុមារ។ សេចក្តីប្រកាសស្តីពីសាលារៀនមានសុវត្ថិភាព ដែលជាការប្តេជ្ញាចិត្តកម្រិតនយោបាយជាលក្ខណៈអន្តរដ្ឋាភិបាល ដើម្បីការពារសិស្ស គ្រូបង្រៀន សាលារៀន និងសាកលវិទ្យាល័យ ពីការវាយប្រហារក្នុងអំឡុងពេលដែលមានជំលោះប្រដាប់អាវុធ បច្ចុប្បន្នបានទទួលការអនុម័តពីរដ្ឋចំនួន ១១២។ កស្តុតាងកាន់តែច្រើនបង្ហាញថា ការធ្វើទារុណកម្មលើរាងកាយ មិនត្រឹមតែបំពានសិទ្ធិកុមារប៉ុណ្ណោះទេ ថែមទាំងប៉ះពាល់ដល់លទ្ធផលនៃការអប់រំផងដែរ។ បច្ចុប្បន្ននេះ ការធ្វើទារុណកម្មលើរាងកាយត្រូវបានហាមឃាត់ទាំងស្រុងនៅតាមសាលារៀនក្នុងប្រទេសចំនួន ១៥៦។

សាលារៀនអាចជាកន្លែងតែមួយគត់ដែលកុមារមួយចំនួនអាចមានទឹកស្អាតបរិក្ខាអនាម័យបរិស្ថាននិងអនាម័យផ្ទាល់ខ្លួនសម្រាប់ប្រើប្រាស់។ នៅក្នុងប្រទេសលីបេរីយ៉ា មានគ្រួសារតិចតួចប៉ុណ្ណោះ ដែលមានបរិក្ខាអនាម័យផ្ទាល់ខ្លួនសម្រាប់ប្រើប្រាស់ ដែលអាចឆ្លើយតបទៅនឹងស្តង់ដារអន្តរជាតិកម្រិតមូលដ្ឋាន ប៉ុន្តែសាលារៀន ៦៩% ដែលមានបរិក្ខាអនាម័យបែបនេះ។ គេអាចសន្មត់ដោយហេតុផលសមស្របថា ទោះជាយ៉ាងនេះក្តី សាលារៀនតូចៗដែលភាគច្រើនមានទីតាំងនៅតំបន់ដាច់ស្រយាល និងជនបទ មិនទំនងជាបានបំពេញតាមលក្ខណៈវិនិច្ឆ័យគុណភាពហេដ្ឋារចនាសម្ព័ន្ធនោះឡើយ បើធៀបនឹងសាលារៀនធំៗ។ នៅក្នុងប្រទេសកាបូវែរដ៍ (Cabo Verde) កាលពីឆ្នាំ ២០១៨ សាលាបឋមសិក្សា ២២% ខ្វះបរិក្ខាលាងសម្អាតដៃកម្រិតមូលដ្ឋាន។ ទោះជាយ៉ាងណាក៏ដោយ សាលាបឋមសិក្សាដែលមានទំហំតូចជាងគេចំនួន ២២% មានសិស្សចុះឈ្មោះចូលរៀនសរុបត្រឹមតែ ២% នៃចំនួនសិស្សចុះឈ្មោះចូលរៀនសរុបនៅកម្រិតបឋមសិក្សាតែប៉ុណ្ណោះ។ ដូច្នេះ នៅក្នុងសកលលោកទាំងមូលភាគរយកុមារដែលរៀននៅសាលារៀនដែលគ្មានបរិក្ខាកម្រិតមូលដ្ឋាន ទំនងជាមានកម្រិតទាបធ្ងាយជាងភាគរយនៃសាលារៀន ដែលមានបរិក្ខាទាំងនេះ។

ក្រៅតែពីបរិក្ខារូបវន្ត ចំណុចផ្សេងទៀតដូចជាការរៀបចំប្រតិទិនសាលារៀន – ពោលគឺចាប់ពីការបែងចែកថ្ងៃបង្រៀនតាមសប្តាហ៍ និងក្នុងឆ្នាំរហូតដល់រយៈ និងការបែងចែកថ្ងៃសិក្សា – អាចមានផលវិបាកដ៏សំខាន់មកលើគុណភាព និងសមធម៌នៃប្រព័ន្ធអប់រំ។ រចនាសម្ព័ន្ធប្រតិទិនសាលារៀនរបស់ប្រទេសជាច្រើនត្រូវបានរៀបចំឡើងដោយសារតែឥទ្ធិពលនៃប្រវត្តិអាណានិគម ជាជាងទៅតាមរដូវ ហើយពុំត្រូវបានរៀបចំឱ្យបានសមស្របដូនៃរដូវធ្វើកសិកម្មតាមមូលដ្ឋាននោះឡើយ។ ពេលវេលាចាប់

ផ្តើមរៀនមួយថ្ងៃក៏មានសារៈសំខាន់ផងដែរ។ បន្ថែមលើការទុកពេលកេងបន្ថែម ការចាប់ផ្តើមម៉ោងរៀនយឺតបន្តិតហាក់បីដូចស្របគ្នាទៅនឹងសង្វាក់រាងកាយ (circadian rhythm) របស់ក្មេងជំទង់ ដែលពួកគេមានអារម្មណ៍ស្រឡះបំផុតនៅចុងព្រឹក និងពេលរសៀល។

ចំណុចដៅ ៤.ខ. អាហារូបករណ៍

ការផ្តល់ជំនួយជារួម ដើម្បីជួយឱ្យសិស្សបានបន្តរៀនពីកម្រិតថ្នាក់មួយទៅកម្រិតថ្នាក់មួយទៀត កើនឡើង ៣0% ចន្លោះពីឆ្នាំ ២០១៥ និង ២០១៩ ពោលគឺពី ៣,៤ ៣ន់លានដុល្លារដល់ ៤,៤ ៣ន់លានដុល្លារ។ ជំនួយអាហារូបករណ៍សរុបដល់ប្រទេសដែលមានចំណូលទាបកើនឡើងទ្វេដងពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៩ ពោលគឺកើនឡើងលើសពីអត្រាកំណើននៃការចុះឈ្មោះចូលរៀននៅកម្រិតឧត្តមសិក្សា។ ប៉ុន្តែប្រសិនបើគេគិតពីប្រទេសចំណូលទាប និងប្រទេសចំណូលមធ្យមបញ្ចូលគ្នា ចំនួនសិស្សដែលចេញទៅសិក្សានៅក្រៅប្រទេស កើនឡើងលឿនជាងអត្រាកំណើននៃជំនួយអាហារូបករណ៍។ គិតជាមធ្យមក្នុងនិស្សិតអន្តរជាតិម្នាក់ជំនួយអាហារូបករណ៍ក្នុងឆ្នាំ ២០១៩ មានតិចជាងជំនួយអាហារូបករណ៍កាលពីឆ្នាំ ២០0៦។ ទិន្នន័យដែលមានមិនដូចគ្នាបង្ហាញថា គេពុំបានសម្រេចតាមបំណងដែលចង់ឱ្យមានពង្រីកជំនួយអាហារូបករណ៍ឱ្យបានច្រើនត្រឹមឆ្នាំ ២0២0 នោះឡើយ។ ប៉ុន្តែបច្ចុប្បន្ននេះ អ្នកផ្តល់ជំនួយទំនងជាផ្តល់អាហារូបករណ៍ដល់ប្រទេសកំពុងអភិវឌ្ឍន៍បន្ថែមទៀត បើធៀបនឹងកាលពីឆ្នាំ ២០១៥ ហើយអ្វីដែលតឹតែងសំខាន់ទៅទៀតនោះ ប្រទេសដែលទទួលអាហារូបករណ៍មិនសូវជាពឹងផ្អែកលើអ្នកផ្តល់ជំនួយសំខាន់ៗមួយ ឬពីរឡើយ។

ទស្សនទាន 'ការហូរចេញនូវអ្នកដែលមានទេពកោសល្យ (brain drain)' ដែលនិស្សិតបានទទួលអាហារូបករណ៍ពុំវិលត្រឡប់ទៅប្រទេសកំណើតរបស់ពួកគេវិញ កំពុងត្រូវបានជំនួសដោយទស្សនទាន 'ការវិលជុំនៃអ្នកដែលមានទេពកោសល្យ (brain circulation)' ដែលជាទស្សនទានស្មុគស្មាញជាងមុន។ ការប៉ាន់ប្រមាណកាលពីពេលថ្មីៗនេះបង្ហាញថា ការធ្វើមាតុភូមិនិវត្តន៍ត្រឡប់ទៅប្រទេសកំណើតវិញ គឺជាផ្នែកដ៏ធំមួយនៃហូរទេសន្តរប្រវេសន៍ ទៅកាន់ប្រទេសអាហ្វ្រិកសាប់សាហារ៉ា និងអាមេរិកឡាទីន ហើយជនទេសន្តរប្រវេសន៍ទាំងនេះ បើគិតជាមធ្យម គឺជាអ្នកដែលមានការអប់រំខ្ពស់ជាងមុន។ ប្រទេសមួយចំនួនទទួលស្គាល់ថា សូម្បីតែពលរដ្ឋដែលមានជំនាញកម្រិតខ្ពស់ ហើយដែលមិនវិលត្រឡប់ទៅប្រទេសកំណើតវិញនាអនាគតដ៏ខ្លី ក៏ជាទ្រព្យសម្បត្តិមួយសម្រាប់ប្រទេសកំណើតដែរ ប្រសិនបើអ្នកទាំងនោះមានឱកាសចូលរួមសមស្របជាមួយនឹងប្រទេសកំណើតរបស់ពួកគេ។ ក្នុងចំណោមប្រទេសនៅអាមេរិកឡាទីន និងការាបៀនចំនួន ២២ ដែលត្រូវបានវិភាគសម្រាប់សន្ទស្សន៍គោលនយោបាយនិប្រវេសន៍ (Emigrant Policies Index) ប្រទេសចំនួន ៨ នៅបន្តរក្សាបណ្តាញផ្លូវការវិលជុំនៃអ្នកដែលមានទេពកោសល្យ។ ការវិភាគដែលធ្វើឡើងកន្លងមកលើគោលនយោបាយទេសន្តរប្រវេសន៍ (diaspora policies) នៅប្រទេសចំនួន ៣៥ ដែលតំណាងឱ្យគ្រប់តំបន់ទាំងអស់នៅក្នុងពិភពលោក ក៏ដូចជាលើកម្រិតប្រាក់ចំណូល និងប្រភេទរដ្ឋាភិបាលបានរកឃើញថាប្រទេស ២ ភាគ ៣ នៅបន្តរក្សាបណ្តាញវិទ្យាសាស្ត្រមួយចំនួន ហើយប្រទេសពាក់កណ្តាលកំណត់កាតព្វកិច្ចឱ្យនិស្សិតដែលត្រូវបានបញ្ជូនទៅរៀនអាហារូបករណ៍នៅក្រៅប្រទេសត្រូវវិលត្រឡប់មកវិញ។

ចំណុចដៅ ៤.គ. គ្រូបង្រៀន

ទិន្នន័យដែលបានពីរបាយការណ៍នានាបង្ហាញថា អាហ្វ្រិកសាប់សាហារ៉ា គឺជាតំបន់ដែលមានភាគរយគ្រូបំពេញតាមស្តង់ដារជាតិទាបជាងគេ៖ ៥៧% សម្រាប់កម្រិតមត្តេយ្យសិក្សា (ធៀបនឹង ៨៣% នៅអាមេរិកឡាទីន និងការីបៀន) ៦៧% សម្រាប់កម្រិតបឋមសិក្សា (ធៀបនឹង ៨៥% នៅអាហ្វ្រិកភាគខាងជើង និងអាស៊ីភាគខាងលិច) និង ៦១% សម្រាប់ការអប់រំកម្រិតមធ្យមសិក្សា (ធៀបនឹង ៧៨% នៅអាស៊ីភាគកណ្តាលនិងអាស៊ីខាងត្បូង)។ ហេតុដូច្នេះផលធៀបសិស្ស/គ្រូដែលបានទទួលការបណ្តុះបណ្តាល នៅអាហ្វ្រិកសាប់សាហារ៉ា ខ្ពស់ជាអត្រាមធ្យមក្នុងសកលលោកជិត ២ ដង បើទោះជាមានភាពល្អប្រសើរតិចតួចចាប់តាំងពីឆ្នាំ ២០១៥ មកក៏ដោយ។

សូម្បីតែគ្រូដែលមានគុណវុឌ្ឍិអាចមិនមានសមត្ថភាពបង្រៀនមុខវិជ្ជាជាក់លាក់ដែលពួកគេបង្រៀននោះឡើយ។ ការបង្រៀនក្រៅមុខវិជ្ជាគឺជាអ្វីដែលកើតមានជាទូទៅនៅតាមប្រទេសជាច្រើនក្នុងពិភពលោក។ ក្នុងប្រព័ន្ធអប់រំយ៉ាងហោចណាស់ចំនួន ៤0 ដែលបានចូលរួមនៅក្នុងការអង្កេតអន្តរជាតិលើការបង្រៀន និងរៀនឆ្នាំ ២០១៨ គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រនៅសាលបឋមសិក្សាបឋមភូមិជាង ១0% ពុំបានទទួលការអប់រំ ឬការបណ្តុះបណ្តាលផ្លូវការសម្រាប់មុខវិជ្ជាដែលពួកគេបង្រៀននោះឡើយ។ នេះ គឺជាអ្វីដែលកើតឡើងចំពោះគ្រូបង្រៀនមុខវិជ្ជាគណិតវិទ្យា។ នៅក្នុងប្រទេសហ្សកហ្ស៊ី និងអារ៉ាប៊ីសាអូឌីត គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យាតិចជាង ៦0% បានទទួលការបណ្តុះបណ្តាលអំពីមុខវិជ្ជារបស់ពួកគេ ក្នុងការអប់រំផ្លូវការរបស់ពួកគេ។ ការបង្រៀនក្រៅមុខវិជ្ជានាំឱ្យមានក្តីបារម្ភពាក់ព័ន្ធនឹងសមធម៌ ព្រោះថាមិនមែនគ្រប់គ្នាសុទ្ធតែទំនងជាត្រូវបានបង្រៀន ឬបានទទួលការបង្រៀនដោយគ្រូដែលបង្រៀនខុសមុខវិជ្ជាឡើយ ដែលនេះគឺជាបញ្ហាបែបនេះច្រើនតែកើតមាននៅតាមតំបន់និងសាលារៀនជនបទ ដែលផ្តល់សេវាដល់សិស្សដែលមិនសូវមានឱកាស។

ការប៉ាន់ប្រមាណថ្មីៗ ដែលធ្វើឡើងដោយ UIS លើសូចនាករបៀវត្សរបស់គ្រូ ដែលពិនិត្យលើថាតើគ្រូបង្រៀនទទួលបានបៀវត្សកម្រិតណា បើធៀបនឹងអ្នកជំនាញដទៃទៀត ដែលត្រូវការគុណវុឌ្ឍិក្នុងកម្រិតប្រហាក់ប្រហែលនេះបង្ហាញថា ភាពខុសគ្នាគិតជាមធ្យមរវាងគ្រូ និងគ្រូនៅកម្រិតអប់រំផ្សេងៗគ្នាក្នុងប្រទេសតែមួយជាទូទៅ មានកម្រិតតិចតួចប៉ុណ្ណោះបើធៀបនឹងភាពខុសគ្នារវាងប្រទេសមួយ និងប្រទេសមួយទៀត។ ក្នុងប្រទេសដែលមានចំណូលមធ្យម ដែលគេមានកស្តង់បង្ហាញភាគច្រើន គ្រូច្រើនតែទទួលបានបៀវត្សតិចជាងវិជ្ជាជីវៈប្រហាក់ប្រហែលគ្នានេះនៅក្នុងវិស័យផ្សេងទៀត (**រូបភាពទី ៨**)។

សូចនាករបៀវត្សគ្រូ គឺជាសូចនាករដែលតំណាងឱ្យការលើកទឹកចិត្តសម្រាប់គ្រូ។ ប៉ុន្តែមានកត្តាជាច្រើនផ្សេងទៀត ដែលប៉ះពាល់ដល់ទឹកចិត្តរបស់គ្រូ ដូចដែលត្រូវបានបង្ហាញក្នុងការវិភាគថ្មីមួយលើបញ្ហាអវត្តមានដ៏ច្រើនរបស់គ្រូ ក្នុងប្រទេសចំនួន ៨ នៅអាហ្វ្រិកខាងកើត និងខាងត្បូង។ បើតាមស្ទង់មតិរបស់គ្រូបង្រៀន ភាគរយរបស់គ្រូដែលអវត្តមានពីសាលារៀន យ៉ាងហោចណាស់ម្តងក្នុងមួយសប្តាហ៍ មានចាប់ពីក្រោម ១០% នៅប្រទេសកេនយ៉ា និងរវ៉ាន់ដា ដល់ជិត ៣០% នៅស៊ូដង់ភាគខាងត្បូង។ គ្រូបង្រៀននិយាយថាពួកគេអវត្តមានដោយសារបញ្ហាសុខភាព (៦២%) និងគ្រួសារ (៣៥%) បន្ទាប់មកដោយសារកត្តាអាកាសធាតុ (ជាពិសេសភ្លៀងធ្លាក់ខ្លាំង និងកម្តៅក្តៅលើសលុប) បញ្ហាពាក់ព័ន្ធនឹងការងារផ្លូវការ និងការធ្វើដំណើរ។

ការអប់រំក្លាយគោលដៅអភិវឌ្ឍន៍ដោយចីរភាពផ្សេងទៀត

ការមានថាមពលប្រើប្រាស់នៅក្នុងផ្ទះ អាចបំពេញតួនាទីសំខាន់ដើម្បីផ្តល់លទ្ធភាពឱ្យកុមារអាចចូលរួមក្នុងសកម្មភាពអប់រំនានាបាន។ កម្មវិធីអគ្គិសនីការ៉ូបនីយកម្មជនបទរបស់ប្រទេសប៊ូតង់ បានជួយកាត់បន្ថយការប្រើប្រាស់អុស និងនាំឱ្យឆ្នាំសិក្សាកើនឡើងបាន ០,៨ ឆ្នាំបន្ថែមទៀត ដែលផ្តល់ជាប្រយោជន៍ដល់ក្មេងស្រីច្រើនជាងក្មេងប្រុស។ ការមានថាមពលប្រើប្រាស់នៅតាមសាលារៀនអាចជួយឱ្យបរិយាកាសរៀនសូត្រកាន់តែមានភាពល្អប្រសើរ និងពង្រីកលទ្ធភាពទទួលបានធនធានសម្រាប់ការសិក្សារៀនសូត្រ។ កម្មវិធីផ្តល់ជំនួយសម្រាប់គ្រប់គ្រងវិស័យថាមពលបានរកឃើញថា សាលារៀន៧២% នៅក្នុងប្រទេសកេនយ៉ា ប៉ុន្តែត្រឹមតែ ២២% ប៉ុណ្ណោះនៅក្នុងប្រទេសអេក្វាឌ័រ មានអគ្គិសនីប្រើប្រាស់ពីបណ្តាញសាធារណៈរបស់រដ្ឋ។ ផ្លូវថ្នល់ជួយកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ច រួមទាំងលទ្ធផលនៃការអប់រំផងដែរ។ នៅក្នុងខេត្តអាន់ទីហ្គៀ (Antioquia) នៅប្រទេសកូឡុំប៊ៀ ផ្លូវជនបទដែលកាន់តែមានភាពល្អប្រសើរ មានទំនាក់ទំនងជាមួយនឹងការកើនឡើងនៃលទ្ធផលអប់រំរបស់សិស្សជនបទ។

ក្នុងដំណើរផ្លាស់ប្តូរទៅសម្រេចគោលដៅអភិវឌ្ឍន៍ដោយចីរភាពត្រឹមឆ្នាំ ២០៣០ មានវឌ្ឍនភាពគួរឱ្យស្ញប់ស្ញែងមួយចំនួន ពាក់ព័ន្ធនឹងការកែលម្អបច្ចេកវិទ្យាថាមពលកកើតឡើងវិញ ជាមួយនឹងការឧបត្ថម្ភពីការវិនិយោគធំៗ លើអន្តរកាលផ្លាស់ប្តូរទៅប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ និងថាមពលខ្យល់។ លើសពីនេះមានការយល់ដឹងកាន់តែច្រើនជាងមុនពីភាពចាំបាច់នៃការប្រើប្រាស់ និងការផលិតប្រកបដោយចីរភាព។ ទោះជាយ៉ាងណាក៏ដោយ ការកើនឡើងផ្នែកគោលដៅដែលមិនផ្តោតលើទីផ្សារ – ដូចជា ការទទួលបានបច្ចេកវិទ្យាចម្ការស្អាត ប្រកបដោយសមធម៌ ជំនាញឯកទេសផ្នែកថាមពលកកើតឡើងវិញ ជំនួយហិរញ្ញវត្ថុដល់ប្រទេសដែលមានការអភិវឌ្ឍតិចតួច ផ្តោតលើការកសាងសមត្ថភាព ការអភិវឌ្ឍកម្លាំងពលកម្ម ដែលមានលក្ខណៈចម្រុះប្រកបដោយសមធម៌ – ត្រូវបានគេដាក់សញ្ញាសម្គាល់កំពុងជួបនឹងការលំបាកល ការអប់រំគាំទ្រដល់ការសម្រេចគោលដៅពាក់ព័ន្ធនឹងចីរភាព។ គ្រឹះស្ថានអប់រំចាំបាច់ត្រូវបង្កើនការយល់ដឹងរបស់សិស្ស អំពីបញ្ហាប្រឈមពាក់ព័ន្ធនឹងថាមពល និងបញ្ហាប្រឈមដទៃទៀតពាក់ព័ន្ធនឹងចីរភាព។ ការយល់ដឹងរបស់សាធារណៈជនទូទៅអាចរួមចំណែកនាំឱ្យមានការផ្លាស់ប្តូរសង្គមយ៉ាងទូលំទូលាយ។ ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈចាំបាច់ត្រូវកើតមានក្នុងល្បឿនដែលមិនធ្លាប់មាន ដើម្បីជួយគាំទ្រដល់អន្តរកាលបៃតង។

ហិរញ្ញប្បទាន

បើតាមទិន្នន័យចុងក្រោយ ដែលពុំបានឆ្លុះបញ្ចាំងពីផលប៉ះពាល់នៃការរាតត្បាតជាសកល ចំណាយលើការអប់រំសាធារណៈស្មើនឹង ៤,៤% នៃ ផ.ស.ស. និង ១៤,១% នៃចំណាយសាធារណៈសរុប។ ក្នុងចំណោមប្រទេសទាំង ១៥១ ដែលមានទិន្នន័យសម្រាប់ឆ្នាំ ២០១៤–១៩, ប្រទេសចំនួន ៤៨ ឬស្មើនឹង ៣២% ខកខានពុំបានសម្រេចតាមចំណុចដៅ ៤% នៃ ផ.ស.ស. និង ១៥% នៃចំណាយរបស់រដ្ឋាភិបាលលើការអប់រំដូចដែលបានដាក់ចេញនៅក្នុងក្របខ័ណ្ឌសកម្មភាពអប់រំឆ្នាំ ២០៣០។ ចំណាយលើការអប់រំសាធារណៈ ស្មើនឹង ៣,៥% នៃ ផ.ស.ស. និង ១៦% នៃចំណាយរបស់រដ្ឋាភិបាលនៅក្នុងប្រទេសដែលមានចំណូលទាប បើធៀបនឹង ៤,៧% នៃ ផ.ស.ស. និង ១២% នៃចំណាយរបស់រដ្ឋាភិបាលលើប្រទេសដែលមានចំណូលខ្ពស់។


ជំនួយសម្រាប់ការអប់រំនៅត្រឹងត្រឹម ១៥,៣ ពាន់លានដុល្លារកាលពីឆ្នាំ ២០១៩។ ជំនួយសម្រាប់ការអប់រំកម្រិតមូលដ្ឋានថយចុះ ៥០៤ លានដុល្លារធៀបនឹងឆ្នាំ ២០១៨ ខណៈពេលដែលជំនួយសម្រាប់ការអប់រំកម្រិតបឋមសិក្សាកើនឡើង ២០៣ លានដុល្លារស្មើនឹង ២០% នៃជំនួយសរុប ពោលគឺកើនឡើងពី ១២% កាលពីឆ្នាំ ២០០៥។ ទោះជាយ៉ាងណាក៏ដោយ សមតុល្យទំនងជាផ្តល់ជាប្រយោជន៍សម្រាប់ការអប់រំថ្នាក់មូលដ្ឋាននៅពេលដែលទិន្នន័យជំនួយឆ្នាំ ២០២០ ត្រូវបានចេញផ្សាយ ព្រោះថាភាពជាដៃគូសកលសម្រាប់ការអប់រំបានទំលាក់ចរិកមិនធ្លាប់មានរហូតដល់ ១ ពាន់លានដុល្លារក្នុងឆ្នាំ ២០២០ ដើម្បីឆ្លើយតបចំពោះផលវិបាកនៃជំងឺកូវីដ ១៩។

ក្នុងចំណោមប្រទេស ៧៥ ដែលមានទិន្នន័យសម្រាប់ឆ្នាំ ២០១៤–១៩ ចំណាយរបស់គ្រួសារស្មើនឹង ០,១% នៃ ផ.ស.ស. ក្នុងប្រទេសចំណូលខ្ពស់, ០,៨% នៅប្រទេសចំណូលមធ្យម និង ៣,៣% នៅប្រទេសចំណូលទាប។

រូបភាពទី ៨៖

ធៀបនឹងវិជ្ជាជីវៈដទៃទៀត គ្រូបង្រៀនច្រើនតែទទួលបានបៀវត្សទាបជាងនៅក្នុងប្រទេសចំណូលខ្ពស់ ប៉ុន្តែទទួលបានបៀវត្សខ្ពស់ជាងនៅក្នុងប្រទេសចំណូលទាប និងចំណូលមធ្យមមួយចំនួន

បៀវត្សគិតជាមធ្យមរបស់គ្រូធៀបនឹងវិជ្ជាជីវៈដទៃទៀត ដែលទាមទារឱ្យមានគុណវុឌ្ឍិក្នុងកម្រិតប្រហាក់ប្រហែលគ្នា ឆ្នាំដែលមានទិន្នន័យចុងក្រោយ ២០១៥–១៩



ប្រភព៖ ប្រព័ន្ធទិន្នន័យ UIS

តួអង្គមិនមែនរដ្ឋ ក្នុងការងារអប់រំ

នរណាជាអ្នកជ្រើសរើស? នរណាជាអ្នកខាតបង់?

តួអង្គមិនមែនរដ្ឋមានតួនាទីលើសពីត្រឹមការផ្តល់សេវាអប់រំតាមសាលារៀន រហូតដល់អន្តរាគមន៍នៅកម្រិតអប់រំផ្សេងៗគ្នា និងការមានឥទ្ធិពលលើរឿងជាច្រើន។ ទន្ទឹមគ្នានេះ ការពិនិត្យឡើងវិញលើវឌ្ឍនភាពឆ្ពោះទៅសម្រេចគោលដៅ SDG ទី ៤ រួមនឹងកស្តុតាងថ្មី អំពីផលប៉ះពាល់នៃការរាតត្បាតជាសកលនៃជំងឺកូវីដ ១៩ របាយការណ៍ពិនិត្យតាមដានការអប់រំសកល ២០២១/២២ ជំរុញឱ្យរដ្ឋាភិបាលចាត់ទុកគ្រឹះស្ថាន សិស្ស និងគ្រូបង្រៀនទាំងអស់ ជាផ្នែកនៃប្រព័ន្ធតែមួយ។ ស្តង់ដារព័ត៌មាន ការលើកទឹកចិត្ត និងគណនេយ្យភាព គួរជួយឱ្យរដ្ឋាភិបាលការពារ គោរព និងបំពេញសិទ្ធិទទួលបានការអប់រំសម្រាប់ទាំងអស់គ្នា ដោយមិនងាកចេញពីការផ្តល់បុព្វសិទ្ធិ ឬការកេងប្រវ័ញ្ច។ ការអប់រំដែលទទួលបានថវិកាគាំទ្រពីប្រភពសាធារណៈមិនមែនត្រូវតែផ្តល់ដោយស្ថាប័នសាធារណៈនោះឡើយប៉ុន្តែភាពខុសគ្នានៃដំណើរការអប់រំលទ្ធផលសិក្សារបស់សិស្សនិងលក្ខខណ្ឌការងាររបស់គ្រូ ជាបញ្ហាដែលត្រូវតែមានការឆ្លើយតប។ គួរមានការផ្សព្វផ្សាយពីគំនិតផ្តួចផ្តើម ដើម្បីប្រសិទ្ធភាព និងនវានុវត្តន៍ ដើម្បីឱ្យទាំងអស់គ្នាយកទៅអនុវត្តចៀសជាងចាត់ទុកវាថាជាព័ត៌មានលាក់ការសម្រាប់ការធ្វើពាណិជ្ជកម្ម។ដើម្បីសម្រេចគោលដៅនេះ តម្លាភាពនិងសុចរិតភាពក្នុងដំណើរការរៀបចំគោលនយោបាយអប់រំសាធារណៈចាំបាច់ត្រូវតែបន្តមាន ដើម្បីរាំងខ្ទប់ផលប្រយោជន៍របស់បុគ្គលមួយចំនួន។

សំណួរដែលចោទសួរ–នរណាជាអ្នកជ្រើសរើស? នរណាជាអ្នកខាតបង់?–នៃរបាយការណ៍នេះអញ្ជើញអ្នកធ្វើគោលនយោបាយឱ្យចោទសួរពីទំនាក់ទំនងជាមួយនឹងតួអង្គមិនមែនរដ្ឋពាក់ព័ន្ធនឹងជម្រើសជាមូលដ្ឋានមួយចំនួន៖ ពោលគឺជម្រើសរវាងសមធម៌ និងសេរីភាពនៃការជ្រើសរើស, ជម្រើសរវាងគំនិតផ្តួចផ្តើមដែលផ្តល់ការលើកទឹកចិត្ត និងការបង្កើតស្តង់ដារ, ជម្រើសរវាងក្រុមដែលមានមធ្យោបាយ និងតម្រូវការខុសៗគ្នា, ជម្រើសរវាងការប្តេជ្ញាចិត្តចំពោះមុខក្រោមក្របខ័ណ្ឌគោលដៅ SDG ទី ៤ និងការប្តេជ្ញាចិត្តដែលត្រូវសម្រេចជាបន្តបន្ទាប់ (ឧទាហរណ៍ ការអប់រំក្រោយមធ្យមសិក្សា), និងជម្រើសរវាងវិស័យអប់រំ និងវិស័យសង្គមដទៃទៀត។

មានឧបករណ៍អនឡាញចំនួន២ដែលផ្តល់ការគាំទ្រដល់ការរៀបចំរបាយការណ៍តាមដានការអប់រំជាសកលលើកទី ៥៖ គឺឧបករណ៍ PEER ជាធនធានសម្រាប់ពិគ្រោះយោបល់កម្រិតនយោបាយដែលរៀបរាប់ពីសកម្មភាពរបស់តួអង្គមិនមែនរដ្ឋ និងលិខិតបទដ្ឋានគតិយុត្តក្នុងប្រព័ន្ធអប់រំរបស់សកលលោក និងឧបករណ៍ VIEW ដែលជាគេហទំព័រថ្មីប្រមូលផ្តុំប្រភពព័ត៌មាននានា និងផ្តល់ព័ត៌មានអំពីការប៉ាន់ប្រមាណអត្រាបញ្ចប់ការសិក្សាថ្មីៗក្នុងរយៈពេលមួយ។

unesco
Global Education Monitoring Report

Sustainable Development Goals

www.unesco.org/publishing ·www.unesco.org/gemreport